**សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច**

Université Royal de Droit et des Sciences Economiques

Royal University of law and Economics

**សារណាបញ្ចប់ការសិក្សា**

# ទណ្ឌកម្មនៃកិច្ចសន្យា

ស្រាវជ្រាវចាប់ពីថ្ងៃ ទី ២៧ ខែ មេសា ឆ្នាំ ២០២១ ដល់ថ្ងៃ ទី ២៥ ខែ មិថុនា ឆ្នាំ ២០២១


ស្រាវជ្រាវដោយ

និស្សិតឈ្មោះ **ល. មាស តុសា**

**ល. ផេន ចន្ធី**

សាស្ត្រាចារ្យណែនាំ

**លោក ជិន វណ្ណារ៉ា**


ថ្នាក់បរិញ្ញាបត្រ នីតិសាស្ត្រ

ជំនាន់ទី ២១

ឆ្នាំចូលសិក្សា ២០១៧

ឆ្នាំសរសេរសារណា ២០២១

# សេចក្ដីថ្លែងអំណរគុណ

ខ្ញុំបាទឈ្មោះ **មាស តុលា** និង ឈ្មោះ **ផេន ចន្នី** ជានិស្សិតបរិញ្ញាបត្រ ផ្នែកនីតិសាស្ត្រ ជំនាន់ទី ២១ នៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច។ សូមគោរពប្រណិបតន៏ និងថ្លែងអំណរអរគុណយ៉ាងជ្រៀវជ្រៅបំផុតជូនចំពោះ៖

-លោក **ឪពុក** និង **អ្នកម្ដាយ** ជាអ្នកមានគុណដ៏មហាសាលបំផុតចំពោះកូន។ លោកបានផ្ដល់កំណើត និងចិញ្ចឹមបីបាច់ថែរក្សា ទំនុកបំរុងកូនសព្វបែបយ៉ាង ទាំងស្មារតី ទាំងសំភារៈ ជាពិសេសលោកតែងតែផ្ដល់នូវដំបូន្មាន ប្រៀនប្រដៅកូន ដើម្បីក្លាយជា កូនល្អ សិស្សល្អ និងមិត្តល្អ ដែលជាកោសិកាមានតម្លៃសំរាប់សង្គមជាតិ។ លោកទាំងទ្វេ ហាក់ដូចជាប្រទីប ដែលបានបំភ្លឺផ្លូវជាដរាបរៀងមកចំពោះកូន ទើបកូនទទួលបានលទ្ធផលបញ្ចប់ថ្នាក់បរិញ្ញាបត្រ ផ្នែកនីតិសាស្ត្រដោយជោគជ័យបែបនេះ។

-ឯកឧត្តមបណ្ឌិត **លុយ ចណ្ណា** សាកលវិទ្យាធិការ នៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និង វិទ្យាសាស្ត្រសេដ្ឋកិច្ច ដែលបានផ្ដល់ឱកាសដល់យើងខ្ញុំ បានទទួលនូវចំណេះដឹងបន្ថែមតាមរយៈការសរសេរសារណាបញ្ចប់ការសិក្សានេះ។

-លោកសាស្ត្រាចារ្យ **ខិន ខណ្ណារ៉ា** ដែលមិនត្រឹមតែជួយបង្ហាត់បង្រៀនដល់យើងខ្ញុំបាទប៉ុណ្ណោះទេថែមទាំងចំណាយពេលវេលាដ៏មានតម្លៃជួយណែនាំ និងខិតខំបង្ហាញផ្លូវ ក្នុងការចងក្រងជាសារណាបញ្ចប់ការសិក្សានេះឡើង ព្រមទាំងផ្ដល់នូវឯកសារផ្សេងៗ ដែលយើងខ្ញុំបាទ ខ្វះលទ្ធភាពក្នុងការស្វែងរកទៀតផង។

-សាកលវិទ្យាធិការរង លោក លោកស្រីសាស្ត្រាចារ្យ និងបុគ្គលិកការិយាល័យសិក្សាស្រាវជ្រាវ ការិយាល័យសិក្សា និងបណ្ណារក្ស នៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និង វិទ្យាសាស្ត្រសេដ្ឋកិច្ច ដែលបានខិតខំអស់ពីកម្លាំងកាយចិត្ត ក្នុងការដឹកនាំ គ្រប់គ្រង រៀបចំកម្មវិធីល្អៗ ជួយជ្រោមជ្រែង និងបង្ហាត់បង្រៀនយើងខ្ញុំបាទឱ្យមានចំណេះដឹង មិនត្រឹមតែផ្នែកទ្រឹស្ដីច្បាប់នោះទេ ថែមទាំងផ្ដល់នូវបទពិសោធន៏មួយចំនួន ដែលកើតមាននៅក្នុងសង្គមទៀតផង។

សូមថ្លែងអំណរគុណទៅដល់មិត្តរួមថ្នាក់ L4A3 ទាំងអស់គ្នា ដែលបានចូលរួមគាំទ្រ និងលើកទឹកចិត្ត និងមានគំនិតកែលំអនៃស្នាដៃសារណារបស់រូបខ្ញុំបាទនេះ។

ឆ្លៀតឱកាសនេះ ខ្ញុំបាទសូមថ្លែងអំណរគុណ និងគោរពជូនពរ ឯកឧត្តមបណ្ឌិតសាកលវិទ្យាធិការ សាកលវិទ្យាធិការរង អស់លោក លោកស្រី ជាសាស្ត្រាចារ្យ និងមន្ត្រីបុគ្គលិក និងមិត្តរួមថ្នាក់ទាំងអស់សូមទទួលបាននូវភាពជោគជ័យគ្រប់ភារកិច្ច និងសមប្រកបដោយពុទ្ធពរទាំង ៤ ប្រការ គឺអាយុ វណ្ណៈសុខៈ ពលៈ កុំបីឃ្លៀងឃ្លាតឡើយ។

# អារម្ភកថា

ក្រោយពីបានសិក្សាថ្នាក់បរិញ្ញាបត្រនីតិសាស្ត្រ រយៈពេលបួនឆ្នាំរួចមក ខ្ញុំបាទទាំងពីរបានទទួលនូវចំណេះដឹងយ៉ាងច្រើនទាំងផ្នែកទ្រឹស្តី និងការលើកឡើងនូវឧទាហរណ៍ដែលកើតមានឡើងក្នុងសង្គមជាក់ស្តែងពីសំណាក់ លោក លោកស្រីសាស្ត្រាចារ្យ ដែលធ្វើឱ្យការសិក្សាផ្នែកច្បាប់នេះកាន់តែងាយស្រួលយល់ ។ ក្នុងចំណោមមុខវិជ្ជាដែលបានសិក្សាកន្លងមក ខ្ញុំបាទទាំងពីរនាក់មានការចាប់អារម្មណ៍យ៉ាងខ្លាំងទៅលើមុខវិជ្ជានីតិរដ្ឋប្បវេណី។ នេះហើយដែលជាកត្តាជំរុញចិត្តឱ្យខ្ញុំបាទទាំងពីរនាក់សម្រេចចិត្តជ្រើសរើសយកប្រធានបទ « **ទណ្ឌកម្ម នៃកិច្ចសន្យា**» មកចងក្រងជាសារណាសម្រាប់បញ្ចប់ថ្នាក់បរិញ្ញាបត្រនីតិសាស្ត្រ។

ទណ្ឌកម្មនៃកិច្ចសន្យា គឺជាមូលហេតុមួយដែលធ្វើឱ្យកិច្ចសន្យាបាត់បង់អានុភាព។ ដោយមេរៀនទណ្ឌកម្មនៃកិច្ចសន្យានេះ គឺជាមេរៀនដែលគួរឱ្យចាប់អារម្មណ៍ និងមានអត្ថប្រយោជន៍ណាស់ ដើម្បីដឹងថាតើការធ្វើកិច្ចសន្យាប្រភេទណាដែលនាំឱ្យមានទណ្ឌកម្មកើតឡើងហើយនិងប្រភេទទណ្ឌកម្មដែលមាននៅក្នុងកិច្ចសន្យានោះ។ម្យ៉ាងវិញទៀត ប្រធានបទនេះ ក៏ជាប្រធាបទមួយដែលមិនទាន់បានធ្វើការសិក្សាឱ្យបានទូលំទូលាយនៅឡើយ។ នៅក្នុងការចងក្រងសារណានេះ ខ្ញុំបាទទាំងពីរនាក់បានពឹងផ្អែកទៅលើអត្ថបទច្បាប់មួយចំនួនដូចជាៈ ក្រមរដ្ឋប្បវេណី ឆ្នាំ ២០០៧ សេចក្តីកំណត់ចំពោះមាត្រានីមួយៗ នៃក្រមរដ្ឋប្បវេណី ឆ្នាំ ២០១០ សេចក្តីពន្យល់អំពី ក្រមរដ្ឋប្បវេណី កម្រងសៀវភៅមេរៀនក្រមរដ្ឋប្បវេណី និងអត្ថបទគតិយុត្តផ្សេងទៀតជាច្រើនផងដែរ ដើម្បីធ្វើឱ្យកំហុសឆ្គងមានបន្តិចបន្តួចបំផុតតាមដែរអាចធ្វើបាន។

ខ្ញុំបាទទាំងពីរនាក់សង្ឃឹមថា សារណានេះនឹងចូលរួមចំណែកជួយសម្រួលដល់ការសិក្សាស្រាវជ្រាវរបស់សិស្ស និស្សិត និងអ្នកសិក្សាស្រាវជ្រាវដទៃទៀត ទាក់ទងនឹងទណ្ឌកម្មនៃកិច្ចសន្យា។ យ៉ាងណាមិញ ដោយសារចំណេះដឹងជាមូលដ្ឋាន ការសិក្សាស្រាវជ្រាវ ក៏ដូចជា ឯកសារសិក្សាស្រាវជ្រាវបន្ថែម និងការរៀបចំចងក្រងជាសារណារបស់ខ្ញុំបាទទាំងពីរនាក់នៅមានកម្រិត ពួកយើងជឿជាក់ថា ចំណុចខ្វះខាតពិតជាមានលេចឡើងយ៉ាងពិតប្រាកដ។ ពួកយើងរីករាយទទួលយកនូវរាល់ការរិះគន់ដើម្បីស្ថាបនាពីសំណាក់សាស្ត្រាចារ្យ រៀមច្បង និងអ្នកសិក្សាស្រាវជ្រាវទាំងអស់ដើម្បីឱ្យស្នាដៃនេះកាន់តែល្អប្រសើរឡើង។

# មាតិកា

ទំព័រ

សេចក្តីផ្តើម ........................................................................ ១

## ជំពូកទី១

## ទណ្ឌកម្មក្នុងពេលបង្កើតកិច្ចសន្យា

**១.១ សញ្ញាណចំណងគតិយុត្តនៃភាគី** ........................................................................ ៣

**១.២ គោលការណ៍ដែលផ្តល់ជាកំណើតកិច្ចសន្យា** ........................................................................ ៣

**១.៣ ប្រភេទទណ្ឌកម្មក្នុងពេលបង្កើតកិច្ចសន្យា** ........................................................................ ៣

១.៣.១ ទណ្ឌកម្មមោឃភាព ........................................................................ ៤

១.៣.១.១ ការបង្ហាញឆន្ទៈមិនពិត ........................................................................ ៤

១.៣.១.២ ភាពខុសច្បាប់ ឬ ភាពផ្ទុយនឹងសណ្តាប់ធ្នាប់សាធារណៈ និងទំនៀមទម្លាប់ល្អ ក្នុងអត្ថន័យនៃកិច្ចសន្យា........................................................................ ៥

១.៣.២ អានុភាពនៃមោឃភាព ........................................................................ ៦

១.៣.២.១ មោឃភាពដោយផ្នែក........................................................................ ៦

១.៣.២.២ បុគ្គលដែលអាចអះអាងពីមោឃភាព ........................................................................ ៦

**១.៤ ទណ្ឌកម្មលុបចោល** ........................................................................ ៧

១.៤.១ ការភាន់ច្រឡំ ........................................................................ ៧

១.៤.១.១ ការភាន់ច្រឡំពីចំណុចសំខាន់នៃកិច្ចសន្យា ដែលភាគីយល់ឃើញថាសំខាន់ ........... ៨

១.៤.១.២ ការភាន់ច្រឡំដោយភាគីទាំងសងខាង ........................................................................ ៨

១.៤.១.៣ ការការពារតតិយជន ........................................................................ ៩

១.៤.២ ការឆបោក........................................................................ ៩

១.៤.២.១ ការឆបោករបស់តតិយជន ........................................................................ ៩

១.៤.២.២ ការការពារតតិយជន ........................................................................១០

១.៤.៣ ព័ត៌មានមិនពិត ........................................................................១០

១.៤.៤ ការរំលោភបំពានលើស្ថានភាព........................................................................១១

១.៤.៥ ការគំរាមកំហែង ........................................................................១២

១.៤.៦ អំពើកេងយកចំណេញហួសហេតុ ........................................................................១២

១.៤.៧ អលទ្ធភាពតាំងពីដំបូង ............ ១៣

១.៤.៨ លក្ខខណ្ឌនៃសកម្មភាពដែលអាចលុបចោលបាន ............ ១៤

១.៤.៨.១ អ្នកដែលមានសិទ្ធិលុបចោល............ ១៤

១.៤.៨.២ ក្នុងករណីវិការៈក្នុងការបង្ហាញឆន្ទៈ ............ ១៤

១.៤.៨.៣ ករណីគ្មានសមត្ថភាពក្នុងការបង្ហាញឆន្ទៈ ............ ១៥

១.៤.៩ វិធីលុបចោល ឬ សច្ចានុមតិ ............ ១៥

១.៤.៩.១ អ្នកដែលមានសិទ្ធិផ្តល់សច្ចានុមតិ និងលក្ខខណ្ឌនៃការផ្តល់សច្ចានុមតិ............ ១៥

១.៤.៩.២ សច្ចានុមតិដែលច្បាប់កំណត់ ............ ១៦

១.៤.៩.៣ អាជ្ញាយុកាលនៃការរំលត់សិទ្ធិលុបចោល............ ១៦

**១.៥ ទណ្ឌកម្មបដិសេធ ............ ១៧**

១.៥.១ ឋបនីយផ្លូវចិត្ត............ ១៧

១.៥.២ ការពារតតិយជន ............ ១៨

## ជំពូកទី២

## ទណ្ឌកម្មក្រោយពេលបង្កើតកិច្ចសន្យា

**២.១ ការមិនអនុវត្តកាតព្វកិច្ច ............ ១៩**

២.១.១ ទម្រង់នៃការមិនអនុវត្តកាតព្វកិច្ច ............ ១៩

២.១.១.១ ការយឺតយ៉ាវក្នុងការអនុវត្តកាតព្វកិច្ច ............ ១៩

២.១.១.២ អលទ្ធភាពក្នុងការអនុវត្តកាតព្វកិច្ច ............ ២០

២.១.២.៣ ការអនុវត្តកាតព្វកិច្ចមិនបានពេញលេញ............ ២០

២.១.២.៤ ករណីផ្សេងនៃការមិនអនុវត្តកាតព្វកិច្ច ............ ២០

**២.២ ការអនុវត្តកាតព្វកិច្ចដោយបង្ខំ............ ២១**

២.២.១ ប្រភេទនៃការអនុវត្តកាតព្វកិច្ចដោយបង្ខំ ............ ២១

២.២.១.១ ការអនុវត្តដោយផ្ទាល់............ ២១

២.២.១.២ ការអនុវត្តជំនួស ............ ២១

២.២.១.៣ វិធានបង្ខំដោយប្រយោល ............ ២២

**២.៣ ការទាមទារសំណងនៃការខូចខាត............ ២២**

២.៣.១ លក្ខខណ្ឌចំពោះកាតព្វកិច្ចជាប្រាក់ ............ ២៣

២.៣.២ ករណីដែលកូនបំណុលឱ្យអ្នកដទៃជាអ្នកជំនួយ............ ២៣

២.៣.៣ ទស្សនៈអំពីការខូចខាត ....................................................................................... ២៣
២.៣.៣.១ ការបាត់បង់ផលប្រយោជន៍ពីការអនុវត្ត ................................................... ២៤
២.៣.៣.២ ការចំណាយផ្សេងៗដែលទាក់ទងនឹងកិច្ចសន្យា........................................ ២៤
២.៣.៣.៣ ការខូចខាតផ្លូវចិត្ត .................................................................................. ២៤
២.៣.៤ ទំហំនៃសំណងការខូចខាត.................................................................................... ២៥
២.៣.៤.១ ការខូចខាតធម្មតា.................................................................................... ២៥
២.៣.៤.២ ការខូចខាតពិសេស .................................................................................. ២៥
២.៣.៤.៣ ការមិនអនុវត្តកាតព្វកិច្ចដោយផ្អែកលើគំនិតព្យាបាទ ឬអំពើមិនស្មោះត្រង់ហួសហេតុ ................................................................................................................ ២៦
២.៣.៥ មូលហេតុដែលនាំឱ្យបន្ថយសំណងការខូចខាត .................................................... ២៦
២.៣.៦ គោលការណ៍នៃការសងការខូចខាតជាប្រាក់ ........................................................ ២៧
២.៣.៧ ចំណុចដែលជាមូលដ្ឋាននៃពេលដែលត្រូវគណនាការខូចខាត................................. ២៧
២.៣.៨ ការកំណត់ជាមុននូវសំណងការខូចខាត............................................................... ២៨
២.៣.៨.១ លក្ខខណ្ឌនៃការកំណត់ជាមុននូវចំនួននៃសំណង........................................ ២៨
២.៣.៨.២ អានុភាពនៃការកំណត់ជាមុននៃចំនួននៃសំណង.......................................... ២៩
២.៣.៨.៣ ប្រាក់ធានាសំណងនៅក្នុងករណីបំពានកិច្ចសន្យា និងការកំណត់ជាមុននូវចំនួននៃសំណង .................................................................................................... ៣០
២.៣.៩ ឧបាទេសកម្មនៃអ្នកសង ...................................................................................... ៣០
២.៣.១០ អាជ្ញាយុកាលនៃការរំលត់សិទ្ធិទាមទារសំណង.................................................... ៣១
**២.៤ ការរំលាយកិច្ចសន្យា** ........................................................................................... ៣១
២.៤.១ ប្រភេទនៃសិទ្ធិរំលាយកិច្ចសន្យា........................................................................... ៣១
២.៤.១.១ ប្រភេទនៃសិទ្ធិរំលាយកិច្ចសន្យាដែលបានកំណត់នៅក្នុងច្បាប់....................... ៣២
២.៤.១.២ សិទ្ធិរំលាយកិច្ចសន្យាដែលបានកំណត់នៅក្នុងកិច្ចសន្យា ............................ ៣២
២.៤.១.៣ ប្រភេទសិទ្ធិរំលាយកិច្ចសន្យាដែលផ្អែកលើបញ្ញត្តិពិសេស ........................... ៣២
២.៤.២ ប្រព័ន្ធប្រហាក់ប្រហែលនិងការរំលាយកិច្ចសន្យា.................................................... ៣២
២.៤.២.១ ការរំលាយកិច្ចសន្យាដោយការព្រមព្រៀង................................................... ៣៣
២.៤.២.២ ការលុបចោលកិច្ចសន្យា.......................................................................... ៣៣

២.៤.៣ លក្ខខណ្ឌនៃការរំលាយកិច្ចសន្យា ........ ៣៤
២.៤.៣.១ ការយឺតយ៉ាវក្នុងការអនុវត្តកាតព្វកិច្ច ........ ៣៥
២.៤.៣.២ អលទ្ធភាពក្នុងការអនុវត្តកាតព្វកិច្ចចំពោះពេលវេលា ........ ៣៥
២.៤.៣.៣ អលទ្ធភាពក្នុងការអនុវត្តកាតព្វកិច្ច ........ ៣៥
២.៤.៣.៤ ការបាត់បង់ទំនុកចិត្តរវាងភាគី ........ ៣៦
២.៤.៤ វិធីអនុវត្តសិទ្ធិរំលាយកិច្ចសន្យា ........ ៣៦
២.៤.៥ អានុភាពនៃការរំលាយកិច្ចសន្យា ........ ៣៧
២.៤.៥.១ ការរលត់នូវករណីកិច្ចក្នុងកិច្ចសន្យា ........ ៣៩
២.៤.៥.២ ករណីបដិទានទៅស្ថានភាពដើមវិញ ........ ៣៩
២.៤.៥.៣ ទំហំនៃករណីកិច្ចធ្វើបដិទាន ........ ៣៩
២.៤.៥.៤ ការការពារតតិយជន ........ ៤០
២.៤.៦ ការរលត់នូវសិទ្ធិរំលាយកិច្ចសន្យា ........ ៤០
២.៤.៦.១ ការអនុវត្តកាតព្វកិច្ច ឬ សំណើរផ្តល់ការអនុវត្តកាព្វកិច្ច ........ ៤០
២.៤.៦.២ ការខូចខាតកម្មវត្ថុនៃកិច្ចសន្យាដោយចេនា ........ ៤០
២.៤.៦.៣ អាជ្ញាយុកាល ........ ៤១
**សេចក្តីសន្និដ្ឋាន ........ ៤២**
**អនុសាសន៍ ........ ៤៣**
**ឯកសារយោង**
**ឧបសម្ព័ន្ធ**

# សេចក្ដីផ្ដើម

# សេចក្តីផ្តើម

មនុស្សរស់នៅក្នុងសង្គមរមែងតែងតែមានទំនាក់ទំនងគ្នាជាប្រចាំ ។ ទំនាក់ទំនងអាចកើតមានពីមនុស្សម្នាក់ និងមនុស្សម្នាក់ទៀត ឬក៏ជាទំនាក់ទំនងដែលកើតមាននៅក្នុងសង្គមគ្រួសារ សហគមន៍ សមាគម អង្គភាព ឬម៉្យាងទៀត វាក៏អាចជាទំនាក់ទំនងដែលមាននៅក្នុងមុខរបររកស៊ី អាជីវកម្មពាណិជ្ជកម្មផ្សេងៗ ។ ទំនាក់ទំនងទាំងនោះ ត្រូវបានស្តែងចេញជា សកម្មភាពជាច្រើនផ្សេងៗគ្នា ខ្លះជាសកម្មភាពដែលបង្ហាញជាចរឹតលក្ខណៈគ្រួសារ មនោសញ្ចេតនា មិត្តភក្តិ ឬក៏អាចឈានដល់ទំនាក់ទំនងដែលជាសកម្មភាពផ្លូវច្បាប់ផងដែរ ។ ចំណងជាចរឹតច្បាប់នេះ ឬអាចហៅម៉្យាងទៀតថា ចំណងគតិយុត្តដែលត្រូវបានរំលេចចេញជា សិទ្ធិ និងកាតព្វកិច្ច ដែលអាចកើតមានឡើងតាមរយៈ ទង្វើក្រៅឆន្ទៈ ឬអាចកើតតាមរយៈការសម្តែងឆន្ទៈរបស់បុគ្គលម្នាក់ ឬតាម ឆន្ទៈនៃក្រុមមួយ និងបុគ្គលម្នាក់ទៀត ឬក្រុមមួយផ្សេងទៀតដែលជាចំណងតាមកិច្ចសន្យា។ តើអ្វីជាកិច្ចសន្យា ?

កិច្ចសន្យា គឺជាកិរិយាដែលបុគ្គលពីរនាក់ ឬច្រើននាក់មានឆន្ទៈត្រូវគ្នាព្រមបង្កើត ឬកែប្រែ ឬរំលត់កាតព្វកិច្ច។

ក្នុងនោះផងដែរ ទំនាក់ទំនងនៃជីវភាពរស់នៅ ឬជីវភាពនៃកិច្ចការជំនួញ កិច្ចសន្យាត្រូវបានបង្កើតឡើងមានច្រើនបែបច្រើនយ៉ាង វាមាន ដូចជា ការលក់ ទិញ ជួល ខ្ចីលុយ ខ្ចីឡាន ឬ ម៉ូតូ ជាអាទ៍ ការធ្វើអំណោយ ការចុះកិច្ចសន្យាការងារ ការធ្វើកិច្ចសន្យាម៉ៅការ ការទទួលអាណត្តិដើម្បីបំពេញកិច្ចការជាក់លាក់ណាមួយ ការទទួលបញ្ញើ ដូចជា ផ្ញើឡាន ម៉ូតូ ឬបញ្ញើប្រាក់នៅធនាគារ ជាអាទិ៍។ សកម្មភាពទាំងនេះ គឺសុទ្ធតែជាសកម្មភាពនៃកិច្ចសន្យា ដែលបង្កើតនូវសិទ្ធិ និងកាតព្វកិច្ចចំពោះភាគី ហើយត្រូវមានបទប្បញ្ញត្តិសម្របសម្រួល ដើម្បីធានានូវការគោរពសិទ្ធិរបស់បុគ្គល និងបង្កើតទំនុកចិត្តរវាងភាគីដែលបង្កើតនូវសកម្មភាពទាំងនោះ ក្នុងគោលដៅធានានូវផលប្រយោជន៍របស់ភាគី និងសកម្មភាពរបស់ភាគី សម្រាប់ចរាចរ ឬដោះដូរទំនិញ សេវា ជាអាទិ៍ ផងដែរ ដែលជាផ្នែកមួយនៃការបង្កើតសកម្មភាពពាណិជ្ជកម្ម ដែលជាដង្ហើម និងសរសៃឈាមរបស់ប្រទេសជាតិ ។

ដោយមើលឃើញពីសារៈសំខាន់នៃទំនាក់ទំនងគតិយុត្តដែលបានផ្តើមបង្ហាញបន្តិចខាងលើនេះការសិក្សាដែលជាសំណេរជាសារណានេះ បានផ្តោតទៅលើប្រធានបទ ‹‹**ទណ្ឌកម្មនៃកិច្ចសន្យា**››។ សារណានេះ មានប្រភពស្រាវជ្រាវជាគោលការណ៍គ្រឹះ គឺក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧ និងមានជាឯកសារជំនួយផ្សេងៗទៀតរបស់សាស្ត្រាចារ្យផ្នែកច្បាប់ រួមទាំង ឯកសារដែលមានតម្កល់នៅក្នុងបណ្ណាល័យ ដែលពាក់ព័ន្ធទៅនឹងប្រធានបទខាងលើនេះ ហើយពោលពេញទៅដោយគំនិតល្អៗជាគន្លឹះដើម្បីធ្វើឱ្យការស្រាវជ្រាវមួយនេះកាន់តែមានភាពល្អប្រសើរថែមមួយកម្រិតទៀត។

សំណេរសារណានេះ ត្រូវបានកំណត់ជាប្លង់បកស្រាយ ជាពីរ ជំពូក ។ ជំពូកទី១ ត្រូវបានបង្ហាញពីទណ្ឌកម្មនៅពេលបង្កើតកិច្ចសន្យា និងជំពូកទី២ ត្រូវបានបកស្រាយពីទណ្ឌកម្មដែលនឹងកើតមានឡើងក្រោយពេលកិច្ចសន្យាបានកើតឡើងហើយ។

# ជំពូកទី១
# ទណ្ឌកម្មក្នុងពេលបង្កើតកិច្ចសន្យា

# ជំពូកទី១

# ទណ្ឌកម្មក្នុងពេលបង្កើតកិច្ចសន្យា

## ១.១.សញ្ញាណចំណងគតិយុត្តនៃភាគី

ចំណងសិទ្ធិ និងកាតព្វកិច្ចដែលកើតពីឆន្ទៈភាគី សងខាងត្រូវបានកំណត់ព្រមព្រៀងគ្នាតាមកិច្ចសន្យា ។

កិច្ចសន្យា គឺជាកិរិយាដែលបុគ្គលពីរនាក់ ឬច្រើននាក់មានឆន្ទៈត្រូវគ្នាព្រម បង្កើត កែប្រែ ឬរំលត់កាតព្វកិច្ច។[1] ក្នុងន័យនេះ កិច្ចសន្យាគឺជាការត្រូវគ្នានៃឆន្ទៈដែលចង់បង្កើត កែប្រែ ឬរំលត់កាតព្វកិច្ច។ កិច្ចសន្យាដែលបង្កើតឡើងត្រូវតែបម្រើឱ្យផលប្រយោជន៍បុគ្គល នឹងប្រយោជន៍សង្គមហើយភាគីនៃកិច្ចសន្យាត្រូវអនុវត្តកិច្ចសន្យាដោយស្មោះត្រង់ និងសីលធម៌សង្គម ។

ម៉្យាងទៀតកិច្ចសន្យា ក៏ជាប្រភពមួយនៃការបង្កើតឱ្យមានកាតព្វកិច្ច ដែលជាចំណងគតិយុត្តចងបុគ្គលដែលបានសម្តែងឆន្ទៈព្រមព្រៀងទាំងសងខាង ដោយឱ្យបុគ្គលជាភាគីម្ខាងដែលបានកំណត់មានករណីកិច្ចចំពោះបុគ្គលដែលបានកំណត់ថាជាភាគីម្ខាងទៀត ។

## ១.២.គោលការណ៍ដែលផ្តល់ជាកំណើតកិច្ចសន្យា

កិច្ចសន្យា មានអានុភាពនៅពេលដែលសំណើ និងស្វីការត្រូវគ្នា។[2] ប៉ុន្តែនៅក្នុងករណីដែលការបង្ហាញឆន្ទៈមានវិការៈ ឬសកម្មភាពនេះផ្ទុយនឹងច្បាប់ ឬមិនស្របនឹងភាពត្រឹមត្រូវទៅនឹងទំនៀមទម្លាប់ល្អរបស់សង្គម នោះអានុភាពនឹងត្រូវបានបដិសេធ។ ដូចនេះដើម្បីឱ្យកិច្ចសន្យាមួយមានសុពលភាពកិច្ចសន្យានោះត្រូវបំពេញឱ្យបាននូវលក្ខខណ្ឌចាំបាច់ គឺសំណើ និង ស្វីការ ត្រូវគ្នា។

ពិតប្រាកដណាស់ ! ប្រសិនបើកិច្ចសន្យាត្រូវបានបង្កើតឡើងមិនមានវិការៈ ឬ មិនផ្ទុយនឹងច្បាប់ទំនៀមទម្លាប់ល្អរបស់សង្គមទេ នោះវាមិនត្រូវបានទទួលទណ្ឌកម្មឡើយ ។ ប៉ុន្តែផ្ទុយទៅវិញបើវាត្រូវបានរកឃើញថាពិតជាមានវិការៈ ឬ ផ្ទុយនឹងច្បាប់ទំនៀមម្លាប់ល្អរបស់សង្គមនោះហើយវាពិតជាមានទណ្ឌកម្មជាក់ជាមិនខាន។

តើទណ្ឌកម្មមានប្រភេទអ្វីខ្លះ? និងមានអត្ថន័យយ៉ាងណាដែរ ?

## ១.៣ ប្រភេទទណ្ឌកម្មក្នុងពេលបង្កើតនៃកិច្ចសន្យា

កិច្ចសន្យាដែលមានសុពលភាពត្រូវតែកើតឡើងដោយសារ ការព្រមព្រៀងពិតប្រាកដ និងដោយសេរីរបស់គូភាគី ។ ហើយការព្រមព្រៀងពិតប្រាកដនិងដោយសេរីត្រូវតែកើតចេញពីឆន្ទៈពិតប្រាកដរបស់ភាគីដើម្បីបង្កើត

[1] មាត្រា៣១១ នៃក្រមរដ្ឋប្បវេណីឆ្នាំ ២០០៧

[2] មាត្រា៣៣៦ កថាខណ្ឌទី១ នៃក្រមរដ្ឋប្បវេណីឆ្នាំ ២០០៧

កិច្ចសន្យាពោលគឺ ការព្រមព្រៀងនេះត្រូវតែគ្មានវិការៈក្នុងការបង្ហាញឆន្ទៈជាដាច់ខាត។ ដែលវិការៈក្នុងការបង្ហាញឆន្ទៈមានដូចជា ការភាន់ច្រឡំ ការឆបោក ព័ត៌មានមិនពិត ការរំលោភបំពានលើស្ថានភាពការគំរាមកំហែង អំពើកេងយកចំណេញហួសហេតុព្រមទាំង បបយនីផ្លូវចិត្ត និងការបង្ហាញឆន្ទៈមិនពិត ជាដើម។

**១.៣.១ ទណ្ឌកម្មមោឃភាព**

ប្រសិនបើអត្ថន័យ នៃសកម្មភាពផ្ទុយនឹងបញ្ញត្តិដែលអនុវត្តដោយបង្ខំ ឬផ្ទុយនឹងសណ្តាប់ធ្នាប់សាធារណៈ និង ទំនៀមទម្លាប់ល្អ ជនណាក៏អាចអះអាងនូវមោឃភាពនៃកិច្ចសន្យានោះបាន។ ជាការពិតណាស់មានករណីនៃមោឃភាពជាច្រើនរួមមានករណីដែលសកម្មភាពត្រូវទុកជាមោឃៈដោយសារអត្ថន័យនៃកិច្ចសន្យាផ្ទុយនឹងបញ្ញត្តិដែលអនុវត្តដោយបង្ខំ ឬ សណ្តាប់ធ្នាប់សាធារណៈ និងទំនៀមទម្លាប់ល្អ និង ករណីដែលសកម្មភាពត្រូវទុកជាមោឃៈ ដោយសារសកម្មភាពនោះផ្ទុយនិងទម្រង់ដែលត្រូវបានទាមទារដោយក្រមនេះ(ក្រមរដ្ឋប្បវេណីឆ្នាំ ២០០៧) ឬ ច្បាប់ផ្សេង។[3] ដែលសកម្មភាពដែលនាំឱ្យមានទណ្ឌកម្មបែបមោឃៈនោះមានដូចជា ការបង្ហាញឆន្ទៈមិនពិត ភាពផ្ទុយច្បាប់ ឬ ភាពផ្ទុយនឹងសណ្តាប់ធ្នាប់សាធារណៈ និង ទំនៀមទម្លាប់ល្អ និង អលទ្ធភាពតាំងពីដំបូង។

**១.៣.១.១ ការបង្ហាញឆន្ទៈមិនពិត**

ការបង្ហាញឆន្ទៈមិនពិត គឺជាការបង្ហាញឆន្ទៈខុសពីការពិតដែលបានធ្វើឡើងដោយការឃុបឃិតជាមួយនឹងភាគីម្ខាងទៀត។ កិច្ចសន្យាដោយផ្អែកលើការបង្ហាញ ឆន្ទៈមិនពិតដែលត្រូវបានធ្វើឡើង ដោយមានការឃុបឃិតជាមួយនឹងភាគីម្ខាងទៀត ត្រូវចាត់ទុកជាមោឃៈ។[4]

នៅក្នុងករណីបបនីយផ្លូវចិត្ត មានតែអ្នកបង្ហាញឆន្ទៈទេ ដែលបង្ហាញនូវឆន្ទៈមិនពិតប្រាកដប៉ុន្តែ នៅក្នុងករណីការបង្ហាញឆន្ទៈមិនពិត មិនត្រឹមតែ អ្នកបង្ហាញឆន្ទៈទេ ថែមទាំងភាគីម្ខាងទៀតបានដឹងថា ការបង្ហាញឆន្ទៈរបស់គេគឺមិនពិត។ ដូចនេះមានន័យថា ភាគីទាំងពីរនៃកិច្ចសន្យាបានបង្ហាញឆន្ទៈមិនពិតដូចគ្នា។

**លក្ខខណ្ឌដើម្បីបង្ហាញពីការបង្ហាញឆន្ទៈមិនពិតមានដូចជា៖**

១.អ្នកបង្ហាញឆន្ទៈបានបង្ហាញឆន្ទៈ ដែលមិនឆ្លើយតបទៅនឹងឆន្ទៈពិតប្រាកដរបស់ខ្លួន វាមានន័យថា អ្នកដែលបង្ហាញ ឆន្ទៈបានដឹងថា ឆន្ទៈដែលបានបង្ហាញជាក់ស្តែងនោះ មិនមែនជាឆន្ទៈពិតប្រាកដនៅក្នុងចិត្តរបស់ខ្លួនឡើយ។

២.អ្នកបង្ហាញឆន្ទៈបានបង្ហាញនូវឆន្ទៈនិង ភាគីម្ខាងទៀតបានឃុបឃិតគ្នា ដើម្បីបង្កើតនូវទិដ្ឋទិភាពមួយដែលខុសពីការពិតវាមានន័យថាភាគីទាំងសងខាងបានត្រូវរ៉ូវគ្នាបង្កើតទិដ្ឋភាពមួយដែលមិនមែនជាការពិត។

[3] សេចក្តីកំណត់ ចំពោះមាត្រានីមួយៗ នៃក្រមរដ្ឋប្បវេណី ឆ្នាំ ២០១០ មាត្រា ៣៥៧

[4] មាត្រា ៣៥៣ កថាខណ្ឌទី១ នៃក្រមរដ្ឋប្បវេណី ឆ្នាំ ២០០៧

ដូចដែរបានលើកឡើង កិច្ចសន្យាដែលបានបង្កើតឡើងដោយសារការបង្ហាញឆន្ទៈមិនពិតត្រូវបានចាត់ទុកជាមោឃៈព្រោះគេមិនចាំបាច់ការពារភាគីម្ខាងទៀត។

មោឃភាពនៃកិច្ចសន្យា ដែលបានកំណត់នៅក្នុង ការបង្ហាញឆន្ទៈមិនពិតនេះមិនអាចអះអាងចំពោះតតិយជនដែលមានទំនាក់ទំនងផលប្រយោជន៍ដោយយកកិច្ចសន្យាដែលផ្អែកលើការបង្ហាញឆន្ទៈមិនពិតជាមូលដ្ឋានបានឡើយ។ ប៉ុន្តែ បញ្ញត្តិនេះមិនត្រូវយកមកអនុវត្តឡើយ ចំពោះករណីដែលតតិយជននោះជាជនទុចរិត ឬ មិនបានដឹងអំពីការបង្ហាញនូវ ឆន្ទៈមិនពិត ដោយសារមានកំហុសធ្ងន់ធ្ងរ។[5]

**១.៣.១.២ ភាពខុសច្បាប់ ឬ ភាពផ្ទុយនឹងសណ្តាប់ធ្នាប់សាធារណៈ និង ទំនៀមទម្លាប់ល្អ ក្នុងអត្ថន័យនៃកិច្ចសន្យា**

ទោះបីជាភាគីនៃកិច្ចសន្យាបានធ្វើការបង្ហាញឆន្ទៈដោយគ្មានវិការៈក៏ដោយក៏កិច្ចសន្យាត្រូវបានចាត់ទុកជាមោឃៈនៅក្នុងករណីដូចខាងក្រោម៖

- អត្ថន័យនៃកិច្ចសន្យានោះផ្ទុយនឹងបញ្ញត្តិដែលអនុវត្តដោយបង្ខំណាមួយ។
- អត្ថន័យនៃកិច្ចសន្យានោះផ្ទុយនឹងសណ្តាប់ធ្នាប់សារធារណៈ និង ទំនៀមទម្លាប់ល្អ។

ទោះបីជាការបង្ហាញឆន្ទៈ របស់ភាគីទាំងពីរត្រូវបានធ្វើដោយគ្មានមូលហេតុនៃមោឃភាព ឬ ការលុបចោលក៏ដោយ ក៏កិច្ចសន្យាត្រូវចាត់ទុកជាមោឃៈដែរ ប្រសិនបើអត្ថន័យនៃកិច្ចសន្យាផ្ទុយនឹងបញ្ញត្តិ ដែលដោយអនុវត្តដោយបង្ខំ ឬ សណ្តាប់ធ្នាប់សាធារណៈ និង ទំនៀមទម្លាប់ល្អ។ បញ្ញត្តិដែលអនុវត្តដោយបង្ខំ គឺជាបញ្ញត្តិដែលបដិសេធអានុភាព នៃសកម្មភាពដែលផ្ទុយនឹងបញ្ញត្តិនេះ។ ដូច្នេះ ប្រសិនដោយបង្ខំ គឺជាបញ្ញត្តិដែលបដិសេធអានុភាព នៃសកម្មភាពដែលផ្ទុយនឹងបញ្ញត្តិនេះ។ ដូច្នេះ ប្រសិនអត្ថន័យ នៃកិច្ចសន្យាផ្ទុយនឹងបញ្ញត្តិដែលអនុវត្តដោយបង្ខំកិច្ចសន្យានោះទុកជាមោឃ។[6] ឧទាហរណ៏៖ ក្នុងគ្រឹះស្ថានប្រភេទណាក៏ដោយ ទោះបីជាគ្រឹះស្ថាននោះមានលក្ខណៈជាការសិក្សាវិជ្ជាជីវៈ ឬជាកិច្ចកុសល ព្រមទាំងនៅក្នុងវិជ្ជាជីវៈ សេរីក៏ដោយចិរវេលាធ្វើការពេញលេញនៃកម្មករនិយោជិកទាំងពីរភេទ មិនត្រូវឱ្យលើសពីប្រាំបីម៉ោងក្នុងមួយថ្ងៃ ឬសែសិបប្រាំបីម៉ោងក្នុងមួយអាទិត្យឡើយ។[7]

ដូចនេះប្រសិនបើនិយោជកនិងកម្មករនិយោជិកបានធ្វើកិច្ចសន្យាការងារដែលមានចិរវេលាធ្វើការច្រើនជាងបញ្ញត្តិនេះត្រូវទុកជាមោឃៈ។

[5] មាត្រា ៣៥៣ កថាខណ្ឌទី២ នៃក្រមរដ្ឋប្បវេណី ឆ្នាំ ២០០៧

[6] សេចក្តីកំណត់ ចំពោះមាត្រា នីមួយៗនៃក្រមរដ្ឋប្បវេណី ឆ្នាំ ២០១០ មាត្រា ៣៥៤ កថាខណ្ឌទី១

[7] មាត្រា ១៣៧ នៃច្បាប់ស្តីពីការងារ ឆ្នាំ ១៩៩៧

### ១.៣.២. អានុភាពនៃមោឃភាព

សកម្មភាពដែលទុកជាមោឃៈ មិនមានអានុភាពតាំងពីដំបូង ចាប់តាំងពីពេលធ្វើសកម្មភាព។ ប្រសិនបើភាគី បានអនុវត្តកាតព្វកិច្ច ដោយផ្អែកលើកិច្ចសន្យាដែលត្រូវទុកជាមោឃៈ ជាទូទៅភាគីម្ខាងទៀតត្រូវសងតាវកាលិកនោះមកវិញ ដោយផ្អែកលើសេចក្ដីចម្រើនឥតហេតុ។ ក៏ប៉ុន្តែ ក្នុងករណីដែលការទាមទាររបស់បុគ្គលដែលត្រូវខូចខាតផលប្រយោជន៍ចំពោះបុគ្គលដែលបានទទួលផលប្រយោជន៍នោះផ្ទុយនឹងរបៀបរាបរយសាធារណៈ ឬ ទំនៀមទម្លាប់ល្អ ឬច្បាប់ដែលទាក់ទងនឹងសណ្ដាប់ធ្នាប់សាធារណៈ ការទាមទារឱ្យសងនោះ ពុំត្រូវបានអនុញ្ញាតឡើយ។[8]

ម្យ៉ាងវិញទៀត គេអាចផ្ដល់សច្ចានុមតិទៅលើ សកម្មភាពដែលអាចចាត់ទុកជាមោឃៈបាន។ ប៉ុន្តែ ប្រសិនបើ បញ្ញត្តិដែលអនុវត្តដោយបង្ខំ ដែលជាមូលហេតុនៃមោឃភាពនៃសកម្មភាពនោះនៅតែមានអានុភាពនៅពេលផ្ដល់សច្ចានុមតិឬការចាយតំលៃអំពីភាពផ្ទុយនឹងសណ្ដាប់ធ្នាប់សាធារណៈ នឹងទំនៀមទម្លាប់ល្អនៅតែមិនមានការផ្លាស់ប្ដូរនៅពេលផ្ដល់សច្ចានុមតិទោះបីជាសកម្មភាពនោះ ត្រូវបានផ្ដល់សច្ចានុមតិក៏ដោយ ក៏សកម្មភាពត្រូវចាត់ទុកជាមោឃៈដែរ។

#### ១.៣.២.១ មោឃភាពដោយផ្នែក

ប្រសិនបើអត្ថន័យនៃកិច្ចសន្យាមានផ្នែកណាមួយដែលផ្ទុយ នឹងបញ្ញត្តិដែលអនុវត្តដោយបង្ខំ ឬផ្ទុយនឹងសណ្ដាប់ធ្នាប់សាធារណៈ និងទំនៀមទម្លាប់ល្អ ហើយទោះបីជាទុកផ្នែកផ្សេងទៀតក៏មិនធ្វើឱ្យខូច សេចក្ដីសង្ឃឹមសមហេតុសមផលរបស់គូភាគីទេនោះ មានតែចំណុចដែលផ្ទុយនឹង បញ្ញត្តិដែលអនុវត្តដោយបង្ខំ ឬ ផ្ទុយនឹងសណ្ដាប់ធ្នាប់សាធារណៈ និងទំនៀមទម្លាប់ល្អតែប៉ុណ្ណោះទេដែលត្រូវទុកជាមោឃៈ។[9] ដែលនេះគឺជាមោឃភាពដោយផ្នែក។ ឧទាហរណ៍៖ មាត្រា ៥៨៥ កថាខណ្ឌ ទី៣ បានចែងថា ប្រសិនបើ អត្រាការប្រាក់ដែលព្រមព្រៀងលើសពីអត្រាការប្រាក់ដែលបានកម្រិត ការព្រមនោះត្រូវទុកជាមោឃៈ ប៉ុន្តែ អ្នកខ្ចី មានករណីកិច្ចសងតែចំពោះការប្រាក់ដែលត្រូវបាន គណនាការប្រាក់ដែលត្រូវបានកម្រិតនោះតែប៉ុណ្ណោះ។

#### ១.៣.២.២ បុគ្គលដែលអាចអះអាងពីមោឃភាព

ក្នុងករណីដែលសកម្មភាពដែលត្រូវបានចាត់ទុកជាមោឃៈ ដោយសារសកម្មភាពនោះផ្ទុយនឹងទម្រង់ដែលត្រូវបានទាមទារឱ្យមាន ដោយក្រមនេះ (ក្រមរដ្ឋប្បវេណី ឆ្នាំ ២០០៧) ឬ ច្បាប់ផ្សេងជនណាក៏អាចអះអាងនូវមោឃភាពនៃកិច្ចសន្យានោះបាន។[10]

---

[8] មាត្រា ៧៤១ នៃក្រមរដ្ឋប្បវេណី ឆ្នាំ ២០០៧

[9] មាត្រា ៣៥៧ វាក្យខណ្ឌទី២ នៃក្រមរដ្ឋប្បវេណី ឆ្នាំ ២០០៧

[10] មាត្រា ៣៥៧ វាក្យខណ្ឌទី២ នៃក្រមរដ្ឋប្បវេណី ឆ្នាំ ២០០៧

ក្នុងករណីដែលអត្ថន័យនៃកិច្ចសន្យា និងសកម្មភាពឯកតោភាគី ត្រូវទុកជាមោឃៈដោយសារផ្ទុយនឹងបញ្ញត្តិដែលអនុវត្តដោយបង្ខំ ឬ សណ្តាប់ធ្នាប់សាធារណៈ និងទំនៀមទម្លាប់ល្អ មិនមែនតែភាគីនៃកិច្ចសន្យា ឬសកម្មភាពឯកតោភាគីទេ រួមទាំងបុគ្គលផ្សេងទៀតក៏អាចអះអាងអំពីមោឃភាពនៃសកម្មភាពនោះបានដែរ។ ការកំណត់ថា សកម្មភាពមួយត្រូវទុកជាមោឃៈបែបនេះ គឺដើម្បីហាមឃាត់កិច្ចសន្យា ឬសកម្មភាពឯកតោភាគី (មតកសាសន៍ ជាអាទិ៍) ដែលផ្ទុយនឹងបញ្ញត្តិដែលអនុវត្តដោយបង្ខំ ឬ សណ្តាប់ធ្នាប់សាធារណៈ និងទំនៀមទម្លាប់ល្អ ហេតុនេះវាត្រឹមត្រូវដែលបញ្ញត្តិនៃមាត្រានេះចែងថា ជនណាក៏អាចអះអាង អំពីមោឃភាពនៃសកម្មភាពបានដែរ។[11] ដូច្នេះ ហើយជនណាក៏អាចអះអាងពីមោឃភាព នៃសកម្មភាពនោះបានគ្រប់ពេលដោយ មិនមានអាជ្ញាយុកាលរំលត់ឡើយ។

## ១.៤. មោឃកម្មលុបចោល

អ្នកដែលបង្ហាញឆន្ទៈអាចលុបចោលកិច្ចសន្យាបានដោយហេតុថា ការបង្ហាញឆន្ទៈមានវិការៈ។[12] កិច្ចសន្យាមានអានុភាព នៅពេលការបង្ហាញឆន្ទៈ របស់ភាគីទាំងពីរស្របគ្នាទៅវិញទៅមក។ ហេតុដូច្នេះហើយ ប្រសិនបើគ្មានការបង្ហាញឆន្ទៈ ដែលមានអានុភាពដែលជាធាតុផ្សំនៃកិច្ចសន្យាទេ កិច្ចសន្យាពុំមានចំណងចងភាគីទាំងពីរទេទោះបីជា កិច្ចសន្យាហាក់ដូចជា ត្រូវបានបង្កើតឡើងបើមើលពីខាងក្រៅក៏ដោយ។ តាមន័យនេះហើយការង្ហាញឆន្ទៈដែលមានសុពលភាព គឺជាលក្ខខណ្ឌដើម្បីឱ្យកិច្ចសន្យាមានអានុភាពចងភាគីទាំងសងខាង។ ហើយវិការៈដែលនាំឱ្យមានការលុបចោល ដូចជា៖ ការភាន់ច្រឡំ ការឆបោក ព័ត៌មានមិនពិត ការរំលោភបំពានលើស្ថានភាព ការគំរាមកំហែង និងអំពើកេងយកចំណេញហួសហេតុ។

### ១.៤.១. ការភាន់ច្រឡំ

ក្នុងករណីដែលភាគីមានការភាន់ច្រឡំអំពីចំណុចសំខាន់ៗ នៃកិច្ចសន្យា បើភាគីម្ខាងទៀតបានស្ថិតនៅក្នុងស្ថានភាពដែលអាចដឹងអំពី ការភាន់ច្រឡំនេះដែលបានដែល បានភាន់ច្រឡំអាចលុបចោលកិច្ចសន្យាបានដោយហេតុថា ការបង្ហាញឆន្ទៈនោះមានវិការៈ។ ភាគីដែលមានការភាន់ច្រឡំត្រូវបានអនុញ្ញាតឱ្យលុបចោលកិច្ចសន្យា ក្នុងលក្ខខណ្ឌដែល ការភាន់ច្រឡំអំពីចំណុចសំខាន់ៗ នៃកិច្ចសន្យា ហើយភាគីម្ខាងទៀតអាចដឹងថាមានការភាន់ច្រឡំ។ ចំណុចដែលសំខាន់នៅក្នុងកិច្ចសន្យាក្នុងកិច្ចសន្យា គឺត្រូវកំណត់ដោយសត្យានុម័ត ទៅតាមប្រភេទនៃកិច្ចសន្យា និង កាលៈទេសៈជាក់ស្តែងផ្សេងទៀត។ ឧទាហរណ៍៖ អ្នកលក់មិនអាចទាមទារលុបចោលកិច្ចសន្យាលក់ទិញបានឡើយ ទោះបីជាមានការភាន់ច្រឡំអំពីអ្នកទិញ ក៏ដោយ ពីព្រោះបញ្ហាក្នុងកិច្ចសន្យាលក់ទិញថា តើអ្នកណាជាអ្នកទិញ ជាទូទៅ មិនមែនជា ចំណុចសំខាន់នៃកិច្ចសន្យាទេ។

---

[11] សេចក្តីកំណត់ ចំពោះមាត្រានីមួយៗ នៃក្រមរដ្ឋប្បវេណី ឆ្នាំ ២០១០ មាត្រា ៣៥៧

[12] មាត្រា ៣៤៥ នៃក្រមរដ្ឋប្បវេណី ឆ្នាំ ២០០៧

ម្យ៉ាងវិញទៀត ការបញ្ជាក់អំពីវត្ថុដែលជាកម្មវត្ថុនៃការលក់ទិញ គឺជាចំណុចសំខាន់នៃកិច្ចសន្យាលក់ហេតុដូច្នេះ ភាគីដែលមានការភាន់ច្រឡំអំពីចំចណុចនេះ អាចលុបចោលកិច្ចសន្យាបាន។ លក្ខខណ្ឌផ្សេងទៀតសម្រាប់ការលុបចោលកិច្ចសន្យាដោយសារការភាន់ច្រឡំ គឺជាលទ្ធភាពក្នុងការដឹងអំពីការភាន់ច្រឡំនេះ។[13]

### ១.៤.១.១ ការភាន់ច្រឡំអំពីចំណុចនៃកិច្ចសន្យា ដែលភាគីយល់ឃើញថាសំខាន់

ក្នុងករណីដែលភាគីម្ខាងនៃកិច្ចសន្យា មានការភាន់ច្រឡំអំពីចំណុចនៃកិច្ចសន្យាដែលខ្លួនយល់ឃើញថាសំខាន់ ឬ ចំណុចដែលខ្លួនយល់ឃើញថាសំខាន់ក្នុងការបង្កើតកិច្ចសន្យា បើភាគីម្ខាងទៀតបានស្ថិតនៅក្នុងស្ថានភាពដែល អាចដឹងអំពីភាពសំខាន់នៃចំណុចនេះ និងការភាន់ច្រឡំរបស់អ្នកបង្ហាញឆន្ទៈ នោះភាគីដែលបានភាន់ច្រឡំ អាចលុបចោលកិច្ចសន្យាបាន ដោយហេតុថា ការបង្ហាញឆន្ទៈមានវិការៈ។[14] ចំណុចដែលភាគីយល់ឃើញថាសំខាន់នេះ អាចមិនមែនពាក់ព័ន្ធទៅនឹងកម្មវត្ថុចម្បងនៃកិច្ចសន្យា ហើយវាមិនមែនសំខាន់សំរាប់តែភាគីទាំងសងខាងនោះទេ គឺវាមានសារៈសំខាន់តែទៅលើភាគីតែម្ខាងប៉ុណ្ណោះ។ ឧទាហរណ៍៖ ក ជាអ្នកចូលចិត្តអានសៀវភៅប្រវត្តិសាស្ត្រ គាត់មិនដែលអានសៀវភៅណាផ្សេង ក្រៅពីសៀវភៅប្រវត្តិសាស្ត្រទេ ដូចនេះគាត់បានទិញមក តែតាមពិតវាមិនមែន ជាប្រវត្តិសាស្ត្រទេ។ ដូចនេះ ក មានការភាន់ច្រឡំ ទៅលើសៀវភៅស្មានថាជាសៀវភៅប្រវត្តិសាស្ត្រ ដែលគាត់យល់ឃើញថាសំខាន់សម្រាប់គាត់។

### ១.៤.១.២ ការភាន់ច្រឡំដោយភាគីទាំងសងខាង

ក្នុងករណីដែលភាគីទាំងសងខាង មានការភាន់ច្រឡំអំពីចំណុចសំខាន់ៗនៃកិច្ចសន្យាឬចំណុចនៃកិច្ចសន្យាដែលភាគីទាំងសងខាង យល់ឃើញថាសំខាន់ ឬ ចំណុចដែលភាគីទាំងសងខាងយល់ឃើញថា សំខាន់ក្នុងពេលបង្កើតកិច្ចសន្យា ទោះបីជាភាគីម្ខាងទៀតមិនមាន លទ្ធភាពអាចដឹងអំពីការភាន់ច្រឡំរបស់ភាគីម្ខាងទៀត ក៏ដោយក៏ភាគីដែលបានភាន់ច្រឡំ អាចលុបចោលនូវកិច្ចសន្យាបានដែរ ដោយហេតុថា ការបង្ហាញឆន្ទៈនោះមានវិការៈ។[15] នេះជាការភាន់ច្រឡំរួម ប្រសិនបើភាគីទាំងពីរមានការភាន់ច្រឡំ អំពីចំណុចសំខាន់នៃកិច្ចសន្យាកិច្ចសន្យា អាចលុបចោលបានទោះបីជាភាគីម្ខាងទៀតគ្មានលទ្ធភាពអាចដឹងអំពីការភាន់ច្រឡំរបស់ភាគីម្ខាងទៀតក៏ដោយ។

ដោយសារភាគីទាំងសងខាង មានការភាន់ច្រឡំ ដូចនេះហើយភាពចាំបាច់ក្នុងការការពារភាគីម្ខាងទៀតគឺមានកម្រិតទាបដែលខុសពីករណីដែលមានតែ ភាគីម្ខាងមានការភាន់ច្រឡំ។ ដូច្នេះ វាមិនមានភាពចំចាច់ក្នុងការពិចារណា ទៅលើលទ្ធភាពក្នុងការដឹងរបស់ភាគីម្ខាងទៀតទេ។

---

[13] សេចក្តីកំណត់ ចំពោះមាត្រានីមួយៗ នៃក្រមរដ្ឋប្បវេណី ឆ្នាំ ២០១០ មាត្រា ៣៤៦ កថាខណ្ឌទី១

[14] មាត្រា ៣៤៦ កថាខណ្ឌទី២ នៃក្រមរដ្ឋប្បវេណី ឆ្នាំ ២០០៧

[15] មាត្រា ៣៤៦ កថាខណ្ឌទី៣ នៃក្រមរដ្ឋប្បវេណី ឆ្នាំ ២០០៧

**១.៤.១.៣ ការការពារតតិយជន**

ការលុបចោលនូវកិច្ចសន្យា ដោយសារការភាន់ច្រឡំក្រៅពីភាគីម្ខាងទៀត អាចអះអាងចំពោះ តតិយជនបាន។ ប៉ុន្តែ ប្រសិនបើតតិយជនជាជនសុចរិតហើយគ្មានកំហុសអំពីការភាន់ច្រឡំ មិនអាចអះអាងចំពោះតតិយជននោះបានឡើយ។[16]

នេះគឺជាលក្ខខណ្ឌតតាំង ការលុបចោលនូវ កិច្ចសន្យាចំពោះតតិយជន ក្នុងករណីដែលមានតតិយជនដែលមានទំនាក់ទំនងផលប្រយោជន៍ជាមួយ នឹងកិច្ចសន្យាដែលត្រូវបានអនុញ្ញាតឱ្យលុបចោលដោយការភាន់ច្រឡំរវាងភាគីនៃកិច្ចសន្យា។

ការការពារតតិយជនគឺ មានសារៈសំខាន់ណាស់ គឺដើម្បីការពារដល់ ប្រយោជន៍របស់តតិយជន ដែលកើតចេញអំពីការបង្កើត កិច្ចសន្យាដោយមានវិការៈនេះ។

**១.៤.២ ការឆបោក**

បុគ្គលដែលបានបង្ហាញឆន្ទៈ ដោយសារមានការឆបោករបស់ភាគីម្ខាងទៀតអាចលុបចោលនូវកិច្ចសន្យាដោយហេតុថា ការបង្ហញឆន្ទៈនោះមានវិការៈ។[17]

ការឆបោក មានន័យថា បុគ្គលណាម្នាក់ ឬ តតិយជន បានធ្វើការបង្ហាញឆន្ទៈ មានការភាន់ច្រឡំដោយសារ មធ្យោបាយឆបោក ហើយអ្នកបង្ហាញឆន្ទៈបានបង្ហាញឆន្ទៈរបស់ខ្លួន ដោយខុសពីឆន្ទៈពិតប្រាកដរបស់ខ្លួន និងគេមិនបានដឹងពីភាពខុសគ្នានេះនៅពេលដែលគេធ្វើការបង្ហាញឆន្ទៈ។

សិទ្ធិលុបចោលកិច្ចសន្យា ដែលត្រូវផ្តល់ឱ្យអ្នកបង្ហាញឆន្ទៈ ប្រសិនបើការបង្ហញឆន្ទៈត្រូវបានធ្វើឡើងដោយមានការឆបោក ដែលប្រព្រឹត្តដោយភាគីម្ខាងទៀត ឬ តតិយជន។ ប្រសិនបើការបង្ហាញឆន្ទៈខុសពីឆន្ទៈពិតរបស់ អ្នកបង្ហាញឆន្ទៈដោយសាការឆបោកហើយកិច្ចសន្យានោះ ត្រូវបានបង្កើតរួចហើយទៀត ទោះបីជាអ្នកបង្ហាញឆន្ទៈ ត្រូវបានបន្ទោសថាឱ្យគេបោកក៏ដោយ ក៏ចាំបាច់ត្រូវតែការពារអ្នកបង្ហាញឆន្ទៈដែរ។ ជាពិសេសប្រសិនបើការបង្ហាញឆន្ទៈ ផ្អែកលើការឆបោករបស់ភាគីម្ខាងទៀត មានភាពចាំបាច់យ៉ាងខ្លាំងដែលត្រូវការពារអ្នកបង្ហាញឆន្ទៈ។[18]

**១.៤.២.១ ការឆបោករបស់តតិយជន**

ក្នុងករណីដែលការបង្ហាញឆន្ទៈ បានធ្វើឡើងដោយសារការឆបោករបស់តតិយជនអ្នកបង្ហាញឆន្ទៈអាចលុបចោលនូវកិច្ចសន្យាដោយហេតុថា ការបង្ហាញឆន្ទៈនោះមានវិការៈ លុះត្រាតែក្នុងករណីដែលភាគីម្ខាងទៀត

[16] មាត្រា ៣៤៦ កថាខណ្ឌទី៤ នៃក្រមរដ្ឋប្បវេណី ឆ្នាំ ២០០៧

[17] មាត្រា ៣៤៧ កថាខណ្ឌទី១ នៃក្រមរដ្ឋប្បវេណី ឆ្នាំ ២០០៧

[18] សេចក្តីកំណត់ ចំពោះមាត្រានីមួយៗ ក្រមរដ្ឋប្បវេណី ឆ្នាំ ២០១០ មាត្រា ៣៤៧

នៃការបង្ហាញឆន្ទៈនោះ បានដឹង ឬ អាចដឹងអំពីការឆបោកនោះ។[19]

ការឆបោកដោយតតិយជន គឺសំដៅទៅលើជនដែលក្រៅពី ភាគីក្នុងកិច្ចសន្យាបានប្រើមធ្យោយឆបោក ដើម្បីឱ្យអ្នកដែលបង្ហាញឆន្ទៈ មានការភាន់ច្រឡំដោយសារមធ្យោបាយឆបោកនោះហើយអ្នកបង្ហញឆន្ទៈបាន បង្ហាញឆន្ទៈរបស់ខ្លួនដោយខុសពីឆន្ទៈ ពិតប្រាកដរបស់ខ្លួន។ ឧទាហរណ៍៖ ក បានប្រាប់ទៅ ខ ថាដីរបស់ គ នឹង មានការអភិវឌ្ឍន៍ដោយក្រុមហ៊ុនបរទេសមួយនាពេលឆាប់ៗនេះ។ គ្រាន់តែឮដូចនេះ ខ បានទិញដីរបស់ គ ភ្លាម។ នៅក្នុងករណីនេះ ខ អាចលុបចោលកិច្ចសន្យាបានប្រសិនបើ ខ បានដឹង ឬ អាចដឹងពីការឆបោករបស់ ក ។

### ១.៤.២.២ ការការពារតតិយជន

ការលុបចោលនូវកិច្ចសន្យា ដោយការឆបោក ក្រៅពីភាគីម្ខាងទៀត អាចអះអាងចំពោះ តតិយជនបាន។ ប៉ុន្តែ ប្រសិនបើតតិយជនជាជនសុចរិត ហើយគ្មានកំហុសអំពីការឆបោក មិនអាចអះអាងនូវអានុភាពនៃការលុប ចោលចំពោះតតិយជននោះបានឡើយ។[20] ឧទាហរណ៍៖ ក បានឆបោក ខ ឱ្យលក់ឡានរបស់ខ្លួនក្នុងតម្លៃទាប ហើយ ក បានលក់ឡាននេះបន្តឱ្យទៅ គ ។ បន្ទាប់មក ខ ក៏បានដឹងថា ក ឆបោកខ្លួនក៏បានសុំលុបចោលកិច្ច សន្យានេះ។ ករណីនេះ ខ អាចអះអាងពីអានុភាពនៃការលុបចោលចំពោះ ក បានដោយយោងទៅលើការឆបោក របស់ ក ទើបធ្វើឱ្យ ខ បង្ហាញ ឆន្ទៈក្នុងការលក់ឡាននេះដែលជាការបង្ហាញឆន្ទៈមានវិការៈ។ ក៏ប៉ុន្តែ ប្រសិនបើ គ ជាជនសុចរិត និងគ្មានកំហុស ខ មិនអាចទាមទារឡានពី គ ដែលជាជនសុចរិត និងគ្មានកំហុសបានទេ។

### ១.៤.៣ ព័ត៌មានមិនពិត

នៅពេលធ្វើកិច្ចសន្យា បើហេតុដែលបានបង្ហាញដោយភាគីម្ខាងនោះខុសពីការពិត ហើយភាគីម្ខាងទៀត បានបង្ហាញឆន្ទៈដោយជឿជាក់ថា ហេតុទាំងនោះខុសពីការពិត ប៉ុន្តែ ប្រសិនបើភាគីនោះដឹងថា ហេតុនោះមិន មែនជាការពិតខ្លួននឹងមិនបង្ហាញឆន្ទៈទេ ភាគីនោះអាចលុបចោលនូវកិច្ចសន្យាបាន ដោយហេតុថា ការបង្ហាញ ឆន្ទៈនោះមានវិការៈ។[21]

ក្នុងករណីនេះ មិនរារាំងភាគីដែលបានបង្ហាញឆន្ទៈក្នុងការទាមទារសំណង នៃការខូចខាត ពីបុគ្គលដែល បានបង្ហាញការមិនពិតនោះទេ ក្នុងករណីបុគ្គលនោះមានកំហុស។ មានន័យថា ភាគីដែលបង្ហាញព័ត៌មានមិន ពិត មានកំហុសក្នុងការបង្ហាញព័ត៌មានមិនពិតនេះភាគីនោះត្រូវទទួលខុសត្រូវក្នុងការសងសំណងការខូចខាត។ ក្នុងករណីនេះ គួរតែមកស្រាយថា ភាគីដែលទទួលរងនូវការខូចខាត អាចលុបចោលកិច្ចសន្យា និង ទាមទារ សំណងនៃការខូចខាតដែលនៅសល់ ក្រោយការលុបចោលបាន ឬ ក៏អាចទាមទារសំណងនៃការខូចខាតដោយ

[19] មាត្រា ៣៤៧ កថាខណ្ឌទី២ នៃក្រមរដ្ឋប្បវេណី ឆ្នាំ ២០០៧

[20] មាត្រា ៣៤៧ កថាខណ្ឌទី៣ នៃក្រមរដ្ឋប្បវេណី ឆ្នាំ ២០០៧

[21] មាត្រា ៣៤៨ កថាខណ្ឌទី១ នៃក្រមរដ្ឋប្បវេណី ឆ្នាំ ២០០៧

មិនលុបចោលកិច្ចសន្យាបានដែរ។ ក្នុងករណីនេះ ការកំណត់លំអិតអំពីការខូចខាតមានការលំបាក។ ការលំបាកនេះទុកឱ្យ ដោះស្រាយតាមយុត្តិសាស្ត្រ និង ទ្រឹស្តី នៅពេលអនាគត។[22]

ការលុបចោលកិច្ចសន្យាដោយព័ត៌មានមិនពិត ក្រៅពីភាគីម្ខាងទៀត អាចអះអាងចំពោះតតិយជនបាន។ ប៉ុន្តែ ប្រសិនបើតតិយជន ជាជនសុចរិតហើយគ្មានកំហុស អំពីព័ត៌មានមិនពិតមិនអាចអះអាងនូវអានុភាពនៃការលុបចោល ចំពោះតតិយជននោះបានឡើយ។[23]

### ១.៤.៤ ការរំលោភបំពានលើស្ថានភាព

នៅពេលធ្វើកិច្ចសន្យា បើភាគីម្ខាងនៃកិច្ចសន្យាបានប្រើ ដោយមិនត្រឹមត្រូវនូវឋានៈ ដែលមានអាទិភាពជាងភាគីម្ខាងទៀត ខាងផ្នែកសេដ្ឋកិច្ច ឬ ផ្នែកសង្គម ឬបានប្រើដោយមិនត្រឹមត្រូវ នូវស្ថានភាពផ្សេងទៀតដែលភាគីម្ខាងទៀត មិនអាចប្រឆាំងតបបានទេ ភាគីម្ខាងទៀតនោះអាចលុបចោលនូវកិច្ចសន្យាបានដោយហេតុ ថា ការបង្ហាញឆន្ទៈមានវិការៈ។[24] ទោះបីជាករណីនេះមិនមែនជាការគំរាមកំហែងក៏ដោយក៏អ្នកបង្ហាញឆន្ទៈ ត្រូវបានបង្ខំឱ្យបង្ហាញឆន្ទៈដែលខ្លួនមិនមានបំណងធ្វើដែរ ហេតុដូច្នេះ ការបង្ហាញឆន្ទៈនោះមានវិការៈ ហើយមាត្រានេះអនុញ្ញាតឱ្យលុបចោលកិច្ចសន្យា ដែលមានការបង្ហាញឆន្ទៈបែបនេះជាធាតុផ្សំ។ ប៉ុន្តែ មានករណីជាច្រើនដែលកិច្ចសន្យាត្រូវបានបង្កើតឡើង តាមរយៈការប្រើឋានៈដែលមាន អាទិភាពជាងភាគីម្ខាងទៀតខាងផ្នែកសេដ្ឋកិច្ច ហើយមិនមែនគ្រប់ករណីទាំងអស់ដែលគេអាចលុបចោលនូវកិច្ចសន្យាបាននោះទេ ហេតុដូច្នេះ អ្នកបង្ហាញឆន្ទៈអាចលុបចោលកិច្ចសន្យាបាន លុះត្រាតែក្នុងករណីដែលមាន ការប្រើប្រាស់ដោយមិនត្រឹមត្រូវ នូវស្ថានភាពនេះប៉ុណ្ណោះ។

ការលុបចោលនូវ កិច្ចសន្យាដោយយោងតាម ការរំលោភបំពានលើស្ថានភាពនេះ មិនអាចអះអរអាងចំពោះតតិយជនដែលជាជនសុចរិត ហើយគ្មានកំហុសអំពីការរំលោភបំពាន លើស្ថានភាពបានឡើយ ។[25] ដើម្បីសម្របសម្រួលផលប្រយោជន៍របស់តតិយជន ដែលជាជនសុច្ចរិតហើយគ្មានកំហុសការលុបចោលកិច្ចសន្យាដោយហេតុនៃការរំលោភបំពានលើស្ថានភាព មិនអាចអះអាងចំពោះតតិយជនដែលគ្មានកំហុសបានឡើយ។ ប្រសិនបើ ប្រៀបធៀបចំពោះការគំរាមកំហែងក្នុង មាត្រា ៣៥០ នៃក្រមរដ្ឋប្បវេណី ឆ្នាំ ២០០៧ ការការពារចំពោះជនដែលបង្ហាញឆន្ទៈដោយសារការរំលោភបំពានលើស្ថានភាពនេះ ខ្សោយជាង។

---

[22] មាត្រា ៣៤៨ កថាខណ្ឌទី១ នៃក្រមរដ្ឋប្បវេណី ឆ្នាំ ២០០៧

[23] សេចក្តីកំណត់ចំពោះ មាត្រានីមួយ នៃក្រមរដ្ឋប្បវេណី ឆ្នាំ ២០១០ មាត្រា ៣៤៨ កថាខណ្ឌទី២

[24] មាត្រា ៣៤៨ កថាខណ្ឌទី៣ នៃក្រមរដ្ឋប្បវេណី ឆ្នាំ ២០០៧

[25] មាត្រា ៣៤៩ កថាខណ្ឌទី២ នៃក្រមរដ្ឋប្បវេណី ឆ្នាំ ២០០៧

### ១.៤.៥ ការគំរាមកំហែង

ការគំរាមកំហែង សំដៅទៅលើករណីដែល អ្នកបង្ហាញឆន្ទៈ បានបង្ហាញឆន្ទៈរបស់ខ្លួន ដែលផ្ទុយនឹងគោលបំណងរបស់ខ្លួន ដោយសារមានការភ័យខ្លាចភាគីម្ខាងទៀត ឬ តតិយជន។ បុគ្គលដែលបានបង្ហាញឆន្ទៈដោយសារមានការគំរាមកំហែងពីសំណាក់ភាគីម្ខាងទៀត ឬពីសំណាក់តតិយជនអាចលុបចោលនូវកិច្ចសន្យាបានដោយហេតុថា ការបង្ហាញឆន្ទៈនោះមានវិការៈ។[26]

**លក្ខណៈខុសគ្នារវាង ការភាន់ច្រឡំ ការឆបោក និងការគំរាមកំហែង៖**

- **ការភាន់ច្រឡំ៖** អ្នកបង្ហាញឆន្ទៈ បានបង្ហាញឆន្ទៈរបស់ខ្លួន ដោយមានការភាន់ច្រឡំ។
- **ការឆបោក៖** អ្នកបង្ហាញឆន្ទៈ បានបង្ហាញឆន្ទៈ ដោយមានការភាន់ច្រឡំ ដែលបង្កឡើងដោយភាគីម្ខាងទៀត ឬ តតិយជន។[27]
- **ការគំរាមកំហែង៖** អ្នកបង្ហាញឆន្ទៈ បានបង្ហាញឆន្ទៈ ដោយគ្មានការភាន់ច្រឡំទេ ប៉ុន្តែ វាផ្ទុយនឹងគោលបំណងរបស់ខ្លួន ដោយសាររមានការភ័យខ្លាច ដែលបង្កឡើងដោយភាគីម្ខាងទៀត ឬ តតិយជន។ ឧទាហរណ៍៖ ក ចង់ទិញផ្ទះរបស់ ខ ទោះបីជា ក ឱ្យតម្លៃថ្លៃយ៉ាងណាក៏ដោយក៏ ខ នៅមិនព្រមលក់ផ្ទះរបស់ខ្លួនដែរ ដោយហេតុតែចង់បានផ្ទះ ក បានគំរាម ខ ថាស្រលាញ់ផ្ទះជាង ឬក៏ស្រលាញ់ជីវិតជាង បន្ទាប់មក ខ ក៏មានការភ័យខ្លាចយ៉ាងខ្លាំងក៏សម្រេចចិត្តលក់ផ្ទះឱ្យទៅ ក។

ចំពោះការពាតតិយជនទាក់ទងទៅ និងការគំរាមកំហែងនេះមិន មានបញ្ញត្តិច្បាប់ សម្រាប់ការពារ តតិយជននោះទេ ទោះបីតតិយជនបានបង្កើតទំនាក់ទំនងក្នុងកិច្ចសន្យា ដោយផ្អែកលើកិច្ចសន្យាដែលអាចត្រូវបានគេលុបចោលនោះ។ ក្នុងករណីនេះ អ្នកបង្ហាញឆន្ទៈ អាចអះអាងពីអានុភាពនៃការលុបចោល ចំពោះតតិយជនបានទោះបីជាតតិយជននោះ គឺជាជនសុចរិតក៏ដោយ។ មូលហេតុដែលមិនមានបញ្ញត្តិ សំរាប់ការពារតតិយជនទាក់ទងនិងការគំរាមកំហែង គឺថាអ្នកបង្ហាញឆន្ទៈបានបង្ហាញឆន្ទៈរបស់ខ្លួន ដោយគ្មានការភាន់ច្រឡំ នៅក្នុងករណីនៃការឆបោក ឬការភាន់ច្រឡំ។[28]

### ១.៤.៦ អំពើកេងយកចំណេញហួសហេតុ

ក្នុងករណី ដែលភាគីម្ខាង បានធ្វើកិច្ចសន្យាដោយឆ្លៀតឱកាស ដែលភាគីម្ខាងទៀត កំពុងជួបប្រទះការលំបាកខាងផ្នែកសេដ្ឋកិច្ច ឬភាពល្ងង់ ឬការខ្វះបទពិសោធន៏ ហើយបានកេងចំណេញយ៉ាងសន្ធឹកសន្ធាប់ពីកិច្ច

[26] មាត្រា ៣៤៩ កថាខណ្ឌទី១ នៃក្រមរដ្ឋប្បវេណី ឆ្នាំ ២០០៧

[27] សេចក្តីពន្យល់ អំពី ក្រមរដ្ឋប្បវេណី ភាគទី១ ឆ្នាំ ២០១៣ ទំព័រ ១៣២

[28] សេចក្តីពន្យល់ អំពី ក្រមរដ្ឋប្បវេណី ភាគទី១ ឆ្នាំ ២០១៣ ទំព័រ ១៣២

សន្យានោះភាគីម្ខាងទៀតនោះ អាចលុបចោលនូវកិច្ចសន្យាបាន ដោយហេតុថា ការបង្ហាញឆន្ទៈនោះមានវិការៈ។[29]

គោលបំណងក្នុងចំណុចនេះ ចង់ការពារភាគីម្ខាងនៃកិច្ចសន្យា ដូចជាអ្នកប្រើប្រាស់ ពីអ្នកផលិតនូវផលិតផលយ៉ាងច្រើនសន្ធឹកសន្ធាប់ ដែលប៉ុនប៉ងកេងយកចំណេញយ៉ាងសន្ធឹកសន្ធាប់ ដោយឆ្លៀតឱកាស នូវភាពល្ងង់ខ្លៅ ឬ ខ្វះបទពិសោធន៍របស់អ្នកប្រើប្រាស់។ ឧទាហរណ៍៖ ក បានទិញម៉ូតូថ្មីមួយគ្រឿងក្នុងតម្លៃ ២០០០$ (ពីរពាន់ដុល្លារអាមេរិច) តែបន្ទាប់មកប្រពន្ធរបស់ ក មានជំងឺជាទម្ងន់ដែលត្រូវការលុយដើម្បីព្យាបាល។ ដោយឃើញដូច្នេះ ខ ចង់ទិញម៉ូតូរបស់ ក តែក្នុងតម្លៃទាបត្រឹមតែ ១០០០$ (មួយពាន់ដុល្លារអាមេរិច)។ដោយសារអត់មានលុយគ្រប់គ្រាន់ដើម្បីមើលជំងឺ ហើយត្រូវការលុយជាការប្រញាប់ទៀតនោះ ក ក៏បានយល់ព្រមលក់ម៉ូតូឱ្យទៅ ខ ក្នុងតម្លៃ ១០០០$ (មួយពាន់ដុល្លារអាមេរិច) ទៅ។

ចំពោះការការពារតតិយជនដែលទាក់ទងនិង ការរំលោភបំពានលើស្ថានភាពនេះ គឺមិនមានបញ្ញត្តិច្បាប់សម្រាប់ការពារតតិយជននោះទេ ព្រោះនៅក្នុងបញ្ញត្តិនេះសន្មតថា អ្នកបង្ហាញឆន្ទៈគឺសាធារណៈជនដែលប្រើប្រាស់ផលិតផល និងភាគីម្ខាងទៀតជាផលិតករដែលផលិត ផលិតផលក្នុងទ្រង់ទ្រាយធំ។ ដូចនេះវាមិនមានបញ្ញត្តិដើម្បីការពារតតិយជនជាងការពារសាធារណៈជនដែលប្រើប្រាស់ផលិតផលនោះ។

### ១.៤.៧ អលទ្ធភាពតាំងពីដំបូង

ប្រសិនបើអត្ថន័យនៃកិច្ចសន្យា មិនអាចសម្រេចបានតាំងពីពេលដែល បង្កើតកិច្ចសន្យាក៏ដោយ ក៏កិច្ចសន្យានោះ មិនត្រូវបានចាត់ទុកជាមោឃៈ ដោយយកមូលហេតុនៃអលទ្ធភាពនោះដែរ។ ប៉ុន្តែបញ្ញត្តិនេះមិនរារាំងភាគី ក្នុងការលុបចោលនូវកិច្ចសន្យាដោយយកមូលហេតុនៃការភាន់ច្រឡំឡើយក្នុងករណីដែលលក្ខខណ្ឌនៃការភាន់ច្រឡំត្រូវបានបំពេញ។[30] មានន័យថា កិច្ចសន្យាមិនត្រូវបានចាត់ទុកជាមោឃៈទេដោយហេតុមួយដែលគេហៅ ថាអលទ្ធភាពតាំងពីដំបូង។ អលទ្ធភាពតាំងពីដំបូងមានន័យថា នៅពេលកិច្ចសន្យាត្រូវបានបង្កើត មានភាពច្បាស់លាស់ជាស្ថាពរថា ការអនុវត្តកិច្ចសន្យានេះមិនអាចធ្វើបានទេ។ ប្រសិនបើអលទ្ធភាពតាំងពីដំបូងមិនត្រូវចាត់ទុកជាមូលហេតុ នៃការអនុវត្តកិច្ចសន្យានេះមិនអាចធ្វើបានទេ។ ប្រសិនបើអលទ្ធភាពតាំងពីដំបូងមិនត្រូវចាត់ទុកជាមូលហេតុនៃមោឃភាពទេ កិច្ចសន្យាត្រូវបង្កើតឡើងដោយមានសុពលភាព ទោះបីជាមានអលទ្ធភាពតាំងពីដំបូងក៏ដោយ។

ក្នុងករណី ដែលភាគីគួរតែអាចដឹងថា អត្ថន័យនៃកិច្ចសន្យា មិនអាចសម្រេចតាំងពីដំបូងបាននាំ ឱ្យមានការខូចខាតដល់ភាគីម្ខាងទៀតដោយសារការបង្កើតកិច្ចសន្យាភាគី នោះត្រូវទទួលខុសត្រូវក្នុការសងការខូចខាតដល់

[29] មាត្រា ៣៥១ នៃក្រមរដ្ឋប្បវេណី ឆ្នាំ ២០០៧

[30] មាត្រា ៣៥៥ កថាខណ្ឌទី១ នៃក្រមរដ្ឋប្បវេណី ឆ្នាំ ២០០៧

ភាគីម្ខាងទៀត ដោយផ្អែកលើបញ្ញត្តិនៃ លក្ខខណ្ឌនៃ ការទទួលខុសត្រូវក្នុងការសងការសំណងនៃការខូចខាត។[31]

ក្នុងករណីនេះ អលទ្ធភាពតាងពីដំបូង ត្រូវបានដោះស្រាយជាបញ្ហាអលទ្ធភាពទូទៅនៃការអនុវត្ត។ ហេតុដូច្នេះហើយ បញ្ហានេះត្រូវបានដោះស្រាយ តាមការរំលាយកិច្ចសន្យាដោយយកអលទ្ធភាពក្នុងការអនុវត្តមកធ្វើជាមូលហេតុ ឬ តាមសំណងការខូចខាត។ ប្រសិនបើភាគីដែលធ្វើកិច្ចសន្យាដោយជឿជាក់ថា ខ្លឹមសារនៃកិច្ចសន្យាអាចអនុវត្តបាន បំពេញលក្ខខណ្ឌនៃការភាន់ច្រឡំ នោះភាគីអាចលុបចោលកិច្ចសន្យាដោយហេតុថា មានការភាន់ច្រឡំ។

### ១.៤.៨ អានុភាពនៃសកម្មភាពដែលអាចលុបចោលបាន

សកម្មភាពដែលអាចលុបចោលបាន មានសុពលភាព រហូតដល់ពេលដែល អ្នកមានសិទ្ធិលុបចោលលុបចោសកម្មភាពនោះ។[32] អត្ថន័យទូទៅ នៃការលុបចោលដែលសកម្មភាពដែលអាចលុចោល នៅតែមានអានុភាពរហូតដល់អ្នកដែលមានសិទ្ធិលុបចោល បានលុបចោលសកម្មភាពនោះ។ ចំពោះករណីនេះ វាខុសគ្នាដ៏សំខាន់រវាងការលុបចោល និង មោឃភាព គឺអត្ថិភាព ឬនត្ថិភាពនៃការកម្រិតពេលវេលាអំពីការអះអាង។ ចំពោះមោឃភាព គ្មានការកំណត់ពេលវេលាទេ ប៉ុន្តែ ការលុបចោលមិនអាចអះអាងបានទេ ប្រសិនបើអំឡុងពេលនៃអាជ្ញាយុកាលនៃការរំលត់សិទ្ធិលុបចោល កន្លងផុត។

#### ១.៤.៨ ១ អ្នកដែលមានសិទ្ធិលុបចោល

ជនដែលមានសិទ្ធិ លុបចោលក្នុងករណី កិច្ចសន្យាអាចលុបចោលដោយ មូលហេតុដែលមានវិការៈក្នុងការបង្ហាញឆន្ទៈក្រៅពីអ្នកបង្ហាញឆន្ទៈ អ្នកបង្ហាញឆន្ទៈដែលច្បាប់បានកំណត់របស់អ្នកបង្ហាញឆន្ទៈ ប្រសិនបើមាន ក៏អាចលុបចោលបានដែរ។ ឧទាហរណ៍៖ មានដូចជាករណីបន្ទាប់ពីបង្ហាញឆន្ទៈដោយការភាន់ច្រឡំ អ្នកបង្ហាញនោះត្រូវបានកម្រិតសមត្ថភាពភាពក្នុងការធ្វើសកម្មភា និងអ្នកអាណាព្យាបាលទូទៅត្រូវបានជ្រើសតាំងសម្រាប់អ្នកបង្ហាញឆន្ទៈនោះ។ ម្យ៉ាងទៀត ជនដែលទទួលបន្តនូវឋានៈរបស់អ្នកដែលបានធ្វើការបង្ហាញឆន្ទៈដែលមានវិការៈ ក៏អាចអនុវត្តសិទ្ធិលុបចោលបានដែរ។[33]

#### ១.៤.៨.២ ក្នុងករណីវិការៈក្នុងការបង្ហាញឆន្ទៈ

ចំពោះសកម្មភាពដែលអាច លុបចោលបានដោយមូលហេតុថា មានវិការៈក្នុងការបង្ហាញឆន្ទៈដែលបានកំណត់ ចាប់ពីមាត្រា ៣៤៦ (ការភាន់ច្រឡំ) ដល់មាត្រា ៣៥១ (អំពើកេងយកចំណេញហួសហេតុ) នៃក្រមនៃក្រមរដ្ឋប្បវេណី ឆ្នាំ ២០០៧ អ្នកដែលបង្ហាះឆន្ទៈដោយមានវិការៈ ឬ អ្នកតំណាងដែលច្បាប់បានកំណត់របស់អ្នក

[31] មាត្រា ៣៥៥ កថាខណ្ឌទី២ នៃក្រមរដ្ឋប្បវេណី ឆ្នាំ ២០០៧

[32] មាត្រា ៣៥៨ កថាខណ្ឌទី១ នៃក្រមរដ្ឋប្បវេណី ឆ្នាំ ២០០៧

[33] សេចក្តីកំណត់ ចំពោះមាត្រានីមួយៗ នៃក្រមរដ្ឋប្បវេណី ឆ្នាំ ២០១០ មាត្រា ៣៥៩

នោះអាចលុបចោលនូវសកម្មភាពនោះបាន។ សន្តតិជនរបស់អ្នកដែលបានបង្ហាញឆន្ទៈ ឬ អ្នកដែលទទួលបន្តនូវឋានៈ ក្នុងកិច្ចសន្យាពីអ្នកដែលបង្ហាញឆន្ទៈ ក៏អាចអនុវត្តសិទ្ធិលុបចោលបានដែរ។[34]

**១.៥.៩.២ ករណីសមត្ថភាពក្នុងការបង្ហាញឆន្ទៈ**

ចំពោះការលុបចោល ដោយមូលហេតុគ្មានសមត្ថភាពក្នុងការបង្ហាញឆន្ទៈ អនីតិភាព ឬការកម្រិតសមត្ថភាពក្នុងការធ្វើសកម្មភាពផ្សេងទៀត សាមីខ្លួន អ្នកតំណាងដែលច្បាប់បានកំណត់ ឬហិតូបត្ថម្ភកៈនៃជននោះ អាចលុបចោលនូវសកម្មភាពបាន។ សន្តតិជន ឬ អច្ច័យលាភីសកលរបស់សាមីខ្លួន ក៏អាចអនុវត្តសិទ្ធិលុបចោលបានដែរ។

**១.៤.៩ វិធីលុបចោល ឬ សច្ចានុមតិ**

ក្នុងករណីដែលភាគីម្ខាងទៀត នៃសកម្មភាពដែលអាចលុបចោលបាន ត្រូវបានកំណត់ច្បាស់លាស់ការលុបចោល ឬសច្ចានុមតិត្រូវធ្វើឡើង ដោយការជូនដំណឹងទៅភាគី ម្ខាងទៀតនោះអានុភាពនៃការលុបចោល ឬ សច្ចានុមតិ ត្រូវកើតឡើងនៅពេលដែលដំណឹងនោះ បានទៅដល់ភាគីម្ខាងទៀតនោះ។ អានុភាពនៃការលុបចោល ឬសច្ចានុមតិ និង ត្រូវកើតឡើងនៅពេលដែលដំណឹងនោះបានទៅដល់ភាគីម្ខាងទៀតនោះ។[35]

**១.៤.៩.១ អ្នកដែលមានសិទ្ធិផ្តល់សច្ចានុមតិ និង លក្ខខណ្ឌនៃការផ្តល់សច្ចានុមតិ**

អ្នកមានសិទ្ធិលុបចោល អាចផ្តល់សច្ចានុមតិ អាចផ្តល់សច្ចានុមតិចំពោះសកម្មភាពដែលអាចលុបចោលបាន។ ប៉ុន្តែ ក្នុងករណីដែលលុបចោលសកម្មភាព ដោយយកការបង្ហាញឆន្ទៈដោយមានវិការៈជាមូលហេតុ អ្នកមានសិទ្ធិលុបចោលអាចផ្តល់សច្ចានុមតិបាន ចាប់តាំងពីពេលដែលអ្នកមានសិទ្ធិលុបចោល នោះបានដឹងមូលហេតុនៃការលុបចោល។ រីឯសកម្មភាពរបស់ជនដែលត្រូវបានកម្រិតសមត្ថភាពវិញអ្នកមានសិទ្ធិលុបចោលអាចផ្តល់សច្ចានុមតិបាន នៅក្រោយពេលដែលស្ថានភាពដែលដែលជាមូលហេតុនៃការលុបចោលត្រូវបានរលត់។[36]

សច្ចានុមតិ គឺជាសកម្មភាពដែលបុគ្គល ដែលមានសិទ្ធិលុបចោលបានបង្ហាញជាស្ថាពរថាខ្លួនមិនអនុវត្តសិទ្ធិលុបចោលដោយ ផ្អែកលើបុរេលក្ខខណ្ឌដែលបាន ដឹងថាសកម្មភាពរបស់ខ្លួនអាចលុបចោលបាន។ ហេតុនេះហើយ ការទទួលស្គាល់ដោយផ្អែកលើសកម្មភាពដោយជនដែលមិនបានដឹងថា មានមូលហេតុនៃការលុបចោល មិនមែនជាជាសច្ចានុមតិឡើយ។

បន្ថែមពីលើនេះក្នុងករណី ដែលការលុបចោលអាចធ្វើបានដោយមូលហេតុ នៃការកម្រិតសមត្ថភាពក្នុងការធ្វើសកម្មភាព ជនដែលត្រូវបានកម្រិតសកម្មភាព អាចលុបចោលកម្មភាពបាន មុនពេលជននោះមានសមត្ថ

[34] មាត្រា ៣៥៩ កថាខណ្ឌទី១ នៃក្រមរដ្ឋប្បវេណី ឆ្នាំ ២០០៧

[35] មាត្រា ៣៦០ នៃក្រមរដ្ឋប្បវេណី ឆ្នាំ ២០០៧

[36] មាត្រា ៣៦១ កថាខណ្ឌទី១ នៃក្រមរដ្ឋប្បវេណី ឆ្នាំ ២០០៧

ភាពក្នុងការធ្វើឡើងវិញ ឬ មុនពេលជននោះដល់នីតិភាព ប៉ុន្តែ ជននោះមិនអាចផ្តល់សច្ចានុមតិ មុនពេលជននោះមានសមត្ថភាពក្នុងការធ្វើសកម្មភាពឡើងវិញ ឬ ជននោះដល់នីតិភាពបានឡើយ ពីព្រោះសច្ចានុមតិគឺជាសកម្មភាពដែល ធ្វើឱ្យសកម្មភាពនោះ មានអានុភាពជាស្ថាពរ។[37] ប៉ុន្តែ បញ្ញត្តិនៃវាក្យខណ្ឌទី៣ កថាខណ្ឌទី១ មាត្រា ៣៦១(អ្នកដែលផ្តល់សច្ចានុមតិ និង លក្ខខណ្ឌនៃការផ្តល់សច្ចានុមតិ)នៃក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧ មិនត្រូវយកមកអនុវត្តឡើយ ចំពោះករណីដែលអ្នកតំណាងដែលច្បាប់បានកំណត់ ឬ ហិតូបត្ថម្ភកៈ របស់ជនដែលត្រូវបានកម្រិត សកម្មភាពផ្តល់សច្ចានុមតិ។

### ១.៤.៩.២ សច្ចានុមតិដែលច្បាប់បានកំណត់

នៅក្រោយពេលដែលអាច ផ្តល់សច្ចានុមតិតាមបញ្ញត្តិ នៃមាត្រា ៣៦១ នៃក្រមរដ្ឋប្បវេណី ឆ្នាំ ២០០៧ (អ្នកមានសិទ្ធិផ្តល់សច្ចានុមតិ និង លក្ខខណ្ឌនៃការផ្តល់សច្ចានុមតិ) ខាងលើ សកម្មភាពដែលអាចលុបចោលបាន ត្រូវចាត់ទុកថា បានផ្តល់សច្ចានុមតិរួចហើយ ក្នុងករណីដូចខាងក្រោមនេះ៖

ក-ការអនុវត្តកាតព្វកិច្ចទាំងមូលឬមួយផ្នែកចំពោះកាតព្វកិច្ចដែលកើតឡើងដោយសកម្មភាពដែលអាចលុបចោលបាន ឬ ការដាក់ប្រាតិភោគដើម្បីធានាកាតព្វកិច្ចនោះ។

ខ-ការអនុវត្តសិទ្ធិដែលបានទទួលពីសកម្មភាពដែលអាចលុបចោលបាន ឬ ការទាមទារឱ្យភាគីម្ខាងទៀតអនុវត្ត។

គ-អនុប្បទាន ឬ ការចាត់ចែងផ្សេងទៀតនូវសិទ្ធិទាំងមូល ឬ មួយផ្នែក ចំពោះសិទ្ធិដែលបានទទួលពីសកម្មភាពដែលអាចលុបចោលបាន។

ប៉ុន្តែ បញ្ញត្តិនេះមិនត្រូវយកមកអនុវត្តឡើយ បើមានឋបនីយផ្លូវចិត្តថា ខ្លួនមិនបានផ្តល់សច្ចានុមតិ នៅពេលដែលហេតុដែលបានកំណត់នៅក្នុងករណីទាំងបីខាងលើនោះ កើតឡើង។[38]

សកម្មភាពដែលបានរៀបរាប់នៅក្នុងមាត្រានេះគឺជាសកម្មភាពដែលត្រូវបានធ្វើឡើង ដោយផ្អែកលើអានុភាពនៃសកម្មភាពដែលអាចលុបចោលបាន ហេតុដូច្នេះ មាត្រានេះបញ្ជាក់ថាសកម្មភាពទាំងនេះមានអានុភាពដូចគ្នានឹងការផ្តល់សច្ចានុមតិដែរ។

### ១.៤.៩.៣ អាជ្ញាយុកាលនៃការរំលត់សិទ្ធិលុបចោល

យោងតាម បញ្ញត្តិនៃមាត្រា ៣៦៣ នៃក្រមរដ្ឋប្បវេណី ឆ្នាំ ២០០៧ ប្រសិនបើអ្នកមានសិទ្ធិលុបចោលមិនអនុវត្តសិទ្ធិនោះក្នុង រយៈពេល ៣ ឆ្នាំ ចាប់តាំងពីពេលដែលខ្លួនក្លាយទៅជាអ្នកដែលអាចផ្តល់សច្ចានុមតិ នោះសិទ្ធិលុបចោល នឹងសិទ្ធិទាមទារឱ្យសង សេចក្តីចម្រើនដោយឥតហេតុដែលកើតឡើង ដោយសារ ការលុប

[37] សេចក្តីកំណត់ ចំពោះមាត្រាមីមួយ នៃក្រមរដ្ឋប្បវេណី ឆ្នាំ ២០១០ មាត្រា ៣៦១

[38] មាត្រា ៣៦២ កថាខណ្ឌទី២ នៃក្រមរដ្ឋប្បវេណី ឆ្នាំ ២០០៧

ចោលនោះត្រូវរលត់ ។ បញ្ញត្តិស្តីពីការផ្អាកអាជ្ញាយុកាលមិនត្រូវយកមកអនុវត្តឡើយចំពោះអំឡុងពេលនេះ។ ប៉ុន្តែសិទ្ធិលុបចោលត្រូវរលត់ដោយអំឡុងពេល ១០ ឆ្នាំ ចាប់ពីកាលបរិច្ឆេទនៃសកម្មភាពនោះ។ ក្រោយពេលអាជ្ញាយុកាលរំលត់ ត្រូវបានបញ្ចប់នោះជន ដែលមានសិទ្ធិលុបចោល មិនអាចលុបចោលសកម្មភាពដែលអាចលុបចោលនោះទៀតទេ ដូច្នេះសកម្មភាពនោះ ត្រូវចាត់ទុកថាមានសុពលភាពជាស្ថាពរ។

ក្នុងករណីដែលបុគ្គលច្រើននាក់ មានសិទ្ធិលុបចោលនូវ សកម្មភាពតែមួយបញ្ញត្តិនៃកថាខណ្ឌទី១ និងកថាខណ្ឌទី២ នៃមាត្រា ៣៦៣ នៃក្រមរដ្ឋប្បវេណី ឆ្នាំ ២០០៧ នេះត្រូវយកមកអនុវត្ត ចំពោះសិទ្ធិលុបចោលនៃបុគ្គលនីមួយៗនោះ។

### ១.៦ ឆន្ទានុម័តបដិសេធ

ជាគោលការណ៍ ប្រសិនបើកិច្ចសន្យា ត្រូវបានបង្កើតឡើងដោយការបង្ហាញឆន្ទៈ ដែលភាគីដឹងខ្លួនថាខុសពីឆន្ទៈពិតរបស់ខ្លួន កិច្ចសន្យានោះមិនត្រូវរារាំងនូវអានុភាពឡើយ។ ព្រោះភាគីម្ខាងទៀតមិនអាចដឹងថា តើអ្នកបង្ហាញឆន្ទៈ បានបង្ហាញឆន្ទៈរបស់ខ្លួនពិតប្រាកដ ឬ អត់។ ដូច្នេះ គេមិនចាំបាច់ការពារអ្នកបង្ហាញឆន្ទៈ ដែលបានធ្វើឋបនីយផ្លូវចិត្តឡើយ។ ឧទាហរណ៍៖ ក បានប្រាប់ ខ ថា សូមលក់ផ្ទះរបស់អ្នកមកឱ្យខ្ញុំ ទោះបីជាតាមពិតទៅគាត់មិនមានឆន្ទៈក្នុងការទិញផ្ទះរបស់ ខ ឡើយ។ នៅក្នុងករណីនេះ ប្រសិនបើ ខ បានធ្វើស៊ីការលើសំណើរបស់ ក នោះកិច្ចសន្យាត្រូវបានបង្កើតឡើងដោយមានអានុភាព ហើយ ក ត្រូវមានកាតព្វកិច្ចបង់ប្រាក់ថ្លៃទិញ។

ប៉ុន្តែ នៅក្នុងករណីដែលភាគីម្ខាងទៀត បានដឹងថាការបង្ហាញឆន្ទៈរបស់អ្នកបង្ហាញឆន្ទៈ ខុសពីឆន្ទៈពិតរបស់អ្នកបង្ហាញឆន្ទៈ អ្នកបង្ហាញឆន្ទៈអាចបដិសេធ ការអនុវត្តកាតព្វកិច្ចរបស់ខ្លួនបាន។ នៅក្នុងករណីនេះ កិច្ចសន្យាត្រូវបានបង្កើតឡើងដោយមានសុពលភាព ប៉ុន្តែ ការដែលភាគីម្ខាងទៀតបានដឹងថា ការបង្ហាញឆន្ទៈរបស់ ក មិនឆ្លុះបញ្ចាំងពីឆន្ទៈពិតប្រាកដ ត្រូវបានចាត់ទុកថាជាការតវ៉ា។ ដូច្នេះ អ្នកបង្ហាញឆន្ទៈដែលចង់បដិសេធការអនុវត្តកាតព្វកិច្ចរបស់ខ្លួន ចាំបាច់ត្រូវបង្ហាញពីភាពទុច្ចរិតរបស់ភាគីម្ខាងទៀត។

#### ១.៦.១ ឋបនីយផ្លូវចិត្ត

ឋបនីយផ្លូវចិត្ត គឺជាករណីដែលអ្នកបង្ហាញឆន្ទៈបានដឹងថា ការបង្ហាញឆន្ទៈនោះ គឺមិនមែនជាឆន្ទៈពិតប្រាកដរបស់ខ្លួន។[39]

ប្រសិនបើកិច្ចសន្យាត្រូវបានបង្កើតឡើង ដោយការបង្ហាញឆន្ទៈដែលភាគីដឹងខ្លួនថាខុសឆន្ទៈពិតប្រាកដរបស់ខ្លួន កិច្ចសន្យានោះមិនត្រូវរារាំងនូវអានុភាពឡើយ។ ប៉ុន្តែក្នុងករណីដែលភាគីម្ខាងទៀតក៏ដឹងថាការបង្ហាញឆន្ទៈនោះខុស នឹងឆន្ទៈពិតរបស់អ្នកបង្ហាញឆន្ទៈដែរអ្នកបង្ហាញឆន្ទៈនោះអាចបដិសេធ ការអនុវត្តកិច្ចសន្យាបាន។[40]

[39] សេចក្តីពន្យល់ អំពី ក្រមរដ្ឋប្បវេណី ភាគទី១ ឆ្នាំ ២០១៣ ទំព័រ ១៣៨

[40] មាត្រា ៣៥២ នៃក្រមរដ្ឋប្បវេណីឆ្នាំ ២០០៧

មានន័យថា ភាគីដែលបង្ហាញឆន្ទៈ ខ្លួនឯងផ្ទាល់នោះបាន ដឹងយ៉ាងពិតប្រាកដថា ការបង្ហាញ ឆន្ទៈដែលបានបង្ហាញឆន្ទៈនោះមិនមែនជាឆន្ទៈពិតប្រាកដរបស់ខ្លួនឡើយហើយខ្លួននៅតែសម្រេចចិត្ត ធ្វើការបង្ហាញទៀត។

**១.៦.២ ការការពារតតិយជន**

ប្រសិនបើកិច្ចសន្យាត្រូវបានបង្កើតឡើង ដោយការបង្ហាញឆន្ទៈ ដែលភាគីដឹងខ្លួនថាខុសឆន្ទៈពិតរបស់ខ្លួន កិច្ចសន្យានោះមិនត្រូវរារាំងនូវអានុភាពឡើយ។ ព្រោះភាគីម្ខាងទៀតមិនបានដឹងថាតើអ្នកបង្ហាញឆន្ទៈ បានបង្ហាញឆន្ទៈពិតប្រាកដដែរ ឬទេ។ ដូចនេះគេមិនចាំបាច់ការពារអ្នកបង្ហាញឆន្ទៈដែលដឹងថាការបង្ហាញឆន្ទៈនោះមិនមែនជាឆន្ទៈពិតប្រាកដរបស់ខ្លួនឡើយ។

ទោះបីជាមិនមាន បញ្ញត្តិច្បាប់ សំរាប់ការពារតតិយជនក្នុងចំណុចនេះក៏ដោយក៏ត្រូវតែ ការពារតតិយជនដែរ ព្រោះថាកិច្ចសន្យាមានអានុភាពទៅហើយ ដូចនេះត្រូវតែការពារតតិយជនដែលមានផលប្រយោជន៍ទាក់ទងនឹងកិច្ចសន្យានេះ។ ឧទាហរណ៍៖ ក បានប្រាប់ ខ គាត់ចង់ទិញដីរបស់ ខ ក្នុងតម្លៃ ៥០០០$ (ប្រាំពាន់ដុល្លារអាមេរិច) តែតាមពិតទៅ ក មិនចង់ទិញដីរបស់ ខ ឡើយ។ បន្ទាប់ពីទិញដីនោះ ក បានលក់ដីនោះឱ្យទៅ គ ។ ដូចនេះ ក មិនអាចលុបចោល ឬ ក៏ទាមទារដីពី គ វិញបានទេ កិច្ចសន្យាដែល ក ធ្វើជាមួយ គ ក៏មានសុពលភាពដែរ។

# ជំពូកទី ២
# ទណ្ឌកម្មក្រោយពេលបង្កើតកិច្ចសន្យា

# ជំពូកទី ២

# ទណ្ឌកម្មក្រោយពេលបង្កើតកិច្ចសន្យា

## ២.១ ការមិនអនុវត្តកាតព្វកិច្ច

នៅពេលដែល ភាគីនៃកិច្ចសន្យា បានបង្កើតកិច្ចសន្យាហើយនោះ ភាគីទាំងសងខាងត្រូវគោរពកាតព្វកិច្ច ដែលកើតឡើងពី កិច្ចសន្យាព្រោះកិច្ចសន្យាគឺជាច្បាប់របស់ភាគី ប្រសិនបើភាគីម្ខាងមិន អនុវត្តតាមកិច្ចសន្យា នោះទណ្ឌកម្មនឹងកើតមានឡើងចំពោះភាគីដែលមិនអនុវត្តកាតព្វកិច្ចនោះ។ ដែលទណ្ឌកម្មទាំងនោះមានដូចជា៖ ការអនុវត្តកាតព្វកិច្ចដោយបង្ខំ ការទាមទារសំណងនៃការខូចខាត និងការរំលាយកិច្ចសន្យា ។ ការអនុវត្តកាតព្វ-កិច្ចដោយបង្ខំ គឺ មានគោលបំណងឱ្យអនុវត្តកាតព្វកិច្ចដោយផ្ទាល់។ ចំណែកឯ ការទាមទារសំណងនៃការខូចខាត និងការរំលាយកិច្ចសន្យាជាការអនុវត្តកាតព្វកិច្ចដោយប្រយោល។

### ២.១.១ ទម្រង់នៃការមិនអនុវត្តកាតព្វកិច្ច

កូនបំណុលដែល មិនអនុវត្តកាតព្វកិច្ច គឺសំដៅទៅលើករណីដែលកូនបំណុលនោះ មិនអនុវត្តកាតព្វកិច្ច ដែលកើតឡើងពីកិច្ចសន្យា។ ទម្រង់នៃការមិនអនុវត្តកាតព្វកិច្ចមានដូចជា៖ ការយឺតយ៉ាវក្នុងការអនុវត្តកាតព្វកិច្ច អលទ្ធភាពក្នុងការអនុវត្តកាតព្វកិច្ច ការអនុវត្តកាតព្វកិច្ចមិនបាន ពេញលេញ និងករណីផ្សេងទៀតដែលគ្មាន ការអនុវត្តតាមខ្លឹមសារនៃកាតព្វកិច្ច។

#### ២.១.១.១ ការយឺតយ៉ាវក្នុងការអនុវត្តកាតព្វកិច្ច

យោងតាម បញ្ញត្តិ មាត្រា ៣៩១ នៃក្រមរដ្ឋប្បវេណី ឆ្នាំ ២០០៧ ការយឺតយ៉ាវក្នុងការអនុវត្តកាតព្វកិច្ច ត្រូវបានបែងចែកជា ៣ ប្រភេទ ៖

-ប្រសិនបើមានពេលកំណត់ពិតប្រាកដសម្រាប់អនុវត្តកាតព្វកិច្ចនៅពេលដល់កាលកំណត់នោះ។ ពេលកំណត់ពិតប្រាកដ សំដៅទៅលើកំណត់ពេលជាក់លាក់ ឧទាហរណ៖ ដូចជា ថ្ងៃទី ០១ ខែ មករា ឆ្នាំ ២០២០។

-ប្រសិនបើមានកំណត់ពេល មិនពិតប្រាកដសម្រាប់អនុវត្តកាតព្វកិច្ច នៅពេលដែលកូនបំណុលនោះដឹងថា ដល់ពេលកំណត់សងហើយ។ កំណត់ពេលមិនពិតប្រាកដ គឺជាកាលបរិច្ឆេទដែលពិតជាឈានមកដល់ ប៉ុន្តែមិនដឹងពិតប្រាកដថា នឹងមកដល់នៅពេលណា។

-ប្រសិនបើមិនបានកំណត់ពេល សម្រាប់អនុវត្តកាតព្វកិច្ចទេ នៅពេលដែលកូនបំណុលនោះទទួលការទាមទារឱ្យអនុវត្ត។ បញ្ញត្តិពិសេស សម្រាប់ខ្ចីបរិភោគ (មាត្រា ៥៩៤ កថាខណ្ឌទី២ នៃក្រមរដ្ឋប្បវេណី ឆ្នាំ ២០០៧) ប្រសិនបើភាគីមិនបានកំណត់កាលបរិច្ឆេទនៃការសងទេ អ្នកឱ្យខ្ចីអាចដាស់តឿនឱ្យសងដោយកំណត់អំឡុងពេលសមរម្យបាន។

#### ២.១.១.២ អលទ្ធភាពក្នុងការអនុវត្តកាតព្វកិច្ច

ប្រសិនបើគ្មានលទ្ធភាព ក្នុងការអនុវត្តទេ ការអនុវត្តកាតព្វកិច្ចក្លាយ ជាអលទ្ធភាព។ អលទ្ធភាពនេះ ត្រូវរាប់បញ្ចូលទាំងករណីដែលការអនុវត្តកាតព្វកិច្ចនោះ ត្រូវបានវាយតម្លៃថាមិនអាច ធ្វើកើតតាមស្ថានភាពសង្គម ឬ សេដ្ឋកិច្ចផងដែរ។ ប្រសិនបើការដែលមិនអាច អនុវត្តកាតព្វកិច្ចនៅពេលកំណត់ ដែលត្រូវអនុវត្តមានពិតប្រាកដមុនពេលកំណត់ត្រូវអនុវត្ត ការអនុវត្តកាតព្វកិច្ចត្រូវបានជាអលទ្ធភាពនៅពេលនោះ។[41]

ប្រសិនបើ ការអនុវត្តកាតព្វកិច្ច នឹងក្លាយទៅជាអលទ្ធភាពដោយសារ តែកំហុសរបស់កូនបំណុលនៅមុនពេលកាលបរិច្ឆេទ ត្រូវចាត់ទុកថា អលទ្ធភាពក្នុងការអនុវត្ត ។ ដូច្នេះ នៅក្នុងករណីនេះម្ចាស់បំណុលអាចទាមទារសំណងការខូចខាតបានទោះបីជាកាលបរិច្ឆេទមិនទាន់មកដល់ក៏ដោយ ។ ឧទាហរណ៍៖ ក បានលក់ គំនូរបុរាណដែលមានតែមួយគត់ទៅឱ្យ លោក ខ ។ តែនៅមិនពេលប្រគល់គំនូរនោះត្រូវបានភ្លើងឆេះអស់ ដូច្នេះ ការប្រគល់គំនូររបស់ លោក ក បានក្លាយទៅជាអលទ្ធភាព។

#### ២.១.២.៣ ការអនុវត្តកាតព្វកិច្ចមិនបានពេញលេញ

ការអនុវត្តកាតព្វកិច្ច មិនបានពេញលេញ សំដៅទៅលើករណីដែល កូនបំណុលមិនបានអនុវត្តកាតព្វកិច្ចតែការផ្តល់តាវកាលិកមិនបានពេញលេញឬករណីដែលបានអនុវត្តតែមួយផ្នែកនៃកាតព្វកិច្ច ឬ ករណីផ្សេងទៀតដែលគ្មានការ អនុវត្តឱ្យបានពេញលេញ តាមខ្លឹមសារនៃកាតព្វកិច្ច ។[42]

នៅពេលដែលការអនុវត្តកាតព្វកិច្ច មិនត្រូវបានធ្វើឡើងនោះ ត្រូវចាត់ទុកថាជាការយឺតយ៉ាវក្នុងការអនុវត្ត ឬ អលទ្ធភាពក្នុងការអនុវត្ត មិនមែនជាការអនុវត្តមិនបានពេញលេញនោះទេ។ ម្យ៉ាងវិញទៀត ប្រសិនបើកម្មវត្ថុនៃការលក់ទិញមានវិការៈ វាគឺជាការអនុវត្តមិនបានពេញលេញ។ ប៉ុន្តែនៅក្នុងកិច្ចសន្យាលក់ទិញ មានបញ្ញត្តិពិសេស ដែលទាក់ទងទៅនឹងការធានារបស់អ្នកលក់។

#### ២.១.២.៤ ករណីផ្សេងនៃការមិនអនុវត្តកាតព្វកិច្ច

ក្រៅពីការយឺតយ៉ាវ ក្នុងការអនុវត្តកាតព្វកិច្ចអលទ្ធភាពក្នុងការអនុវត្តកាតព្វកិច្ច ករណីដែលមានការបំពានករណីកិច្ចផ្សេងដែលកើតឡើងពីកិច្ចសន្យា ក៏ត្រូវចាត់ទុកជាការមិនអនុវត្តកាតព្វកិច្ចដែរ ។[43] ចំណុចនេះបានទុកជម្រើសឱ្យដើម្បីដោះស្រាយ ចំពោះការមិនអនុវត្តកាតព្វកិច្ចផ្សេងដែលមិនមាននៅក្នុងចំណុចទាំង ៣ ខាងលើ។ ឧទាហរណ៍៖ ក្នុងករណីដែលអ្នកលក់ ផ្តល់តាវកាលិកជាបសុសត្វដែលមានវិការៈ (ជម្ងឺ) ឱ្យទៅអ្នកទិញ ប្រសិនបើជម្ងឺនេះឆ្លងទៅបសុសត្វរបស់អ្នកទិញផងដែរនោះ ករណីនេះជាករណីដែលការ អនុវត្តកាតព្វកិច្ច

[41] មាត្រា ៣៩២ កថាខណ្ឌទី១ នៃក្រមរដ្ឋប្បវេណី ឆ្នាំ ២០០៧

[42] មាត្រា ៣៩៣ នៃក្រមរដ្ឋប្បវេណី ឆ្នាំ ២០០៧

[43] មាត្រា ៣៩៤ នៃក្រមរដ្ឋប្បវេណី ឆ្នាំ ២០០៧

មិនបានពេញលេញ ប៉ុន្តែការដែលជំងឺឆ្លងទៅបសុបសត្វរបស់អ្នកទិញ មិនត្រឹមតែជាការអនុវត្ត កាតព្វកិច្ចមិនបានពេញលេញនោះទេ គឺនាំឱ្យមានការខូចខាតចំពោះ ភាគីម្ខាងទៀត ហេតុដូច្នេះវាគួរត្រូវបានបកស្រាយថាជាករណីផ្សេងនៃការមិនអនុវត្តកាតព្វកិច្ច។

## ២.២ ការអនុវត្តកាតព្វកិច្ចដោយបង្ខំ

ការអនុវត្តកាតព្វកិច្ចដោយបង្ខំ គឺជាការចាប់បង្ខំកូនបំណុលឱ្យ អនុវត្តកាតព្វកិច្ច របស់ខ្លួនដោយបង្ខំតាមនីតិវិធីតុលាការ។ ការអនុវត្តកាតព្វកិច្ចដោយបង្ខំនេះត្រូវ អនុវត្តតាមក្រមនីតិវិធីរដ្ឋប្បវេណី។ ក៏ប៉ុន្តែប្រសិនបើលក្ខណៈនៃកាតព្វកិច្ចមិនសមនឹងការអនុវត្តដោយបង្ខំ ម្ចាស់បំណុលមិនអាចប្រើប្រាស់មធ្យោបាយនេះបានទេ។

### ២.២.១ ប្រភេទនៃការអនុវត្តកាតព្វកិច្ចដោយបង្ខំ

ប្រសិនបើកូនបំណុលមិនអនុវត្តកាតព្វកិច្ចដោយស្ម័គ្រចិត្តនោះម្ចាស់បំណុលអាចបង្ខំឱ្យកូនបំណុលអនុវត្តកាតព្វកិច្ចទៅតាមនីតិវិធីអនុវត្តដោយបង្ខំ។

ការអនុវត្តដោយបង្ខំដោយឈរលើទស្សនៈ វិស័យនៃនីតិវិធីដែលត្រូវយកមកប្រើមាន ៣ ប្រភេទ ដូចជា ៖

-ការអនុវត្តដោយផ្ទាល់

-ការអនុវត្តជំនួស

-ការអនុវត្តដោយប្រយោល។[44]

#### ២.២.១.១ ការអនុវត្តដោយផ្ទាល់

ភាគីដែលឈ្នះក្តី អាចយកសាលក្រមដែលចូលជាស្ថាពរទៅឱ្យកូនបំណុលអនុវត្តបាន។ នេះគឺជាការធ្វើឱ្យសម្រេចនូវកម្មវត្ថុនៃកាតព្វកិច្ចដោយផ្ទាល់ដោយស្ថាប័នអនុវត្តដែលមានភាពសមស្របចំពោះការអនុវត្តកាតព្វកិច្ច ដូចជាការអនុវត្តដោយបង្ខំចំពោះសិទ្ធិទាមទារ ដែលមានគោលបំណងឱ្យសងជាប្រាក់ និងការអនុវត្តដោយបង្ខំឱ្យប្រគល់ចលនវត្ថុ អចលនវត្ថុ។[45]

#### ២.២.១.២ ការអនុវត្តជំនួស

នៅពេលដែល សេចក្តីសម្រេចរបស់តុលាការចូលជាស្ថាពរនោះម្ចាស់បំណុលអាចសម្រេចនូវសិទ្ធិទាមទាររបស់ខ្លួនដែលអាចធ្វើឡើងដោយខ្លួនឯង ឬតតិយជនដោយធ្វើជំនួសក្នុងនាមកូនបំណុលដើម្បីប្រមូលសោហ៊ុយពីកូនបំណុល។[46] វិធីនេះល្អសម្រាប់ការអនុវត្តកាតព្វកិច្ចដែលមិនសមស្របនឹងឱ្យស្ថាប័នអនុវត្តធ្វើការអនុវត្តដោយផ្ទាល់បានប៉ុន្តែទោះបីជាកូនបំណុលមិនសម្រេចនូវខ្លឹមសារនៃតាវកាលិកនោះដោយខ្លួនឯងក៏ដោយ

[44] សេចក្តីពន្យល់ អំពី ក្រមរដ្ឋប្បវេណី ភាគទី១ ឆ្នាំ ២០១៣ ទំព័រ ១៦១

[45] គន្ថីទី៦ ជំពូកទី២ នៃក្រមនីតិវិធីរដ្ឋប្បវេណី ឆ្នាំ ២០០៦

[46] មាត្រា ៥២៧ នៃក្រមនីតិវិធីរដ្ឋប្បវេណី ឆ្នាំ ២០០៦

ក៏ការសម្រេចឱ្យបាននូវលទ្ធផលដូចគ្នា នោះជាការគ្រប់គ្រាន់ដែរសម្រាប់ម្ចាស់បំណុល។ កាតព្វកិច្ចបែបនេះមានដូចជាកាតព្វកិច្ចដែលមានគោលបំណងឱ្យធ្វើសកម្មភាពណាមួយដែលអាចជំនួសបាន។

#### ២.២.១.៣ វិធានបង្ខំដោយប្រយោល

វិធានបង្ខំដោយប្រយោលគឺជាវិធានមួយដែលដាក់ការគាបសង្កត់ ផ្នែកផ្លូវចិត្តទៅលើកូនបំណុល ដើម្បីបង្ខំឱ្យកូនបំណុលនោះ អនុវត្តកាតព្វកិច្ចរបស់ខ្លួន។[47] វិធានការណ៍នៃការគាបសង្កាត់នេះមានដូចជា ការគាបសង្កាត់ឱ្យបង់ប្រាក់ ជាសំណងសងការខូចខាតការដាក់ទោសដោយអាជ្ញាធររដ្ឋការដាក់ទណ្ឌកម្ម ឬការដាក់ពន្ធនាគារជាដើម។ ចំពោះការអនុវត្តទៅលើរូបរាងកាយ និងឆន្ទៈសេរីរបស់កូនបំណុល គឺមានលក្ខណៈខ្លាំងជាងការអនុវត្តដោយផ្ទាល់។ វីធីនេះត្រូវបានប្រើប្រាស់សម្រាប់ អនុវត្តកាតព្វកិច្ច ដែលមានតែសកម្មភាព របស់កូនបំណុលទេ ដែលអាចធ្វើឱ្យសម្រេចនូវកម្មវត្ថុនោះបាន ដូចជាកាតព្វកិច្ច ដែលមានគោលបំណងឱ្យធ្វើ ឬ មិនធ្វើសកម្មភាពអ្វីមួយដែលមិនអាចជំនួសបានប៉ុន្តែវិធាននេះ ក៏អាចអនុវត្តចំពោះកាតព្វកិច្ចធ្វើសកម្មភាពដែលអាចជំនួសបានដែរ។

### ២.៣ សំណងនៃការខូចខាត

សំណងនៃការខូចខាត គឺជាការខូចខាតដែលបណ្ដាល មកពីការមិនអនុវត្តកាតព្វកិច្ចក្នុងកិច្ចសន្យា។ ក្នុងករណីដែលកូនបំណុលមិនអនុវត្តកាតព្វកិច្ចទេ ម្ចាស់បំណុលអាចទាមទារសំណងនៃការខូចខាតដែលកើតឡើង ដោយសារការមិនអនុវត្តកាតព្វកិច្ចបាន។ ប៉ុន្តែក្នុងករណីដែលកូនបំណុលមានសំអាងបញ្ជាក់ថា ខ្លួនគ្មានកំហុសចំពោះការមិនអនុវត្តកាតព្វកិច្ចនោះទេ កូនបំណុលនោះ ត្រូវរួចផុតពីការទទួលខុសត្រូវក្នុងការសងសំណងខូចខាត។

ក្នុងករណីដែលកូនបំណុល ឱ្យអ្នកដទៃទៀតធ្វើជាអ្នកជំនួយដើម្បីឱ្យ ជួយអនុវត្តកាតព្វកិច្ច កូនបំណុលនោះមិនអាចរួចផុតពីការទទួលខុសត្រូវ ក្នុងការសងសំណងការខូចខាតបានទេលើកលែងតែ កូនបំណុលនោះមានសំអាងបញ្ជាក់ថា ខ្លួនគ្មានកំហុសក្នុងការជ្រើសតាំងនិងការត្រួតពិនិត្យអ្នកជំនួយទេ ហើយអ្នកជំនួយនោះក៏គ្មានកំហុសដែរ។[48]

**ដើម្បីទាមទារសំណងការខូចខាត ត្រូវមានលក្ខខណ្ឌមួយចំនួនដូចជា៖**

- កាតព្វកិច្ចមិនត្រូវបានអនុវត្ត
- ការមិនអនុវត្តដោយកំហុសរបស់កូនបំណុលដើម្បីជៀសវាងការសងសំណងនៃការខូចខាតនោះ កូនបំណុលត្រូវបង្ហាញថាខ្លួនមិនបានប្រព្រឹត្តនូវកំហុសទេ។

[47] មាត្រា ៥២៧ នៃក្រមនីតិវិធីរដ្ឋប្បវេណី ឆ្នាំ ២០០៦

[48] មាត្រា ៣៩៤ នៃក្រមរដ្ឋប្បវេណី ឆ្នាំ ២០០៧

### ២.៣.១ លក្ខខណ្ឌចំពោះកាតព្វកិច្ចជាប្រាក់

ចំពោះកាតព្វកិច្ចដែលមានគោលបំណងសងជាប្រាក់ទោះបីជាកូនបំណុលមានសំអាង បញ្ជាក់ថា ការយឺតយ៉ាវក្នុងការសងបានកើតឡើងដោយប្រធានសក្តិក៏ដោយ ក៏កូនបំណុលនោះមិនរួចផុតពីការសងការប្រាក់ក្នុងអំឡុងពេលនៃការយឺតយ៉ាវនោះបានដែរ។[49] នេះមានន័យថា ការកន្លងហួសនៃកំណត់ពេលត្រូវអនុវត្តកាតព្វកិច្ចជាប្រាក់ ត្រូវក្លាយទៅជាការយឺតយ៉ាវក្នុងការអនុវត្តជានិច្ច ហើយការប្រាក់ក្នុងអំឡុងពេលនៃការយឺតយ៉ាវដែលជាសំណងនៃការខូចខាត ត្រូវបានទទួលស្គាល់ដោយមិនគិតពិចារណានូវអត្ថិភាព ឬនត្ថិភាពនៃកំហុសរបស់កូនបំណុលទេ។

ចំពោះការខូចខាត ដែលមានចំនួនលើសពីការប្រាក់ ក្នុងអំឡុងពេលនៃការយឺតយ៉ាវ ប្រសិនបើកូនបំណុលមានសំអាងបញ្ជាក់ថា ខ្លួនគ្មានកំហុសចំពោះការ មិនអនុវត្តកាតព្វកិច្ចនោះទេ នោះកូនបំណុលត្រូវរួចផុតពីការមិនទទួលខុសត្រូវក្នុងការសងការខូចខាត។[50] ចំពោះករណីខ្លះ ការយឺតយ៉ាវនៃការសង គឺធ្វើឱ្យមានការខូចខាត ក្រៅពីការប្រាក់។

### ២.៣.២ ករណីដែលកូនបំណុលឱ្យអ្នកដទៃធ្វើជាអ្នកជំនួយ

ក្នុងករណីដែលកូន បំណុលឱ្យអ្នកដទៃធ្វើជាអ្នកជំនួយដើម្បីឱ្យ ជួយអនុវត្តកាតព្វកិច្ចកូនបំណុលនោះមិនអាចរួចផុតពីការ ទទួលខុសត្រូវក្នុងការ សងសំណងការខូចខាតបានទេ លើកលែងតែ កូនបំណុលមានសំអាងបញ្ជាក់ថា ខ្លួនគ្មានកំហុសក្នុងការជ្រើសតាំង និងការត្រួតពិនិត្យអ្នកជំនួយ អ្នកជំនួយនោះក៏គ្មានកំហុសដែរ។[51]

បើយោងតាម គោលការណ៍សេរីភាពបុគ្គលឯកជន កូនបំណុលមិនចាំបាច់សងសំណងនៃការខូចខាតដែលបង្កឡើងដោយសកម្មភាពរបស់អ្នកដទៃឡើយ តែដោយសារតែ កូនបំណុលបានទទួលផលប្រយោជន៍ ពីការប្រើប្រាស់អ្នកជំនួយ និងអ្នកជំនួយ ត្រូវស្ថិតនៅក្រោមការពិនិត្យ របស់កូនបំណុល។ នៅក្នុងចំណុចនេះ ក្រមរដ្ឋប្បវេណីមិនបានចែងពីនិយមន័យនៃពាក្យ អ្នកជំនួយទេ ប៉ុន្តែ ពាក្យនេះប្រើសំដៅទៅលើបុគ្គលដែលកូនបំណុលអាចត្រួតពិនិត្យបាន។

### ២.៣.៣ ទស្សនៈអំពីការខូចខាត

ម្ចាស់បំណុល អាចទាមទារសំណងនៃការខូចខាត គឺទាមទារសំណងនៃផលប្រយោជន៍ ពីការអនុវត្តដែលខ្លួនត្រូវទទួលបានដោយកិច្ចសន្យានោះ ហើយក្រៅពីនេះអាចទាមទារផងដែរនូវចំណាយដែលគ្មាន

[49] មាត្រា ៣៩៩ កថាខណ្ឌទី១ នៃក្រមរដ្ឋប្បវេណី ឆ្នាំ ២០០៧

[50] មាត្រា ៣៩៩ កថាខណ្ឌទី២ នៃក្រមរដ្ឋប្បវេណី ឆ្នាំ ២០០៧

[51] មាត្រា ៣៩៨ កថាខណ្ឌទី២ នៃក្រមរដ្ឋប្បវេណី ឆ្នាំ ២០០៧

ប្រយោជន៍ដោយសារការមិនអនុវត្ត និងចំណាយ ឬ បន្ទុកដែលបង្កើតឡើងដោយសារការមិនអនុវត្តកាតព្វកិច្ច ក្នុងទំហំដែលមិនជាន់គ្នាជាមួយនឹងសំណងនៃផលប្រយោជន៍ពីការមិនអនុវត្ត។

តុលាការក៏អាចបង្គាប់ឱ្យកូនបំណុលសងសំណងនៃការខូចខាតខាងផ្លូវចិត្ត ដោយផ្អែកលើការទាមទាររបស់ ម្ចាស់បំណុលបានដែរ។ ចំពោះចំនួនសំណងនៃការខូចខាតខាងផ្លូវចិត្ត តុលាការត្រូវសម្រេចដោយគិតពិចារណាអំពីកាលៈទេសៈជុំវិញផ្សេងៗ។

យោងតាម បញ្ញត្តិមាត្រា ៤០០ នៃក្រមរដ្ឋប្បវេណី ឆ្នាំ ២០០៧ ប្រភេទទស្សនៈនៃការខូចខាត មាន ៣ ប្រភេទ ៖

- ការបាត់បង់ផលប្រយោជន៍ពីការអនុវត្ត
- ការចំណាយផ្សេងៗដែលទាក់ទងនឹងកិច្ចសន្យា
- ការខូចខាតខាងផ្លូវចិត្ត។

### ២.៣.៣.១ ការបាត់បង់ផលប្រយោជន៍ពីការអនុវត្ត

សំណងនៃការខូចខាត គឺជាសំណងដែលមានកម្មវត្ថុ ជាផលប្រយោជន៍ពីការអនុវត្ត មានន័យថា ជាផលប្រយោជន៍ដែលអាចទទួលបានប្រសិនបើកិច្ចសន្យាត្រូវបានអនុវត្ត។ ឧទាហរណ៍៖ ក បានទិញម៉ូតូពី ខ ហើយ ខ បានពន្យាពេលក្នុងការប្រគល់ម៉ូតូអស់រយៈពេលមួយខែ ដែលធ្វើឱ្យ ក បានទៅជួលម៉ូតូពី គ ដើម្បីប្រើប្រាស់អស់រយៈពេលមួយខែ ហើយចំណាយប្រាក់អស់ ១០០$ ( មួយរយដូល្លារអាមេរិច)។ ដូច្នេះ ក អាចទាមទារសំណងនៃការខូចខាត ដែលជាប្រាក់ថ្លៃជួលម៉ូតូក្នុងរយៈពេលមួយខែនេះ។

### ២.៣.៣.២ ការចំណាយផ្សេងៗដែលទាក់ទងនឹងកិច្ចសន្យា

ប្រសិនបើកូនបំណុល ខកខានក្នុងការអនុវត្តកាតព្វកិច្ចរបស់ខ្លួនវាធ្វើឱ្យមានការខូចខាតកើតឡើងចំពោះម្ចាស់បំណុល មិនត្រឹមតែផលប្រយោជន៍ ពីការអនុវត្តប៉ុណ្ណោះទេ។ ម្ចាស់បំណុលមានការចំណាយមួយចំនួនដែលមិនត្រឹមត្រូវដូចជា៖

-ការចំណាយដែលគ្មានប្រយោជន៍ដោយសារការមិនអនុវត្ត

-ការចំណាយ ឬ បន្ទុកដែលបង្កើតឡើងដោយសារការមិនអនុវត្តកាតព្វកិច្ច ឧទាហរណ៍៖ ដោយ សារកូនបំណុលមិនអនុវត្តកាតព្វកិច្ច ម្ចាស់បំណុលត្រូវធ្វើលិខិតទាមទារតាមប្រៃសណីយ៍និងថ្លៃពិគ្រោះជាមួយមេធាវី។ នេះគឺជាចំណាយ ឬបន្ទុកដែលបង្កើតឡើង ដោយសារការមិនអនុវត្តកាតព្វកិច្ច។

### ២.៣.៣.៣ ការខូចខាតផ្លូវចិត្ត

តុលាការអាចបង្គាប់ឱ្យកូនបំណុលសងសំណងនៃការខូចខាតខាងផ្លូវចិត្តដោយផ្អែកលើការទាមទាររបស់ម្ចាស់បំណុលបានដែរ។ ចំពោះចំនួននៃសំណងការខូចខាតខាង ផ្លូវចិត្តតុលាការត្រូវសម្រេចដោយគិតពិចារណា

អំពីកាលៈទេសៈជុំវិញផ្សេងៗ។

ការខូចខាតខាងផ្លូវចិត្ត មានន័យទូលំទូលាយណាស់ ហើយវាពុំមានការកំណត់ច្បាស់លាស់ទេ ព្រោះ ការខូចខាតបែបនេះ មិនអាចប៉ាន់ស្មានបាន ឬ មិនអាចកំណត់ច្បាស់លាស់បានឡើយ ប៉ុន្តែគំនិតទូទៅ វាត្រូវ បានសម្រេចដោយចៅក្រម ដោយធ្វើការពិចារណាទៅលើស្ថានភាពជាក់ស្តែងកម្រិត ឬ ប្រភេទនៃការខូចខាត ខាងផ្លូវចិត្ត។ ដូច្នេះ តុលាការ កម្រនឹងទទួលស្គាល់នូវសំណងនៃការខូចខាតខាងផ្លូវចិត្ត ក្រៅពីសំណងនៃ បាត់បង់ទ្រព្យសម្បត្តិ នៅក្នុងករណីនៃការបាត់បង់ទ្រព្យសម្បត្តិ។[52]

### ២.៣.៤ ទំហំនៃសំណងការខូចខាត

យោងតាមបញ្ញត្តិ មាត្រា ៤០១ នៃក្រមរដ្ឋប្បវេណីឆ្នាំ ២០០៧ ទំហំនៃសំណងការខូចខាត ត្រូវបានចែក ជា ពីរប្រភេទ មានដូចជា៖

- ការខូចខាតធម្មតា
- ការខូចខាតពិសេស។

#### ២.៣.៤.១ ការខូចខាតធម្មតា

ការខូចខាតធម្មតា សំដៅទៅលើការខូចខាតដែល កើតឡើងជាធម្មតា ចំពោះម្ចាស់បំណុល ដោយសារ ការមិនអនុវត្តកាតព្វកិច្ច។[53] ការខូចខាតធម្មតាមានដូចជា៖

- ការយឺតយ៉ាវក្នុងការអនុវត្ត ការខូចខាតធម្មតាគឺជាតម្លៃនៃ អត្ថប្រយោជន៍នៅក្នុងពេលយឺតយ៉ាវ នោះ។
- អលទ្ធភាពក្នុងការអនុវត្ត ការខូចខាតជាធម្មតា គឺជាតម្លៃថ្នូរ។
- ការអនុវត្តមិនបានពេញលេញ ការខូចខាតជាធម្មតា គឺជាតម្លៃនៃអត្ថប្រយោជន៍ ប្រសិនបើការ អនុវត្តពេញលេញ ត្រូវបានធ្វើឡើង និងជាតម្លៃថ្នូរបើការអនុវត្តពេញលេញមិនត្រូវបានធ្វើឡើង។

#### ២.៣.៤.២ ការខូចខាតពិសេស

ការខូចខាតពិសេស ជាការខូចខាតដែលកើតឡើង ចំពោះម្ចាស់បំណុលដោយសារ កាលៈទេសៈពិសេស ហើយគូភាគីនៃកិច្ចសន្យាអាចព្យាករណ៍បាននៅ ការខូចខាតនោះដែលនឹងអាចកើតឡើង នៅពេលធ្វើកិច្ចសន្យា នោះ។ ប៉ុន្តែ បញ្ញត្តិនេះ មិនត្រូវយកមកអនុវត្តឡើយ ចំពោះករណីដែលគូភាគីនៃកិច្ចសន្យាមិនបានគិតគូរ ពិចារណាអំពីការខូចខាតពិសេសនោះនៅពេលធ្វើកិច្ចសន្យា។[54] ឧទាហរណ៍៖ ករណីដឹកវត្ថុបុរាណជាទូទៅ អ្នក

[52] សេចក្តីពន្យល់ អំពីក្រមរដ្ឋប្បវេណី ភាគទី១ ឆ្នាំ ២០១៣ ទំព័រ ១៦៥

[53] មាត្រា ៤០១ ចំណុច ក នៃក្រមរដ្ឋប្បវេណី ឆ្នាំ ២០០៧

[54] មាត្រា ៤០១ ចំណុច ខ នៃក្រមរដ្ឋប្បវេណី ឆ្នាំ ២០០៧

ដឹកជញ្ជូនត្រូវយកថ្លៃដឹកជញ្ជូនខ្ពស់ ជាងតំលៃធម្មតា ។ ប្រសិនបើម្ចាស់វត្ថុបុរាណមិនបានបង់តាមតម្លៃពិសេសនោះទេ វាមានន័យថា ភាគីនៃកិច្ចសន្យាដឹងថា វត្ថុបុរាណនោះមានតម្លៃខ្ពស់ ប៉ុន្តែ គ្មានឆន្ទៈរៀបចំការដឹកជញ្ជូនពិសេសទេ ដូច្នេះក្នុងករណីនេះ ភាគីនៃកិច្ចសន្យា មិនបានពិចារណាអំពីការខូចខាតពិសេស ដែលកើតឡើងដោយសារកាលៈទេសៈទេ ហើយអ្នកដឹងជញ្ជូនមិនចាំបាច់សងសំណងនៃការខូចខាតដែលមានតម្លៃខ្ពស់ទេ។

**២.៣.៤.៣ ការមិនអនុវត្តកាតព្វកិច្ចដោយផ្អែកលើគំនិតព្យាបាទ ឬអំពើមិនស្មោះត្រង់ហួសហេតុ**

ក្នុងករណីដែលកូនបំណុល មិនអនុវត្តកាតព្វកិច្ចដោយមានឆន្ទៈព្យាបាទ ឬដោយអំពើមិនស្មោះត្រង់ហួសហេតុតុលាការអាចបង្គាប់ ឱ្យកូនបំណុលសងផលប្រយោជន៍ ដែលកូនបំណុលបានទទួល ពីអំពើដែលជាការមិនអនុវត្តកាតព្វកិច្ច ដោយផ្អែកលើការទាមទាររបស់កូនបំណុលបាន។[55]

បញ្ហានេះដោយសារមានករណីដែលកូនបំណុលមិនអនុវត្តកាតព្វកិច្ចដោយមានគោលបំណងបង្កនូវការខូចខាតទៅដល់ម្ចាស់បំណុល ។ ឧទាហរណ៍៖ ក បានលក់មាន់ទៅឱ្យ ខ ដែលជាមាន់មានជំងឺ ហើយ ក ក៏បានដឹងពីហេតុការណ៏នេះដែរ ។ បន្ទាប់មកក្រោយពីបានដាក់មាន់ដែលបានទិញចូលទៅជាមួយមាន់ដែលមានស្រាប់នោះ ធ្វើឱ្យមានរបស់ ខ ឆ្លងជំងឺហើយស្លាប់ទាំងអស់ ។ ការការខូចខាតប្រភេទនេះ ត្រូវបានគេចាត់ទុកថាជាឆន្ទៈព្យាបាទ និងត្រូវសងសំណងនៃការខូចខាតទោះបីជាការខូចខាតនោះមិនបានព្យាករណ៏មុនក៏ដោយ ។

**២.៣.៥ មូលហេតុដែលនាំឱ្យបន្ថយសំណងនៃការខូចខាត**

កាលបើការ មិនអនុវត្តកាតព្វកិច្ច ឬការខូចខាតកើតឡើងផ្អែកខ្លះត្រូវបានបង្កឡើងដោយកំហុសរបស់ម្ចាស់បំណុល តុលាការអាចបន្ថយនូវចំនួននៃសំណងការខូចខាតដែលកូនបំណុលត្រូវសងបាន តាមកម្រិតនៃការបង្កនោះ ។[56] ឧទាហរណ៍៖ ក្នុងករណីដែលអ្នកជំងឺដែលមានលក្ខណៈ ពិសេសចំពោះសុខភាព មិនបានជូនដំណឹងដល់វេជ្ជបណ្ឌិតអំពីលក្ខណៈ ពិសេសហើយការព្យាបាលអ្នកជំងឺបានទទួលជោគជ័យដោយសារប្រតិកម្មនៃថ្នាំស្ពឹកនិងអ្នកជំងឺទទួលផលប៉ះពាល់ ។ ប្រសិនបើអ្នកជំងឺនោះបានជូនដំណឹងអំពីលក្ខណៈពិសេសនៃសុខភាពរបស់ខ្លួនការព្យាបាលអាចទទួលបានជោគជ័យ ហេតុដូច្នេះ តុលាការអាចកាត់បន្ថយចំនួនទឹកប្រាក់នៃសំណងការខូចខាតដែល វេជ្ជបណ្ឌិតត្រូវសង ដោយពិចារណាទៅលើកម្រិតនៃកំហុសរបស់អ្នកជំងឺ។

ក្នុងករណីដែលការខូចខាតកើតឡើង ដោយសារម្ចាស់បំណុលធ្វេសប្រហែស ក្នុងការសម្រាលការខូចខាតនោះ តុលាការអាចបន្ថយចំនួន នៃសំណងការខូចខាត ដែលកូនបំណុលត្រូវសង តាមកម្រិតនៃការខូចខាត

[55] មាត្រា ៤០១ ចំណុច គ នៃក្រមរដ្ឋប្បវេណី ឆ្នាំ ២០០៧

[56] មាត្រា ៤០២ កថាខណ្ឌទី១ នៃក្រមរដ្ឋប្បវេណី ឆ្នាំ ២០០៧

ដែល ម្ចាស់បំណុលអាចសម្រាលបាននោះ ។[57] ឧទាហរណ៍៖ ក្នុងករណីដែលគ្រូពេទ្យដែលបានវះកាត់អ្នកជំងឺ ប៉ុន្តែ ការជាសះស្បើយរបស់អ្នកជំងឺ មានការយឺតយ៉ាវ ដោយសារកំហុស កំឡុងពេលព្យាបាល។ ទន្ទឹមនឹងនោះ អ្នកជំងឺ ក៏មិនបានធ្វើតាមបង្គាប់របស់គ្រូពេទ្យ ដែលត្រូវសម្រាកក្រោយពីវះកាត់ ដែលជាហេតុធ្វើឱ្យ ការជាសះស្បើយរបស់អ្នកជំងឺ កាន់តែយឺតថែមទៀត ។ ក្នុងករណីនេះ អ្នកជំងឺ អាចទាមទារសំណងនៃការខូចខាតពីគ្រូពេទ្យបាន តែសំណងនៃការខូចខាត ត្រូវបានកាត់បន្ថយ ។

### ២.៣.៦ គោលការណ៍នៃការសងការខូចខាតជាប្រាក់

ចំពោះសំណងនៃការខូចខាត ដែលកើតឡើងដោយសារការមិនអនុវត្តកាតព្វកិច្ច កូនបំណុលត្រូវសងជាប្រាក់។ ប៉ុន្តែ បញ្ញត្តិនេះមិនត្រូវយកមកអនុវត្តឡើយ ចំពោះករណីដែលភាគីទាំងសងខាងបានកំណត់ផ្សេងពីនេះដោយការសន្យាពិសេស។[58] យោងតាមទស្សនៈនេះប្រសិនបើជនណាម្នាក់ធ្វើឱ្យមានបែកបាក់វត្ថុនោះ ជននោះត្រូវតម្រូវឱ្យ ធ្វើសំណងការខូចខាតចំពោះវត្ថុនោះ ដោយធ្វើការជួសជុលវត្ថុនោះ។ ប្រសិនបើជនណាម្នាក់បានធ្វើឱ្យវត្ថុនោះប្រឡាក់ ជននោះត្រូវតម្រូវឱ្យសងសំណងការខូចខាតដោយធ្វើការសំអាតវត្ថុនោះ។ ប៉ុន្តែទោះបីជាក្នុងករណីនេះក៏ដោយ វាមានភាពងាយស្រួលក្នុងការទាមទារឱ្យពួកគេបង់ថ្លៃជាទឹកប្រាក់ទៅលើការចំណាយជួសជុល ឬ សំអាតវត្ថុនោះ ដូច្នេះហើយ គោលការណ៍នៃការសងការខូចខាតជាទឹកប្រាក់ត្រូវបានយកមកអនុវត្ត។ ទោះបីជាយ៉ាងណាក៏ដោយ ប្រសិនបើភាគីពាក់ព័ន្ធទាំងអស់ ព្រមព្រៀងទៅលើ វិធីផ្សេងពីការសងជាប្រាក់ វិធីនោះក៏ត្រូវបានអនុញ្ញាតផងដែរ។

ចំពោះបញ្ហាដូច ជាការខូចខាតដល់បរិស្ថាន ជាអាទិ៍ ការសងសំណងនៃការខូខាត ដោយការធ្វើបដិទានមានតួនាទីដ៏សំខាន់។ ប៉ុន្តែ ទស្សនៈនឹងចែងនៅក្នុងច្បាប់ ឬ វិធានដោយឡែក។

### ២.៣.៧ ចំណុចដែលជាមូលដ្ឋាននៃពេលដែលត្រូវគណនាការខូចខាត

តម្លៃកម្មវត្ថុនៃកិច្ចសន្យា គឺមានការប្រែប្រួលនៅពេលខ្លះ ហើយវិធីក្នុងការគណនាការខូចខាត គឺជាបញ្ហានៅក្នុងករណីដែលមានការប្រែប្រួលនៃថ្លៃទំនិញ។ ភាគីសម្រេចពីតម្លៃកម្មវត្ថុនៃកិច្ចសន្យាដោយអនុលោមតាមតម្លៃនៅពេលបង្កើតកិច្ចសន្យា ។ ក៏ប៉ុន្តែនៅពេលខ្លះតម្លៃគឺមានភាពផ្លាស់ប្តូរ នៅស្ទើរតែគ្រប់ករណីតម្លៃអាចកើតឡើង។ នៅក្នុងករណីដែលវាត្រូវចំណាយពេលយូរ ចាប់តាំងពីការបង្កើតកិច្ចសន្យារហូតដល់ការអនុវត្តកាតព្វកិច្ច គូភាគីអាចគិតពិចារណាដល់ការប្រែប្រួលនៃតម្លៃ។ ដូច្នេះនៅក្នុងករណីនេះការប្រែប្រួលតម្លៃជាធម្មតាត្រូវចាត់ទុកថានៅក្នុងទំហំនៃការខូចខាតធម្មតា។

ផ្ទុយទៅវិញ ការឡើងថ្លៃខ្ពស់ដោយសារការ ផ្លាស់ប្តូរនៃលក្ខណៈសង្គម។ គេអាចនិយាយបានថាការប្រែ

---

[57] មាត្រា ៤០២ កថាខណ្ឌទី២ នៃក្រមរដ្ឋប្បវេណី ឆ្នាំ ២០០៧

[58] មាត្រា ៤០៤ នៃក្រមរដ្ឋប្បវេណី ឆ្នាំ ២០០៧

ប្រួលតម្លៃនេះអាចត្រូវបានកើតឡើងក្នុង កាលៈទេសៈពិសេសហើយវាត្រូវចាត់ទុកថាជាការខូចខាតពិសេស។ ដូច្នេះ ប្រសិនបើគូភាគី អាចព្យាករណ៍បាននូវការ ឡើងថ្លៃខ្ពស់នៃតម្លៃនេះនៅពេលបង្កើតកិច្ចសន្យានោះកូនបំណុលត្រូវតែសងសំណងនៃការខូចខាតដែលជាការខូចខាតពិសេសនេះ ។

ចំណុចដែលជាមូលដ្ឋាននៃពេលវេលា ថាតើពេលណាមួយដែលត្រូវចាត់ទុកថាជាចំណុចមូលដ្ឋាននៃការគណនាការខូចខាតមានគំនិតមួយចំនួនដែលអាចមាន។ មធ្យោបាយដែលជាបទដ្ឋានត្រឹមត្រូវបំផុត គឺជាចំណុចមូលដ្ឋាននៃពេលវេលាសម្រាប់គណនាគឺជាពេលនៃការមិនអនុវត្តកាតព្វកិច្ច ព្រោះម្ចាស់បំណុល ទទួលបានសិទ្ធិសម្រាប់សំណង នៃការខូចខាតនៅពេលដែល ការមិនអនុវត្តកាតព្វកិច្ចកើតឡើង។[59]

## ២.៣.៨ ការកំណត់ជាមុននូវសំណងការខូចខាត

ម្ចាស់បំណុល និង កូនបំណុល អាចកំណត់ជាមុននូវការសន្យាពិសេសអំពីលក្ខខណ្ឌ និង ចំនួនសំណងការខូចខាតបាន។[60] នៅពេលខ្លះ ការទទួលស្គាល់នូវទំហំនៃសំណងការខូចខាត ឬ ការគណនានៃសំណងការខូចខាតត្រូវ បានរកឃើញថាមានការលំបាក។ បើឈរលើទស្សនៈម្ចាស់បំណុល គឺវាហានិភ័យដែល ថាម្ចាស់បំណុលនឹងមិនអាច ទទួលបានសំណង ការខូចខាតគ្រប់គ្រាន់នោះទេ ផ្ទុយមកវិញបើតាមទស្សនៈរបស់កូនបំណុល គឺវាមានហានិភ័យដែលថាកូនបំណុល ត្រូវសងសំណងការខូចខាតជាមុននៅពេលដែលការ មិនអនុវត្តកាតព្វកិច្ចបានកើតមានឡើង។ នេះសំដៅទៅលើការកំណត់ជាមុននូវចំនួននៃសំណង។ ប្រសិនបើការកំណត់ជាមុននូវចំនួននៃសំណងត្រូវបានធ្វើឡើង ទោះបីជាបញ្ហានេះ ត្រូវបានយកទៅដោះស្រាយតាម ផ្លូវតុលាការក៏ដោយ ក៏ចំនួននៃសំណងដែលតុលាការត្រូវបង្គាប់ឱ្យកូនបំណុលសង ជាគោលការណ៍ គឺផ្អែកទៅលើចំនួនដែលបានព្រមព្រៀង និង មិនអាចផ្លាស់ប្តូរចំនួននោះបានដែរ។

### ២.៣.៨.១ លក្ខខណ្ឌនៃការកំណត់ជាមុននូវចំនួននៃសំណង

ប្រសិនបើការកំណត់ជាមុននូវចំនួនសំណងត្រូវបាន ព្រមព្រៀងដោយផ្អែកទៅលើកិច្ចសន្យានោះវាមានលក្ខណៈសំខាន់ណាស់ដែលការ មិនអនុវត្តកាតព្វកិច្ចត្រូវកើតមានឡើង ដើម្បីទាមទារសំណងនៃការខូចខាត។ ម្ចាស់បំណុលមិនចាំបាច់បង្ហាញពីកំហុសរបស់កូនបំណុលឡើយ ។

ប្រសិនបើការកំណត់ជាមុននូវចំនួនសំណងត្រូវបានកំណត់ជាក់លាក់តើកូនបំណុលអាចបង្ហាញថា ខ្លួនគ្មានកំហុស និង អាចរួចផុតពីការទទួលខុសត្រូវដែរ ឬ ទេ ចំណុចនេះមិនមានភាពច្បាស់លាស់ទេ នៅក្នុងមាត្រា ៤០៣ នៃក្រមរដ្ឋប្បវេណី ឆ្នាំ ២០០៧ ។ វាត្រូវបានគេចាត់ទុកថា បញ្ហានេះសម្រេចដោយផ្អែកទៅលើការព្រមព្រៀងពិសេស ដែលចែងអំពីការកំណត់ជាមុននូវចំនួននៃសំណង។ គេអាចធ្វើការទាមទារសំណងដែលត្រូវបាន

[59] សេចក្តីពន្យល់ អំពីក្រមរដ្ឋប្បវេណី ភាគទី១ ឆ្នាំ ២០១៣ ទំព័រ ១៧១

[60] មាត្រា ៤០៣ កថាខណ្ឌទី១ នៃក្រមរដ្ឋប្បវេណី ឆ្នាំ ២០០៧

កំណត់ជាមុន ដោយមិនគិតថាមានកំហុសនោះទេ ប្រសិនគោលគំនិតនៃការកំណត់នេះ គឺដើម្បីបង្ការនូវ វិវាទអំពីភាពមានកំហុស ឬ គ្មានកំហុសរបស់កូនបំណុល និង ដែលអាចឱ្យគេធ្វើការទាមទារចំនួនសំណងដែលកំណត់ជាមុនបាន។ ការព្រមព្រៀងបែបនេះ ត្រូវបានធ្វើឡើងនៅពេលដែលម្ចាស់បំណុលស្ថិតនៅក្នុងស្ថានភាពដែលមានអានុភាពជាង។ ក៏ប៉ុន្តែ ប្រសិនបើគោលបំណង នៃការព្រមព្រៀងពិសេស មិនមែនគ្រាន់តែដើម្បីបង្កើននូវចំនួននៃការទទួលខុសត្រូវរបស់កូនបំណុលនោះ កូនបំណុលមិនចាំបាច់បង់នូវសំណង ដែលត្រូវបានកំណត់ជាមុននោះទេ ប្រសិន បើកូនបំណុលបង្ហាញថាខ្លួនគ្មានកំហុស ដោយផ្អែកទៅលើគោលការណ៍ នៃការទទួលខុសត្រូវចំពោះការមិនអនុវត្តការព្វកិច្ច។ ប្រសិនបើខ្លឹមសារដែលបានព្រមព្រៀងនោះ មិនមានភាពច្បាស់លាស់ នោះគេអាចចាត់ទុកថាកូនបំណុល ត្រូវរួចផុតពីការទទួលខុសត្រូវប្រសិន បើភាពគ្មានកំហុសត្រូវបានបង្ហាញ ដោយស្របទៅនឹងគោលការណ៍ នៃការមិនអនុវត្តកាតព្វកិច្ច។

ផ្ទុយទៅវិញ នៅក្នុងករណីដែលម្ចាស់បំណុលស្ថិតនៅ ក្នុងស្ថានភាពមួយដែលងាយនឹងទទួលរងគ្រោះនោះគាត់នឹងប្រឈមមុខទៅ នឹងការបង្កើតការព្រមព្រៀងនៃការកំណត់ ជាមុននៃការខូចខាតដែលខូចផលប្រយោជន៍តែម្ខាង។ ដូច្នេះ ក្រមរដ្ឋប្បវេណី ឆ្នាំ ២០០៧ មាត្រា ៤០៣ កថាខណ្ឌទី២ បានកំណត់ថា ការសន្យាពិសេសដែលឱ្យកូនបំណុលរួចផុតជាមុន ពីការទទួលខុសត្រូវក្នុងការមិន អនុវត្តកាតព្វកិច្ចដោយចេតនា ឬ ដោយកំហុសដ៏ធ្ងន់ធ្ងររបស់ខ្លួន មិនមានអានុភាពឡើយ ដើម្បីផ្តល់ការការពារដល់ម្ចាស់បំណុល។

### ២.៣.៨.២ អានុភាពនៃការកំណត់ជាមុននូវចំនួននៃសំណង

ប្រសិនបើការកំណត់ជាមុននូវចំនួនសំណងត្រូវបានបង្កើតឡើង នោះជាគោលការណ៍តុលាការមិនអាចបន្ថយចំនួននៃសំណងដែលបានកំណត់ជាមុននោះទេ។[61] នេះគឺដោយសារតែទោះបីការខូចខាត មិនអាចត្រូវបានបង្ហាញយ៉ាងជាក់លាក់ក៏ដោយ ក៏ការព្រមព្រៀងដែលត្រូវបានធ្វើឡើង ដោយគូភាគីដែលបានកំណត់ពីចំនួននៃសំណង ដែលអាចទាមទារបាន ត្រូវបានគេគោរពដែរ។ ក៏ប៉ុន្តែប្រសិន បើចំនួន នៃសំណងដែលត្រូវបានកំណត់ជាមុន មានចំនួនច្រើនហួសហេតុ ឬ តិចហួសហេតុជាងការខូចខាតដែលត្រូវបានគណនាដោយពិតប្រាកដនោះ វាមិនមានភាពអយុត្តិធម៌ ឬ មិនត្រឹមត្រូវតាមច្បាប់ដែលតុលាការបង្គាប់ឱ្យសងនូវចំនួននៃការសងការខូចខាត ដែលត្រូវបានកំណត់ជាមុននោះ ដូច្នេះតុលាការអាចបន្ថយ ឬបន្ថែមនូវចំនួននៃសំណង ដែលបានកំណត់ជាមុននោះ។[62] វាមិនបានកំណត់ច្បាស់លាស់នៅក្នុងក្រមនេះ (ក្រមរដ្ឋប្បវេណីឆ្នាំ ២០០៧) ទេថាតើត្រឹមទំហំណា ដែលចំនួននោះអាចបន្ថែម ឬ បន្ថយ នៅក្នុងករណីដែលវាច្រើនហួសហេតុ ឬ តិចហួសហេតុនេះ វាមានលក្ខណៈត្រឹមត្រូវដោយចាត់ទុកចំនួនដែលអាចត្រូវបានបន្ថែម ឬ បន្ថយនោះ មិនមែនជាទំហំនៃការខូចខាត

[61] មាត្រា ៤០៣ កថាខណ្ឌទី៣ នៃក្រមរដ្ឋប្បវេណី ឆ្នាំ ២០០៧

[62] មាត្រា ៤០៣ កថាខណ្ឌទី៣ វាក្យខណ្ឌទី២ នៃក្រមរដ្ឋប្បវេណី ឆ្នាំ ២០០៧

ពិតប្រាកដ ប៉ុន្តែវាគឺជាចំនួន សមរម្យមួយដោយពិចារណាទៅ លើការខូចខាតពិតប្រាកដ។

**២.៣.៨.៣ ប្រាក់ធានាសំណងនៅក្នុងករណីបំពានកិច្ចសន្យា និង ការកំណត់ជាមុននូវចំនួននៃសំណង**

ប្រាក់ធានាសំណង ក្នុងករណីបំពានកិច្ចសន្យា ត្រូវសន្មតថាជាការកំណត់ ជាមុននូវចំនួននៃសំណង។[63] ប្រាក់ធានាសំណងក្នុងករណីបំពានកិច្ចសន្យា មានន័យថា នៅក្នុងករណីដែលភាគីបំពានកិច្ចសន្យា គាត់ត្រូវសងជាប្រាក់ក្រៅ ពីសំណងនៃការខូចខខាត ដោយផ្អែកលើការព្រមព្រៀង។ ដូចដូច្នេះ ភាគីដែលបានបំពានកិច្ចសន្យា ត្រូវទទួលខុសត្រូវ ចំពោះការមិនអនុវត្តកាតព្វកិច្ចទោះបីជា គាត់បានបង់ប្រាក់ធានាសំណងនៅក្នុងករណីបំពានកិច្ចសន្យាក៏ដោយ។ វាជាការលំបាកក្នុងការកំណត់ការបញ្ជាក់ពីចំនួន ទឹកប្រាក់នៃការខូចខាត នៅក្នុងករណីមួយចំនួន។ ក៏ប៉ុន្តែ ប្រសិនបើមានការព្រៀងជាមុនអំពីសំណងការខូចខាត ម្ចាស់បំណុលអាចចៀសវាងពីការលំបាកនោះបាន។ ម្យ៉ាងទៀតចំពោះកូនបំណុល ប្រសិនបើមានការព្រមព្រៀងអំពីចំនួននៃសំណងការខូចខាតសមហេតុផលជាមុន ក៏អាចមានលទ្ធភាពត្រៀម ខ្លួនចំពោះការសងសំណងនេះ ហើយគាត់មិនចាំបាច់បារម្ភថា តើតុលាការដាក់បន្ទុកឱ្យសងសំណងចំនួនប៉ុន្មានដែរ។

ក្រៅពីចំនួន នៃសំណងការខូចខាត ភាគីទាំងពីរ ក៏អាចបង្កើតការសន្យាពិសេសអំពីលក្ខខណ្ឌនៃការទទួលខុសត្រូវក្នុងការសងសំណងការខូចខាតបានដែរ។

ក្នុងករណីដែលភាគីទាំងសងខាងបានធ្វើការសន្យាពិសេសអំពីចំនួននៃសំណងការខូចខាត តុលាការមិនអាចបន្ថែម ឬ បន្ថយចំនួននោះបានទេ។ ដោយហេតុថា បញ្ញត្តិនេះមានគោលបំណងជៀសវាងនូវវិវាទដែលមិនចាំបាច់ទៅលើ ទំហំនៃការខូចខាតនោះ តុលាការមិនត្រូវបានអនុញ្ញាតឱ្យធ្វើការផ្លាស់ប្តូរទំហំនៃការខូចខាតនេះ នៅក្នុងករណីដែលរឿងក្តីនេះត្រូវបានដាក់បញ្ជូនទៅតុលាការ។

**២.៣.៩ ឧបាទេសកម្មនៃអ្នកសង**

ប្រសិនបើម្ចាស់បំណុលបានទទួលនូវសំណង នៃការខូចខាតដោយការសងតម្លៃនៃវត្ថុឬ សិទ្ធិដែលជាអត្ថន័យនៃសិទ្ធិលើបំណុលកូនបំណុលត្រូវទទួលឋានៈដែលម្ចាស់បំណុលធ្លាប់មានចំពោះវត្ថុ ឬ សិទ្ធិនោះដោយស្វ័យប្រវត្តិ។[64] ឧបាទេសកម្មនៃអ្នកសង គឺដើម្បីផ្តល់នូវសមភាពនៃផលប្រយោជន៍រវាងភាគីដែលសងសំណងការខូចខាត និងភាគីដែលទទួលសំណងការខូចខាត។ ឧទាហរណ៍៖ ករណីដែល ក បានផ្ញើថូរបុរាណមួយនៅ ខ ប៉ុន្តែ ខ បានធ្វើឱ្យបែកថូរនោះ ដោយកំហុស។ នៅក្នុងករណីនេះ ខ ត្រូវសងសំណងការខូចខាត។ ហើយនៅពេលដែល ក ទទួលបានសំណងជាទឹកប្រាក់ស្មើរតម្លៃថូរបុរាណនោះ ខ ត្រូវទទួលបានកម្មសិទ្ធិលើថូរបែក ។

[63] មាត្រា ៤០៣ កថាខណ្ឌទី៥ នៃក្រមរដ្ឋប្បវេណី ឆ្នាំ ២០០៧

[64] មាត្រា ៤០៥ នៃក្រមរដ្ឋប្បវេណី ឆ្នាំ ២០០៧

ខ អាចយកថូរដែលបែកនេះ ទៅជួសជុល និង ធ្វើជាកម្មសិទ្ធិករនៃថូរនេះ។

ទន្ទឹមនឹងនេះផងដែរ នៅក្នុងករណីដែលថូរបុរាណដែលត្រូវបានគេផ្ញើនេះ ត្រូវបាន គ លួចយកទៅបាត់ ព្រោះ ខ មិនបានចាក់សោរទុកស្រួលបួល។ នៅក្នុងករណីនេះ ខ ត្រូវទទួលបានសិទ្ធិទាមទារឱ្យ គ ប្រគល់ថូរបុរាណនោះមកវិញ ដោយផ្អែកលើការបំពានកម្មសិទ្ធិ ព្រោះ ខ ធ្វើឧបាទេសកម្មលើកម្មសិទ្ធិលើរបស់ ក ហើយ។

### ២.៣.១០ អាជ្ញាយុកាលនៃការរំលត់សិទ្ធិទាមទារសំណង

អាជ្ញាយុកាលនៃការរំលត់សិទ្ធិទាមទារឱ្យសងការខូចខាតដោយសារការមិនអនុវត្តកាតព្វកិច្ច មានអំឡុងពេល ៥ (ប្រាំ) ឆ្នាំ ក្រោយពេលដែលការខូចខាតនោះបានកើតឡើង។[65]

នៅពេលដែលការមិនអនុវត្តកាតព្វកិច្ចណាមួយកើតឡើងម្ចាស់បំណុលអាចអនុវត្តវិធីនៃការសង្គ្រោះជាច្រើន ដូចជា ការអនុវត្តកាតព្វកិច្ចដោយបង្ខំ ការទាមទារសំណងការខូចខាត និង ការរំលាយកិច្ចសន្យាជាអាទិ៍។ ចំពោះវិធីសង្គ្រោះនីមួយៗអំឡុងពេលនៃអាជ្ញាយុកាល ចាំបាច់ត្រូវពិចារណា ។ អាជ្ញាយុកាល នៃការរំលត់សិទ្ធិលើបំណុល សំដៅទៅលើការ រលត់សិទ្ធិលើបំណុលដោយផ្អែកលើកាលដែលម្ចាស់បំណុលមិនអនុវត្តសិទ្ធិ ក្នុងអំឡុងពេលដែលត្រូវបានកំណត់។[66] អំឡុងពេលនៃអាជ្ញាយុកាល អាចត្រូវបានចាប់គិតពីពេលដែល មានការមិនអនុវត្តកាតព្វកិច្ច ប៉ុន្តែវាគួរតែគិតបន្ទាប់ពីការចាប់ផ្តើមកើតមានការខូចខាតដោយហេតុថា ភាគីណាម្នាក់អាចទាមទារ។

ដូច្នេះនៅក្នុងករណីដែលសិទ្ធិទាមទារសំណងនៃការខូចខាតដោយសារការមិនអនុវត្តកាតព្វកិច្ច អំឡុងពេលនៃអាជ្ញាយុកាលរំលត់ ត្រូវបានចាប់ផ្តើមគិតនៅពេលដែលការខូចខាតកើតឡើង មិនមែននៅពេលដែលការមិនអនុវត្ត កើតឡើងនោះទេ។

## ២.៤ ការរំលាយកិច្ចសន្យា

ការរំលាយកិច្ចសន្យាជាមធ្យោបាយចុងក្រោយ សម្រាប់ធ្វើការដោះស្រាយ នៅពេលដែលភាគីម្ខាងមិនព្រមអនុវត្តកាតព្វកិច្ច ការរំលាយកិច្ចសន្យា ជាទណ្ឌកម្មមួយ ដែលត្រូវបានបង្កើតឡើងដោយ សារភាគីម្ខាង បានបំពាននូវកាតព្វកិច្ចនៃកិច្ចសន្យា។ ភាគីម្ខាងនៃកិច្ចសន្យាអញ្ញមញ្ញ (កិច្ចសន្យាដែលមានបន្ទុកបំពេញនូវកាតព្វកិច្ចទៅវិញទៅមក) អាចរំលាយកិច្ចសន្យាបានភ្លាមៗ នៅករណីដែលភាគីម្ខាងទៀត បានបំពានលើកិច្ចសន្យាយ៉ាងធ្ងន់ធ្ងរ។

### ២.៤.១ ប្រភេទនៃសិទ្ធិរំលាយកិច្ចសន្យា

ការរំលាយកិច្ចសន្យា សំដៅទៅលើសកម្មភាពឯកតោភាគី ដែលធ្វើឱ្យភាគីទាំងសងខាងរួចផុតពីករណី

[65] មាត្រា ៤០៦ នៃក្រមរដ្ឋប្បវេណី ឆ្នាំ ២០០៧

[66] មាត្រា ៤៨០ នៃក្រមរដ្ឋប្បវេណី ឆ្នាំ ២០០៧

កិច្ចរបស់ខ្លួននៅក្នុងកិច្ចសន្យា លើកលែងតែករណីកិច្ចសងការខូចខាត។[67] ការរំលាយកិច្ចសសន្យាអាចធ្វើឱ្យមានអានុភាពជាឯកតោភាគី ហើយមិនចាំបាច់មាន ការព្រមព្រៀងពីភាគី ម្ខាងទៀងទេ ព្រោះវាជាសកម្មភាពឯតោភាគី។[68] ប្រភេទនៃសិទ្ធិរំលាយកិច្ចសន្យាមានដូចជា៖ សិទ្ធិរំលាយកិច្ចសន្យាដែលបានកំណត់នៅក្នុងច្បាប់ សិទ្ធិរំលាយកិច្ចសន្យាដែលបានកំណត់ នៅក្នុងកិច្ចសន្យា និងសិទ្ធិរំលាយកិច្ចសន្យាដោយផ្អែកលើបទបញ្ញត្តិពិសេស។

### ២.៤.១.១ ប្រភេទសិទ្ធិរំលាយកិច្ចសន្យាដែលបានកំណត់នៅក្នុងច្បាប់

សិទ្ធិរំលាយកិច្ចសន្យា ដែលត្រូវបានកំណត់នៅក្នុងច្បាប់ត្រូវបាន បញ្ញត្តិឡើងដោយ មាត្រា ៤០៧ ដល់មាត្រា ៤១៣ នៃក្រមរដ្ឋប្បវេណី ឆ្នាំ ២០០៧។ ឧទាហរណ៍៖ ក្នុងករណីដែល ក មិនបានប្រគល់នូវកម្មវត្ថុក្នុងអំឡុងពេលសមរម្យ នៅក្រោយកាលបរិច្ឆេទ ទោះបីជាមានការដាស់តឿនរបស់ ខ នោះ ខ អាចលើកឡើងពីការរំលាយកិច្ចសន្យាបាន។ នៅក្នុងករណីនេះ ការរំលាយកិច្ចសន្យា របស់ ខ ត្រូវអនុវត្ត ដោយផ្អែកលើបញ្ញត្តិនៃមាត្រា ៤០៨ កថាខណ្ឌទី១ ចំណុច ក នៃក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧។

### ២.៤.១.២ សិទ្ធិរំលាយកិច្ចសន្យាដែលបានកំណត់នៅក្នុងកិច្ចសន្យា

សិទ្ធិរំលាយកិច្ចសន្យា ដែលបានកំណត់ក្នុងកិច្ចសន្យា គឺជាសិទ្ធិរំលាយកិច្ចសន្យា ដែលភាគីម្ខាង ឬសងខាង អាចរំលាយកិច្ចសន្យាបាន ដោយផ្អែកកិច្ចសន្យានោះផ្ទាល់តែម្តង។ ឧទាហរណ៍៖ ប្រសិនបើភាគីបានធ្វើការព្រមព្រៀងគ្នានៅក្នុងកិច្ចសន្យា មិនថាអ្នកលក់ ឬអ្នកទិញនោះទេ គឺអាចរំលាយកិច្ចសន្យាជាឯកតោភាគីនៅពេលណាក៏បាន ក្នុងរយៈពេល ១ ខែ ក្រោយពេលប្រគល់វត្ថុ ដូច្នេះ អ្នកទិញអាចរំលាយកិច្ចសន្យាបានតាមលក្ខខណ្ឌដែលមានចែងនៅពេលបង្កើតកិច្ចសន្យានោះផ្ទាល់តែម្តង។

អានុភាព ឬ វិធីក្នុងការអនុវត្តសិទ្ធិរំលាយកិច្ចសន្យា គឺត្រូវអនុវត្តដូចគ្នា ទៅនឹងសិទ្ធិរំលាយកិច្ចសន្យាដែលបានកំណត់នៅក្នុងច្បាប់ លើកលែងតែភាគីបានព្រមព្រៀងគ្នាផ្សេងពីនេះ។[69]

### ២.៤.១.៣ សិទ្ធិរំលាយកិច្ចសន្យាដែលផ្អែកលើបញ្ញត្តិពិសេស

បញ្ញត្តិមួយចំនួននៅក្នុងកិច្ចសន្យាសំខាន់ៗ បានចែងអំពីសិទ្ធិរំលាយកិច្ចសន្យាពិសេសនៅក្នុងកិច្ចសន្យានីមួយៗ តែម្តង ដែលមានដូចជា៖

- បញ្ញត្តិមាត្រា ៦៤៧ នៃក្រមរដ្ឋប្បវេណី ឆ្នាំ ២០០៧ ទាក់ទងនឹងការរំលាយកិច្ចសន្យាអាណិត្តបានចែងថា ភាគីនីមួយៗ អាចរំលាយកិច្ចសន្យាអាណិត្តនៅពេលណាក៏បាន។

[67] មាត្រា ៤១១ កថាខណ្ឌទី១ នៃក្រមរដ្ឋប្បវេណី ឆ្នាំ ២០០៧

[68] មាត្រា ៣១២ នៃក្រមរដ្ឋប្បវេណី ឆ្នាំ ២០០៧

[69] មាត្រា ៤១៤ កថាខណ្ឌទី១ នៃក្រមរដ្ឋប្បវេណី ឆ្នាំ ២០០៧

❖ បញ្ញត្តិមាត្រា ៦៦៣ នៃក្រមរដ្ឋប្បវេណី ឆ្នាំ ២០០៧ ទាក់ទងនឹងការរំលាយកិច្ចសន្យាម៉ៅការ បានចែងថា ម្ចាស់ការអាចរំលាយកិច្ចសន្យា នៅពេលណាក៏បាន ដោយសងសំណងនៃការខូចខាតរហូតដល់ពេលដែលអ្នកម៉ៅការ បានសម្រេចការងារ។

ការរំលាយកិច្ចសន្យាដែលផ្អែកលើ បញ្ញត្តិពិសេសនេះ នឹងត្រូវបានលើកយកមកសិក្សាលម្អិត នៅពេលសិក្សាពីកិច្ចសន្យាសំខាន់ៗ នោះតែម្តង។

**២.៤.២ ប្រព័ន្ធប្រហាក់ប្រហែលនឹងការរំលាយកិច្ចសន្យា**

ប្រព័ន្ធមួយចំនួន ដែលមានលក្ខណៈស្រដៀងគ្នាទៅនឹងការរំលាយកិច្ចសន្យា ប៉ុន្តែវាមិនមែនជាការរំលាយកិច្ចសន្យាទេ ។ ប្រពន្ធប្រហាក់ប្រហែលនឹងការរំលាយកិច្ចសន្យា មានចំនួនពីរ ប្រភេទ៖

- ការរំលាយកិច្ចសន្យាដោយការព្រមព្រៀង
- ការលុបចោលកិច្ចសន្យា។

**២.៤.២.១ ការរំលាយកិច្ចសន្យាដោយការព្រមព្រៀង**

ការរំលាយកិច្ចសន្យាដោយការព្រមព្រៀង មានន័យថាជាការរំលាយកិច្ចសន្យា ដោយផ្អែកលើការព្រមព្រៀងថ្មីរបស់គូរភាគី នៅក្នុងករណីដែលភាគីមិនបានចែងអំពីការរំលាយកិច្ចសន្យានេះក្នុងកិច្ចសន្យារបស់ខ្លួន។ ឧទាហរណ៍៖ ភាគី ក បានលក់ម៉ូតូឱ្យភាគី ខ តែបន្ទាប់មក ខ បានជួបបញ្ហាសេដ្ឋកិច្ចដែលធ្វើឱ្យ ខ មិនមានប្រាក់គ្រប់គ្រាន់ដើម្បីប្រគល់ឱ្យ ក ហើយ ខ ក៏បានសុំ ក រំលាយកិច្ចសន្យានោះចោល ដោយសារការអាណិត ក ក៏បានយល់ព្រម។ នៅក្នុងករណីនេះ ភាគីទាំងពីរបានព្រមព្រៀងគ្នាដើម្បីបង្កើតកិច្ចសន្យាថ្មីដើម្បីរំលាយកិច្ចសន្យាចាស់ចោល។

ការរំលាយកិច្ចសន្យា ដោយការព្រមព្រៀងនេះ មានអានុភាពខុសពីការរំលាយកិច្ចសន្យាដែលបានកំណត់នៅក្នុងច្បាប់ ដោយសារភាគីដែលចង់រំលាយកិច្ចសន្យា មិនអាចបង្ហាញឆន្ទៈឯកតោភាគីឡើយ ដាច់ខាតត្រូវតែមានការយល់ព្រមពីភាគីម្ខាងទៀតនៃ កិច្ចសន្យា។ ហើយវាក៏មានលក្ខណៈខុសពី ការរំលាយកិច្ចសន្យាដែលបានកំណត់នៅក្នុងកិច្ចសន្យា ដែលត្រូវតែអនុវត្ត ដោយផ្អែកលើលក្ខខណ្ឌដែលបានកំណត់នៅក្នុងកិច្ចសន្យាផងដែរ។

**២.៤.២.២ ការលុបចោលកិច្ចសន្យា**

ក្នុងករណីដែលកិច្ចសន្យាត្រូវបានលុបចោល នោះកិច្ចសន្យាត្រូវបានចាត់ទុកជាមោឃៈតាំងពីដំបូង។[70] ការលុបចោលកិច្ចសន្យា និងការរំលាយកិច្ចសន្យាមានចំណុច ដូចគ្នានិងចំណុចខុសគ្នាមួយចំនួនដូចជា៖

[70] មាត្រា ៣៥៨ កថាខណ្ឌទី២ នៃក្រមរដ្ឋប្បវេណី ឆ្នាំ ២០០៧

- **ចំណុចដែលដូចគ្នា**
  - ភាគីទាំងសងខាង ត្រូវបានរួចផុតពីកាតព្វកិច្ច
  - ជាសកម្មភាពឯកតោភាគី
- **ចំណុចដែលខុសគ្នា**
  - ការរំលាយកិច្ចសន្យា កើតមកពីមូលហេតុការបំពានកិច្ចសន្យាធ្ងន់ធ្ងររបស់ភាគី
  - ការលុបចោលកិច្ចសន្យា កើតមកពីវិការៈនៃការព្រមព្រៀង (ការឆបោក ឬការបង្ខិតបង្ខំជាអាទិ៍)។

### ២.៤.៣ លក្ខខណ្ឌនៃការរំលាយកិច្ចសន្យា

ភាគីម្ខាងនៃកិច្ចសន្យាអញ្ញមញ្ញ អាចរំលាយកិច្ចសន្យាបានភ្លាមៗ ក្នុងករណីដែល ភាគីម្ខាងទៀត បំពានកិច្ចសន្យាយ៉ាងធ្ងន់ធ្ងរ។[71]

ដូចនេះ លក្ខខណ្ឌនៃការរំលាយកិច្ចសន្យា ដោយមូលហេតុមិនអនុវត្តកាតព្វកិច្ច មានចំនួនពីរគឺ៖

- ក្នុងកិច្ចសន្យាទ្វេភាគី
- ភាគីម្ខាងបានបំពានកិច្ចសន្យាយ៉ាងធ្ងន់ធ្ងរ។

ភាគីដែលបំពានកិច្ចសន្យា មិនអាចរារាំងការរំលាយកិច្ចសន្យាដោយយកមូលហេតុថា ខ្លួនគ្មានកំហុសចំពោះការមិនអនុវត្តកាតព្វកិច្ចរបស់ខ្លួន បានឡើយ។[72]

ដូច្នេះ មានភាពខុសគ្នាពីករណីនៃសំណងនៃការខូចខាត ដោយការរំលាយកិច្ចសន្យា ដែលមិនតម្រូវឱ្យមានកំហុសរបស់កូនបំណុលទេ។

ការបំពានកិច្ចសន្យាយ៉ាងធ្ងន់ធ្ងរ សំដៅទៅលើករណីដែលភាគីម្ខាង មិនអាចសម្រេចគោលបំណងនៃកិច្ចសន្យាបាន ដោយសារការបំពានរបស់ភាគីម្ខាងទៀត។[73]

**ត្រូវចាត់ទុកថាមានការបំពានកិច្ចសន្យាយ៉ាងធ្ងន់ធ្ងរ ក្នុងករណីដែលដូចជា៖**

- ការយឺតយ៉ាវក្នុងការអនុវត្តកាតព្វកិច្ច
- អលទ្ធភាពក្នុងការអនុវត្តកាតព្វកិច្ចចំពោះពេលវេលា
- អលទ្ធភាពក្នុងការអនុវត្តកាតព្វកិច្ច
- ការបាត់បង់ទំនុកចិត្តរវាងភាគី

[71] មាត្រា ៤០៧ នៃក្រមរដ្ឋប្បវេណី ឆ្នាំ ២០០៧

[72] មាត្រា ៤០៧ នៃក្រមរដ្ឋប្បវេណី ឆ្នាំ ២០០៧

[73] មាត្រា ៤០៨ កថាខណ្ឌទី២ នៃក្រមរដ្ឋប្បវេណី ឆ្នាំ ២០០៧

ចំណុចផ្សេងក្រៅពីការបំពានកិច្ចសន្យា យ៉ាងធ្ងន់ធ្ងរទាំងបួនខាងលើនេះ តុលាការ អាចទទួលស្គាល់ថាមានការបំពានកិច្ចសន្យាយ៉ាងធ្ងន់ធ្ងរដែលអាស្រ័យទៅតាមស្ថានការណ៍ជាក់ស្តែង។

**២.៤.៣.១ ការយឺតយ៉ាវក្នុងការអនុវត្តកាតព្វកិច្ច**

ភាគីម្ខាងបានដាស់តឿនភាគីម្ខាងទៀត ដែលមិនបានអនុវត្តកាតព្វកិច្ច តាមពេលកំណត់ដោយដោយកំណត់អំឡុង ពេលសមរម្យដើម្បីអនុវត្តកាតព្វកិច្ច ហើយកាតព្វកិច្ចមិនត្រូវបានអនុវត្តក្នុងអំឡុងពេលនោះ។[74]

**ដូនេះ លក្ខខណ្ឌនៃការមិនអនុវត្តកាតព្វកិច្ច មានលក្ខខណ្ឌចំនួន ៣ គឺ៖**

- កូនបំណុលមិនអនុវត្តកាតព្វកិច្ចរបស់ខ្លួន តាមពេលកំណត់
- ម្ចាស់បំណុលដាស់តឿនកូនបំណុលដែលមិនអនុវត្តកាតព្វកិច្ចឱ្យអនុវត្តក្នុងអំឡុងពេលសមរម្យ។
- កូនបំណុល មិនអនុវត្តកាតព្វកិច្ច ក្នុងអំឡុងពេលសមរម្យ។ ឧទាហរណ៍៖ ក បានទិញម៉ូតូពី ខ ដោយ ខ បានប្រគល់ម៉ូតូឱ្យ ក រួចរាល់ហើយ ប៉ុន្តែ ក មិនទាន់បានប្រគល់ប្រាក់ឱ្យ ខ តាមពេលកំណត់ទេ បន្ទាប់មកទៀត ខ បានកំណត់អំឡុងពេលសមរម្យដើម្បីឱ្យ ក ប្រគល់ប្រាក់ តែ ក នៅតែមិនបានប្រគល់ប្រាក់ឱ្យ ខ ដដែល។ នៅក្នុងករណីនេះ ខ អាចរំលាយកិច្ចសន្យាបាន ដោយហេតុថា ក មានការយឺតយ៉ាវក្នុងការអនុវត្តកាតព្វកិច្ច។

**២.៤.៣.២ អលទ្ធភាពក្នុងការអនុវត្តកាតព្វកិច្ចចំពោះពេលវេលា**

ភាគីដែលមិនបានអនុវត្តកាតព្វកិច្ច តាមពេលវេលា កំណត់ក្នុងកិច្ចសន្យា ក្នុងករណីដែលគោលបំណងនៃកិច្ចសន្យាមិនបានសម្រេចសោះបើភាគីមិនអនុវត្តកាតព្វកិច្ចតាមពេលកំណត់នោះ។[75] ឧទាហរណ៍៖ ក បានទៅកាត់សំលៀកបំពាក់ សម្រាប់ថ្ងៃខួបកំណើតរបស់ខ្លួនដោយកំណត់មុនថ្ងៃខួបកំណើតរបស់ខ្លួនមួយថ្ងៃ គឺនៅថ្ងៃទី ២៥ ខែ តុលា ឆ្នាំ ២០១៧ ប៉ុន្តែជាងកាត់ដេរសម្លៀកបំពាក់ខកខានមិនបានធ្វើតាមពេលកំណត់។ ក្នុងករណីនេះ ក មានសិទ្ធិរំលាយកិច្ចសន្យាបាន ដោយហេតុថា ក គ្មានអត្ថប្រយោជន៍ក្នុងការទទួលយកការអនុវត្តកាតព្វកិច្ច ក្រោយពេលខួបកំណើតនោះទេ។

**២.៤.៣.៣ អលទ្ធភាពក្នុងការអនុវត្តកាតព្វកិច្ច**

ភាគីមិនអាចអនុវត្តករណីកិច្ច ផ្តល់តាវកាលិកចម្បងរបស់ខ្លួនបានទេ។[76] តាវកាលិក ចម្បងគឺជាសកម្មភាពដែលភាគី មិនអាចសម្រេចគោលបំណងនៃកិច្ចសន្យា ប្រសិនបើ តាវកាលិកនោះ មិនត្រូវបានផ្តល់ឱ្យ។

---

[74] មាត្រា ៤០៨ កថាខណ្ឌទី១ ចំណុច ក នៃក្រមរដ្ឋប្បវេណី ឆ្នាំ ២០០៧

[75] មាត្រា ៤០៨ កថាខណ្ឌទី១ ចំណុច ខ នៃក្រមរដ្ឋប្បវេណិ ឆ្នាំ ២០០៧

[76] មាត្រា ៤០៨ កថាខណ្ឌទី១ ចំណុច គ នៃក្រមរដ្ឋប្បវេណី ឆ្នាំ ២០០៧

តាវកាលិកចម្បង ត្រូវសម្រេចដោយផ្អែកលើលក្ខខណ្ឌ ឬខ្លឹមសារនៃកិច្ចសន្យានិងឆន្ទៈរបស់ភាគី។ ឧទាហរណ៍៖ ក បានទិញម៉ូតូពី ខ ដោយបានប្រគល់ប្រាក់រួចរាល់ហើយ ប៉ុន្តែ មុនពេលប្រគល់ម៉ូតូនោះ មានទឹកជំនន់ បានធ្វើឱ្យមានការខូចខាតម៉ាស៊ីនរបស់ម៉ូតូ។ នៅក្នុងករណីនេះទោះបី ជាម៉ូតូស្ថិតនៅក្នុងសភាពដើមក៏ដោយ ក៏កាតព្វកិច្ចក្លាយជាអលទ្ធភាពដែរ ពីព្រោះ ក មិនពីព្រោះ ក មិនអាចប្រើម៉ូតូដែលខូចម៉ាស៊ីននោះទេ។ ដូច្នេះ ក អាចរំលាយកិច្ចសន្យាលក់ទិញនោះបាន ដោយហេតុថា ខ មិនអាចប្រគល់ម៉ូតូ ដែលជាតាវកាលិកចម្បងនៃកិច្ចសន្យា។

នៅក្នុងករណីដែលមានតាវកាលិកបន្ទាប់បន្សំ រួចជាមួយតាវកាលិកចម្បង នោះម្ចាស់បំណុលមិនអាចរំលាយកិច្ចសន្យាដោយសារតែកូនបំណុលមិនអនុវត្តកាតព្វកិច្ចបន្ទាប់បន្សំនោះទេ។ ឧទាហរណ៍៖ ក បានទិញទូរស័ព្ទពី ខ ដោយ ក បានប្រគល់ប្រាក់រួចរាល់ហើយ ចំណែកឯ ខ ក៏បានប្រគល់ទូរស័ព្ទឱ្យផងដែរ តែ ខ មិនបានប្រគល់ប្រដាប់បញ្ចូលភ្លើងទូរស័ព្ទទេ។ នៅក្នុងករណីនេះប្រដាប់បញ្ចូលភ្លើងទូរស័ព្ទ គឺជាកាតព្វកិច្ចបន្ទាប់បន្សំ ដូច្នេះ ក មិនអាចរំលាយកិច្ចសន្យានេះបានទេ ដោយផ្អែកលើមូលហេតុមិនអនុវត្តកាតព្វកិច្ច។

#### ២.៤.៣.៤ ការបាត់បង់ទំនុកចិត្តរវាងភាគី

ការបំពានកិច្ចសន្យាមានភាពហួសហេតុ ដែលធ្វើឱ្យបាត់បង់ទំនុកចិត្តរវាងគូភាគី ហើយមិនអាចជឿជាក់ថា នឹងអនុវត្តកាតព្វកិច្ចនាអនាគត។[77]

ចំពោះការរំលាយកិច្ចសន្យាប្រភេទនេះ មានភាពមិនច្បាស់លាស់ទេ។ ទំនុកចិត្តរវាងគូភាគីចាំ ចាំបាច់មានខ្លាំងនៅក្នុងកិច្ចសន្យាមួយចំនួនដូចជា កិច្ចសន្យាលក់ទិញបន្តបន្ទាប់ កិច្ចសន្យាម៉ៅការកិច្ច សន្យាជួល ជាអាទិ៍ដែលជាប្រភេទកិច្ចសន្យាដែលគូភាគីត្រូវអនុវត្តជាបន្តបន្ទាប់ ក្នុងអំឡុងពេលវែង។ ឧទាហរណ៍៖ ក ជាអ្នកលក់ទឹកអំពៅ ដែលទិញអំពៅពី ខ ដោយគូភាគីទាំងពីរបានព្រមព្រៀងគ្នាថា ខ ត្រូវតែប្រគល់អំពៅឱ្យ ក ក្នុងមួយសប្តាហ៍ម្តងរាល់ព្រឹកថ្ងៃ សៅរ៍ ម៉ោង ៦ ព្រឹក។ ដោយជារឿយៗ ខ ប្រគល់អំពៅយឺត ១ ទៅ ២ ម៉ោង ដែលជាហេតុធ្វើឱ្យ ក មិនបានលក់ក្នុងអំឡុងពេលយឺតនោះជាញឹកញាប់ផងដែរ។ វាជាការលំបាកដែល ក អាចរក្សាទំនុកចិត្តជាមួយ ខ ទោះបីជាការយឺតយ៉ាវម្តងៗមិនមានលក្ខណៈធ្ងន់ធ្ងរក៏ដោយ។ ដូច្នេះ ក អាចរំលាយកិច្ចសន្យាដោយលារការបាត់បង់ទំនុកចិត្តទៅលើ ខ ។

### ២.៤.៤ វិធីអនុវត្តសិទ្ធិរំលាយកិច្ចសន្យា

ភាគីដែលមានសិទ្ធិរំលាយកិច្ចសន្យា អាចរំលាយកិច្ចសន្យាដោយបង្ហាញ ឆន្ទៈរំលាយកិច្ចសន្យាចំពោះភាគីម្ខាងទៀត។ ការរំលាយកិច្ចសន្យានេះអាចធ្វើឡើងក្រៅតុលាការបាន។[78] ការរំលាយកិច្ចសន្យាត្រូវធ្វើឡើង

[77] មាត្រា ៤០៨ កថាខណ្ឌទី១ ចំណុច ឃ នៃក្រមរដ្ឋប្បវេណី ឆ្នាំ ២០០៧

[78] មាត្រា ៤០៩ នៃក្រមរដ្ឋប្បវេណី ឆ្នាំ ២០០៧

ដោយការបង្ហាញឆន្ទៈរំលាយ ស្របតាមគោលការណ៍ ទូទៅនៃការបង្ហាញឆន្ទៈ ការបង្ហាញឆន្ទៈរំលាយនេះត្រូវមាន អានុភាពនៅពេលដែលការបង្ហាញឆន្ទៈនេះបានដល់ភាគីម្ខាង ទៀត។ ហើយការបង្ហាញឆន្ទៈ រំលាយកិច្ចសន្យានេះអាចធ្វើឡើងក្រៅតុលាការបាន ដោយហេតុថាវាធ្វើឱ្យ មានបន្ទុកកាន់តែធ្ងន់សម្រាប់តុលាការ និងជាការលំបាកសម្រាប់គូភាគីដែលត្រូវសុំឱ្យតុលាការចេញសេចក្ដីសម្រេចនៅគ្រប់ពេលដែលភាគីម្ខាងមានបំណងរំលាយកិច្ចសន្យាម្យ៉ាងវិញទៀតប្រសិនបើភាគីម្ខាងមិនព្រមទទួលការរំលាយកិច្ចសន្យានោះ ភាគីដែលបានរំលាយ កិច្ចសន្យានោះ នឹងប្ដឹងទៅតុលាការដើម្បីចេញសេចក្ដីសម្រេច។

ការបង្ហាញឆន្ទៈរំលាយកិច្ចសន្យានេះ មិនអាចដកវិញបានទេ។ មិនអនុញ្ញាត ឱ្យដកការបង្ហាញឆន្ទៈរំលាយកិច្ចសន្យាបានទេដោយហេតុថា អាចកើតឡើងនូវភាពច្របូកច្របល់ដែលមិនចាំបាច់ ប្រសិនបើអនុញ្ញាតឱ្យមានការដក និង កិច្ចសន្យាដែលត្រូវបានរំលាយហើយនោះ ប្រែក្លាយទៅជាមានអានុភាពឡើងវិញ។ ប៉ុន្តែគោលការណ៍ទូទៅនៃការបង្ហាញឆន្ទៈត្រូវយកអនុវត្ត ចំពោះការបង្ហាញឆន្ទៈរំលាយកិច្ចសន្យា ហេតុដូច្នេះ ហើយការរំលាយកិច្ចសន្យាដែលធ្វើឡើងដោយជនដែលត្រូវបានកម្រិតសមត្ថភាពក្នុងធ្វើសកម្មភាព ឬ រំលាយកិច្ចសន្យាដែលមានវិការៈក្នុងការបង្ហាញឆន្ទៈ ដូចជាការភាន់ច្រឡំ ឬការគំរាមកំហែង ជាអាទិ៍ អាចត្រូវបានលុបចោលនៅពេលក្រោយ។

ការបង្ហាញឆន្ទៈ រំលាយកិច្ចសន្យានេះអាចដាក់លក្ខខណ្ឌបង្អង់បាន។ ការបង្ហាញឆន្ទៈរំលាយកិច្ចសន្យាអាចដាក់លក្ខខណ្ឌបង្អង់បាន ដោយសារការធ្វើដូច្នេះមានលក្ខណៈងាយស្រួល ។ ឧទាហរណ៍៖ ក្នុងករណីដែលមាន ការមិនអនុវត្តកាតព្វកិច្ចរបស់ភាគីម្ខាង ហើយភាគីម្ខាងទៀតដាស់តឿន ឱ្យអនុវត្តកាតព្វកិច្ចដោយកំណត់ពេលជាក់លាក់ដើម្បីអនុវត្ត មានករណីច្រើនដែល ភាគីម្ខាងទៀតនោះបង្ហាញឆន្ទៈថា នឹងរំលាយកិច្ចសន្យាប្រសិនបើ មិនអនុវត្តកាតព្វកិច្ច ក្នុងអំឡុងពេលកំណត់នោះ។ ករណីនេះ គឺជាករណីដែលភ្ជាប់លក្ខខណ្ឌបង្អង់ចំពោះការបង្កើតអានុភាពនៃការបង្ហាញឆន្ទៈរំលាយកិច្ចសន្យា។ លក្ខខណ្ឌសំដៅទៅលើព្រឹត្តិការណ៍ដែលកើតឡើងនាពេលអនាគត ដែលមិនទៀងទាត់។[79] ទន្ទឹមនឹងនោះលក្ខខណ្ឌបង្អង់មានន័យថា កាតព្វកិច្ច ឬសិទ្ធិនឹងមានអានុភាពនៅពេលដែលលក្ខខណ្ឌនោះ បានបំពេញ។

### ២.៤.៥ អានុភាពនៃការរំលាយកិច្ចសន្យា

យោងតាមបញ្ញត្តិមាត្រា ៤១១ នៃក្រមរដ្ឋប្បវេណី ឆ្នាំ ២០០៧ អានុភាពដែលចេញពីការរំលាយកិច្ចសន្យាមានដូចជា៖

[79] មាត្រា ៣២៥ កថាខណ្ឌទី២ នៃក្រមរដ្ឋប្បវេណី ឆ្នាំ ២០០៧

- ការរំលាយកិច្ចសន្យា នាំឱ្យភាគីរួចផុតពីករណីក្នុងកិច្ចសន្យា លើកលែងតែករណីកិច្ចសងការខូចខាត។
- គូភាគីដែលបានទទួលតាវកាលិកនៃកិច្ចសន្យាតែមួយភាគ ឬ ទាំងអស់ ត្រូវមានករណីកិច្ចសងតាវកាលិកនោះទៅភាគីម្ខាងទៀត ដើម្បីភាគីនោះទទួលបដិទានឡើងវិញ ដោយ សារការរំលាយ។ ក្នុងករណីដែលភាគីទាំងសងខាង មានករណីកិច្ចធ្វើបដិទានទៅវិញទៅមក ករណីកិច្ចទាំងនោះត្រូវអនុវត្តនៅពេលជាមួយគ្នា។
- ភាគីមានករណីកិច្ចសងជាប្រាក់ដោយការរំលាយកិច្ចសន្យាត្រូវសងជាមួយនឹងការប្រាក់ដោយគិតចាប់ពីថ្ងៃដែលបានទទួលប្រាក់ដើមនោះ។ ភាគីដែលមានករណីកិច្ចបង្វិលជាវត្ថុ ឬ ជាតាវកាលិកផ្សេងដែលខ្លួនបានទទួល ទៅភាគីម្ខាងទៀតដោយសារការរំលាយ ត្រូវសងទាំងផលដែលបានទទួលពីវត្ថុ ឬ តាវកាលិកនោះវិញផងដែរ។
- ការរំលាយកិច្ចសន្យាមិនអាចធ្វើឱ្យខូចផលប្រយោជន៍ត្រឹមត្រូវរបស់តតិយជនបានឡើយ។

ក៏ប៉ុន្តែ មិនមានបញ្ញត្តិណាមួយដែលចែងច្បាស់ថា ហេតុអ្វីបានអានុភាពទាំងនេះកើតឡើងទេ។ ចំពោះអានុភាពនៃការរំលាយកិច្ចសន្យានេះមានគំនិតពីរ ដែលគំនិតទី១ ទទួលស្គាល់អានុភាពនៃការរំលាយកិច្ចសន្យាមានអានុភាពប្រតិសកម្ម និងគំនិតទី២ គឺមិនទទួលស្គាល់អានុភាពនៃការរំលាយកិច្ចសន្យា មានអានុភាពប្រតិសកម្ម។[80]

**គំនិតទី១ ដែលទទួលស្គាល់អានុភាពប្រតិសកម្ម:** ផ្អែកតាមគំនិតនេះ នៅក្នុងករណីដែលកិច្ចសន្យាត្រូវបានរំលាយ វាត្រូវបានចាត់ទុកថាគ្មានកិច្ចសន្យាតាំងពីដំបូង។ ដូនេះ ប្រសិនបើភាគីបានទទួលតាវកាលិកនៅមុនពេលរំលាយកិច្ចសន្យា គាត់ត្រូវធ្វើបដិទានឡើងវិញទៅស្ថានភាពដើមរបស់ភាគីម្ខាងទៀត ដោយផ្អែកលើសេចក្តីចម្រើនដោយឥតហេតុ។ នៅក្នុងសេចក្តីចម្រើនដោយឥតហេតុ ទោះបីជាគ្មានមូលហេតុ លើផ្លូវច្បាប់ក៏ដោយ បុគ្គលដែលបានទទួល ផលប្រយោជន៍ដោយសារទ្រព្យសម្បត្តិ ឬ ពលកម្មរបស់អ្នកដទៃ ហើយធ្វើឱ្យកើតមានការ បាត់បង់ផលប្រយោជន៍ ដល់អ្នកដទៃ ដោយសារការទទួលនោះ មានករណីកិច្ចត្រូវសងប្រយោជន៍នោះត្រឹមកម្រិតដែលផលប្រយោជន៍នោះមាន។[81]

ដូច្នេះ ដោយផ្អែកលើគំនិតទី១ ទំហំនៃកាតព្វកិច្ចដែលត្រូវបានធ្វើបដិទាន ត្រូវបានពន្លាតចាប់ពី ផលប្រយោជន៍ទៅត្រឹមកម្រិតដែលផលប្រយោជន៍នោះមាន រហូតដល់ ការធ្វើបដិទានទៅស្ថានភាពដើមវិញរបស់ភាគី។

[80] សេចក្តីពន្យល់ អំពីក្រមរដ្ឋប្បវេណី ភាគទី១ ឆ្នាំ ២០១៣ ទំព័រ ១៨៤

[81] មាត្រា ៧៣១ កថាខណ្ឌទី១ នៃក្រមរដ្ឋប្បវេណី ឆ្នាំ ២០០៧

**គំនិតទី២ ដែលមិនទទួលស្គាល់អានុភាពប្រតិសកម្មៈ** គំនិតដែលមិនទទួលស្គាល់អានុភាពប្រតិសកម្ម គឺក្នុងករណីដែលកិច្ចសន្យាត្រូវបានរំលាយត្រូវចាត់ទុកថា គ្មានអានុភាពប្រតិសកម្ម។ ដូច្នេះ សិទ្ធិលើបំណុលនិងកាតព្វកិច្ចដើម ត្រូវផ្លាស់ប្តូរទៅជា សិទ្ធិទាមទារ និងកាតព្វកិច្ចធ្វើបដិទានទៅស្ថានភាពដើមវិញ របស់ភាគី។ នៅក្នុងគំនិតនេះ បញ្ញត្តិនេះ បញ្ញត្តិនៃការរំលាយកិច្ចសន្យា ត្រូវយកមកអនុវត្តចំពោះពេលអនាគត ហើយទាក់ទងនឹងកាតព្វកិច្ច ដែលមិនទាន់ត្រូវបានអនុវត្ត គឺមិនមានអត្ថិភាពទៀតទេ នៅពេលអនាគត ។ ផ្ទុយទៅវិញ កាតព្វកិច្ច ដែលត្រូវអនុវត្តរួចហើយ គឺមានសុពលភាព ហើយមិនអាចក្លាយជាសេចក្តីចម្រើនឥតហេតុទេ ។

### ២.៤.៥.១ ការរលត់នូវករណីកិច្ចក្នុងកិច្ចសន្យា

ប្រសិនបើកិច្ចសន្យាមួយត្រូវបានរំលាយ ចំណងកិច្ចសន្យានឹងត្រូវរលត់។ ការរំលាយកិច្ចសន្យានឹងរំលត់រាល់កាតព្វកិច្ចទាំងឡាយ របស់ភាគីដែលកើតឡើងដោយកិច្ចសន្យា និងនាំឱ្យគូភាគីនៃកិច្ចសន្យារួចផុតពីកិច្ចសន្យានោះ។ ប៉ុន្តែ ក្នុងករណីដែលកិច្ចសន្យា ត្រូវបានរំលាយដោយមូលហេតុ មិនអនុវត្តកាតព្វកិច្ច នោះករណីកិច្ចសងសំណងការខូចខាត របស់កូនបំណុលដែលមិនអនុវត្តកិច្ច នៅតែមានអានុភាព។

### ២.៤.៥.២ ករណីកិច្ចបដិទាននៅស្ថានភាពដើមវិញ

ក្រោយពេលរំលាយកិច្ចសន្យា ភាគីដែលបានទទួលតាវកាលិក ត្រូវសងនូវតាវកាលិកនោះ ទៅឱ្យភាគីម្ខាងទៀតវិញ។ ក្នុងករណីដែលភាគីទាំងសងខាងមានករណីកិច្ចធ្វើបដិទានទៅវិញទៅមក ករណីកិច្ចទាំងនោះត្រូវអនុវត្តនៅពេលជាមួយគ្នា។ ឧទាហរណ៍៖ ក បានទិញឡានរបស់ ខ ដោយបានទទួលឡាននោះហើយ តែ ខ បានទទួលប្រាក់តែពាក់កណ្តាល។ ដល់ថ្ងៃប្រគល់ប្រាក់ ក នៅតែមិនបានប្រគល់ប្រាក់ពាក់កណ្តាលទៀតឱ្យ ខ ទោះបីជាមានការដាស់តឿនយ៉ាងណាក៏ដោយ។ ក្នុងករណីនេះ ខ មានសិទ្ធិរំលាយកិច្ចសន្យាហើយទាមទារឡានរបស់ខ្លួនមកវិញតែត្រូវប្រគល់ប្រាក់ពាក់កណ្តាល ដែលខ្លួនបានទទួលឱ្យទៅ ក វិញ។

### ២.៤.៥.៣ ទំហំនៃករណីកិច្ចធ្វើបដិទាន

ក្រៅពីតាវកាលិកជាប្រាក់ ដែលខ្លួនបានទទួល ភាគីត្រូវសងទៅវិញទៅមកផងដែរ នូវការប្រាក់នៃប្រាក់ដែលបានទទួលនិងផលប្រយោជន៍ទាំឡាយបានមកពីការប្រើប្រាស់តាវកាលិកដែលទទួលបាន។ ឧទាហរណ៍៖ ក បានទិញម៉ូតូរបស់ ខ ដោយបានទទួលម៉ូតូនោះហើយ តែ ខ បានទទួលប្រាក់តែពាក់កណ្តាល។ ដល់ថ្ងៃប្រគល់ប្រាក់ ក នៅតែមិនបានប្រគល់ប្រាក់ពាក់កណ្តាលទៀតឱ្យ ខ ទោះបីមានការដាស់តឿនយ៉ាងណាក៏ដោយ។ ក្នុងករណីនេះចំពោះអ្នកលក់ ខ មានសិទ្ធិរំលាយកិច្ចសន្យាហើ យទាមទារម៉ូតូរបស់ខ្លួនមកវិញ រួមជាមួយនឹងទឹកប្រាក់ដែលមាន តម្លៃស្មើនឹងថ្លៃជួលម៉ូតូក្នុងរយៈពេលដែល ក បានប្រើប្រាស់ម៉ូតូនេះ ដែលជា ផលប្រយោជន៍បានមកពីវត្ថុនោះ។ ចំពោះអ្នកទិញ ក វិញ មានសិទ្ធិទាមទារប្រាក់ពាក់កណ្តាល រួមជាមួយការប្រាក់គិតចាប់ពីពេលដែលអ្នកលក់ ខ បានទទួលប្រាក់នោះ។

**៣.៤.៥.៣ ការការពារតតិយជន**

ការរំលាយកិច្ចសន្យា មិនអាចធ្វើឱ្យខូចផលប្រយោជន៍ត្រឹមត្រូវ របស់តតិយជនបានឡើយ។ ចំពោះការការពារតតិយជន គឺអាស្រ័យទៅលើថាតើ អានុភាពប្រតិសកម្ម ត្រូវបានទទួលស្គាល់ ឬ មិនទទួលស្គាល់។ ការទទួលស្គាល់ ឬមិនទទួលស្គាល់នូវអានុភាព ប្រតិសកម្ម គឺជាបញ្ហាដែលមានលក្ខណៈទ្រឹស្តីស្មុគស្មាញ ដែលត្រូវទុកដោះស្រាយ តាមយុត្តិសាស្ត្រនាពេលអានាគត ដោយមិនចែងក្នុងក្រមរដ្ឋប្បវេណី ឆ្នាំ ២០០៧ ទេ។ ឧទាហរណ៍៖ ក បានលក់ផ្ទះទៅឱ្យ ខ ហើយ ខ បានលក់ផ្ទះនោះបន្តទៅឱ្យ គ។ ប៉ុន្តែ ខ បានខកខានក្នុងការបង់ថ្លៃទិញផ្ទះដែលធ្វើឱ្យ ក រំលាយកិច្ចសន្យា។ បញ្ហាកើតឡើងត្រង់ថា អ្នកទិញ ខ បានលក់ដីនេះបន្តឱ្យតតិយជន គ មុនពេលដែលអ្នកលក់ ក បង្ហាញឆន្ទៈរំលាយកិច្ចសន្យា។

**២.៤.៦ ការរលត់នូវសិទ្ធិរំលាយកិច្ចសន្យា**

**ការរំលត់នូវសិទ្ធិរំលាយកិច្ចសន្យា ត្រូវបានចែកចេញជា ៣ គឺ៖**

- ការរលត់កាតព្វកិច្ច ឬ សំណើរផ្តល់ការអនុវត្តកាតព្វកិច្ច
- ការខូចខាតកម្មវត្ថុនៃកិច្ចសន្យាដោយចេតនា
- អាជ្ញាយុកាល។

**២.៤.៦.១ ការអនុវត្តកាតព្វកិច្ច ឬ សំណើរផ្តល់ការអនុវត្តកាតព្វកិច្ច**

យោងតាមបញ្ញត្តិ មាត្រា ៤០៨ កថាខណ្ឌទី១ វាក្យខណ្ឌ ក នៃក្រមរដ្ឋប្បវេណី ឆ្នាំ ២០០៧ ការយឺតយ៉ាវក្នុងការអនុវត្តកាតព្វកិច្ច មានលក្ខខណ្ឌចំនួន ៣ គឺ៖

- កូនបំណុលមិនអនុវត្ត កាតព្វកិច្ចរបស់ខ្លួនតាមពេលកំណត់
- ម្ចាស់បំណុល ដាស់តឿនកូនបំណុលដែលមិនអនុវត្តកាតព្វកិច្ចឱ្យអនុវត្ត ក្នុងអំឡុងពេលសមរម្យ។
- កូនបំណុល មិនអនុវត្តកាតព្វកិច្ច នៅក្នុងអំឡុងពេលសមរម្យ។ដូច្នេះប្រសិនបើកូនបំណុលអនុវត្តកាតព្វកិច្ចនៅក្នុងអំឡុងពេលនោះកាតព្វកិច្ចត្រូវរលត់ដោយសារការសម្រេចនូវគោលបំណងនោះសិទ្ធិរំលាយកិច្ចសន្យា ក៏ត្រូវរលត់ដែរ។

ករណីដែលម្ចាស់បំណុល មិនព្រមទទួលយកកម្មវត្ថុ ទោះបីជា កូនបំណុលបានស្នើផ្តល់ការអនុវត្តកាតព្វកិច្ចដោយយោងទៅតាមការដាស់តឿនរបស់ម្ចាស់បំណុលនោះសិទ្ធិរំលាយរបស់ម្ចាស់បំណុលត្រូវរលត់។

**២.៤.៦.២ ការខូចខាតកម្មវត្ថុនៃកិច្ចសន្យាដោយចេតនា**

យោងតាម បញ្ញត្តិមាត្រា ៤១២ នៃក្រមរដ្ឋប្បវេណី ឆ្នាំ ២០០៧ សិទ្ធិរំលាយត្រូវរលត់ក្នុងករណីដែលភាគីមានសិទ្ធិរំលាយ៖

- បានធ្វើឱ្យមានការខូចខាត ឬបាត់បង់ដល់វត្ថុដែលជាកម្មវត្ថុនៃ កិច្ចសន្យាឬមិនអាចសងវត្ថុនោះវិញដោយចេតនា។ ឧទាហរណ៍៖ កម្មវត្ថុនៃកិច្ចសន្យាបានលក់បន្តបាត់ ឬបានបែកបាក់អស់ដោយចេតនា។
- ធ្វើឱ្យវត្ថុនោះក្លាយជាវត្ថុផ្សេង ដោយការកែច្នៃ ឬការផ្លាស់ទម្រង់ដោយចេតនា។ ឧទាហរណ៍៖ ការទិញអង្ករ តែអង្ករ ត្រូវបានធ្វើជានំបញ្ចុកអស់ទៅហើយ។

ប៉ុន្តែក្នុងករណីដែល កម្មវត្ថុត្រូវបានធ្វើឱ្យខូចខាត ឬបាត់បង់ ឬមិនអាចសងមកវិញ ដោយមិនមានចេតនានោះសិទ្ធិរំលាយមិនត្រូវរលត់ទេ។ គាត់អាចរំលាយកិច្ចសន្យាបានប៉ុន្តែ គាត់ត្រូវសងជាទឹកប្រាក់ ចំពោះតម្លៃដែលត្រូវបានបន្ថយដោយសារការខូចខាតនោះ។ ឧទាហរណ៍៖ ក បានទិញម៉ូតូពី ខ ដែលជាម៉ូតូថ្មីហើយភាគីទាំងពីរនាក់បានអនុវត្តកាតព្វកិច្ចរួចរាល់ហើយ ដោយ ក បានទទួលម៉ូតូ និង ខ បានទទួលប្រាក់ តែក្រោយមក ក បានដឹងថា ម៉ូតូនោះមិនមែនជាម៉ូតូថ្មីទេ ហើយបានទាមទារឱ្យ ខ ប្រគល់ម៉ូតូថ្មី ដោយកំណត់ពេលសមរម្យ តែ ខ នៅតែមិនព្រមប្រគល់ ហេតុនេះ ក រំលាយកិច្ចសន្យា តែមុនពេលប្រគល់ម៉ូតូនោះ ក បានធ្វើឱ្យខូចខាតម៉ូតូដោយអចេតនា ក្នុងគ្រោះថ្នាក់ចរាចរណ៍មួយ។ ក អាចរំលាយកិច្ចសន្យាបានតែត្រូវចេញថ្លៃជួសជុលម៉ូតូ ដែលខ្លួនបានធ្វើឱ្យខូចខាត។

**២.៤.៦.៣ អាជ្ញាយុកាល**

អាជ្ញាយុកាលនៃការរំលត់សិទ្ធិរំលាយ កិច្ចសន្យាដោយមូលហេតុនៃការមិនអនុវត្តកាតព្វកិច្ច និង សិទ្ធិទាមទារបដិទាន មានអំឡុងពេល ៥ (ប្រាំ) ឆ្នាំ ក្រោយពីពេលដែលមិនបានអនុវត្តកាតព្វកិច្ច។[82] វាមិនដូច នឹងការទាមទារឱ្យសងសំណងនៃការខូចខាតទេ អាជ្ញាយុកាលនៃសិទ្ធិរំលាយ ចាប់គិតពីពេល ដែលមានការមិនអនុវត្តកាតព្វកិច្ច។ ក្នុងករណីយឺតយ៉ាវក្នុងការអនុវត្តកាតព្វកិច្ចសិទ្ធិរំលាយកិច្ចសន្យាមិនត្រូវកើតឡើងប្រសិនបើម្ចាស់បំណុលមិនបានដាស់តឿន។ ប៉ុន្តែប្រសិនបើការអនុវត្តកាតព្វកិច្ចនេះមានការយឺតយ៉ាវនោះ ម្ចាស់បំណុលអាចបង្កើតសិទ្ធិ រំលាយដោយធ្វើការដាស់តឿន នៅពេលណាក៏បានដែរ។ ហេតុដូច្នេះ គ្មានបញ្ហាទេចំពោះការចែងថាអាជ្ញាយុកាលនៃការរំលត់សិទ្ធិរំលាយកិច្ចសន្យា ចាប់គិតពីពេលនៃការយឺតយ៉ាវក្នុងការអនុវត្តកាតព្វកិច្ច។

ចំពោះសិទ្ធិទាមទារ ឱ្យធ្វើបដិទានដែលកើតឡើងវិញដោយអនុវត្ត សិទ្ធិរំលាយគ្មានអាជ្ញាយុកាលដោយឡែក ពិសេសទេហេតុដូច្នេះ សិទ្ធិទាមទារឱ្យធ្វើបដិទាន នេះនឹងត្រូវរលត់ ប្រសិនបើមិនទាមទារឱ្យធ្វើបដិទានមុនអាជ្ញាយុកាលនៃការរំលត់សិទ្ធិរំលាយត្រូវបានសម្រេច។

[82] មាត្រា ៤១៣ នៃក្រមរដ្ឋប្បវេណី ឆ្នាំ ២០០៧

# សេចក្តីសន្និដ្ឋាន

ទណ្ឌកម្មនៃកិច្ចសន្យា គឺជាសកម្មភាពមួយដែលបានកំណត់ក្នុងក្រមរដ្ឋប្បវេណី ឆ្នាំ ២០០៧ ដូច្នេះប្រសិនបើមានវិវាទកើតឡើងអំពីកិច្ចសន្យា នោះភាគីនៃកិច្ចសន្យា នឹងមានកាតព្វកិច្ចកើតឡើងពួកគេត្រូវយកសញ្ញាណគតិយុត្តដែលមានចែងក្នុងក្រមរដ្ឋប្បវេណីឆ្នាំ ២០០៧ មកអនុវត្ត ប្រសិនបើពួកគេមិនបានព្រមព្រៀងផ្សេងពីនេះ។ ក្រោយពីបានធ្វើការសិក្សាស្រាវជ្រាវទៅលើប្រធានបទ «ទណ្ឌកម្មនៃកិច្ចសន្យា» នេះរួចមកឃើញថាទណ្ឌកម្មគឺពិតជាមានសារៈសំខាន់ខ្លាំងណាស់ ក្នុងវិស័យទំនាក់ទំនងឯកជនជាពិសេសក្នុងដំណើរនៃអាជីវកម្មដែលគូភាគីបានព្រៀមព្រៀងគ្នា ដើម្បីសម្រេចនូវឆន្ទៈរួមមួយ និងគុណប្រយោជន៍ជាការចែករំលែកចំណេះដឹងសម្រាប់សិស្សប្អូនៗជំនាន់ក្រោយក្នុងការសិក្សាស្រាវជ្រាវផងដែរ។ ម្យ៉ាងវិញទៀត គឺបានផ្តល់ចំណេះដឹងដល់ប្រជាពលរដ្ឋទូទៅដែលមាន បំណងចង់បង្កើតកិច្ចសន្យា និងបានដឹងអំពីកាតព្វកិច្ចរបស់ខ្លួនដើម្បីជៀសវាងកុំឱ្យមានទណ្ឌកម្មកើតមានឡើង។ ជាក់ស្តែងបុគ្គលមួយចំនួនយល់ថា ទណ្ឌកម្មនៃកិច្ចសន្យា ត្រូវអនុលោមតាមច្បាប់ព្រហ្មទណ្ឌ ផ្ទុយមកវិញ ទណ្ឌកម្មនៃកិច្ចសន្យានេះ ជាប្រភេទទណ្ឌកកម្មដែលស្ថិតនៅក្នុង បរិបទក្រមរដ្ឋប្បវេណី ឆ្នាំ ២០០៧ ប៉ុណ្ណោះ។

ជំហានដំបូងត្រូវយល់ថា ទណ្ឌកម្មនៃកិច្ចសន្យា គឺមានពីរប្រភេទធំៗ គឺទណ្ឌកម្មក្នុងពេលបង្កើតកិច្ចសន្យា និងទណ្ឌកម្មក្រោយពេលបង្កើតកិច្ចសន្យា ហើយទណ្ឌកម្មនៅក្នុងពេលបង្កើតកិច្ចសន្យាមានដូចជា៖ ការបង្ហាញឆន្ទៈមិនពិត ភាពខុសច្បាប់ ឬផ្ទុយនិងសណ្តាប់ធ្នាប់សាធារណៈ ឬទំនៀមទម្លាប់ល្អ ការភាន់ច្រឡំ ការឆបោក ព័ត៌មានមិនពិត ការរំលោភបំពានលើស្ថានភាព អំពើកេងយកចំណេញហួសហេតុ អលទ្ធភាពតាំងពីដំបូង និងឋបនីយផ្លូវចិត្ត។ ចំណែកឯទណ្ឌកម្មក្រោយពេលបង្កើតកិច្ចសន្យាវិញមានដូចជា៖ ការអនុវត្តកាតព្វកិច្ចដោយបង្ខំ ការទាមទារសំណងការខូចខាត និងការរំលាយកិច្ចសន្យា។

សរុបជារួមមក ដោយមើលឃើញការនុវត្តភាពនៅក្នុងប្រទេសកម្ពុជា បច្ចុប្បន្នស្របពេល ដែលប្រទេសមានសន្តិភាព និងការអភិវឌ្ឍន៍ ការបង្កើតកិច្ចសន្យា ដែលមានចែងក្នុងក្រមរដ្ឋប្បវេណី ឆ្នាំ ២០០៧ ងាយស្រួលក្នុងការបង្កើត និងរំលាយ ដោយសារតែមានការកំណត់បានច្បាស់លាស់ ដែលមានលក្ខណៈងាយស្រួលក្នុងការអនុវត្ត ក៏ប៉ុន្តែ បើខុសនិងលក្ខខណ្ឌវិញ នោះទណ្ឌកម្មនិងកើតមានឡើងដល់ភាគី នៃកិច្ចសន្យាដែលមិនអនុវត្តកាតព្វកិច្ចក្នុងកិច្ចសន្យានោះ។ បើកិច្ចសន្យាកំពុងត្រូវបានបង្កើតនោះទណ្ឌកម្មក្នុងពេលបង្កើតកិច្ចសន្យា និងត្រូវបានយកអនុវត្ត តែបើ កិច្ចសន្យាត្រូវបានបង្កើតហើយនោះ ទណ្ឌកម្មក្រោយពេលបង្កើតកិច្ចសន្យានិងត្រូវបានយកមកអនុម័ត។

## អនុសាសន៍

ដើម្បីឆ្លើយតបទៅនឹងបញ្ហាដែលបានលើកឡើងខាងលើ ខ្ញុំបាទទាំងពីរនាក់សូមសំណូមពរដល់អ្នកដែលពាក់ព័ន្ធដូចជាៈ

**-រដ្ឋាភិបាលៈ** ជាពិសេសក្រសួងពាក់ព័ន្ធនានាជួយពង្រឹង លើកកម្ពស់ ផ្សព្វផ្សាយ ចំណេះដឹងផ្នែកច្បាប់ឱ្យបានទូលំទូលាយបន្ថែមទៀត តាមរយៈការដាក់បញ្ចូលក្នុងកម្មវិធីសិក្សាថ្នាក់ក្រោមឧត្តមសិក្សានូវចំណេះដឹងជាមូលដ្ឋានផ្នែកច្បាប់ ក៏ដូចជាការបង្កើតជាកម្មវិធីផ្សព្វផ្សាយផ្សេងៗ ទាំងតាមរយៈការចុះទៅដល់សហគមន៍ផ្ទាល់ និងតាមរយៈប្រពន្ធផ្សព្វផ្សាយនានា ដោយសារប្រជាជនភាគច្រើន ជាពិសេសអ្នកដែលរស់នៅតំបន់ដាច់ស្រយាលពិតជាមិនសូវបានចាប់អារម្មណ៍ឬទទួលបានចំណេះដឹងច្បាប់ទេ ខណៈដែលច្បាប់ថ្មីៗកំពុងតែត្រូវបានបង្កើតជាបន្តបន្ទាប់។

**-ស្ថាប័នតុលាការៈ** ពន្លឿនការដោះស្រាយវិវាទ ដែលប្រជាពលរដ្ឋបានដាក់បណ្ដឹងទៅឱ្យបានលឿន និងមានប្រសិទ្ធិភាពជាងនេះទៀត ព្រោះបើកាលណានីតិវិធីបណ្ដឹងមានរយៈពេលយូរ ប្រជាពលរដ្ឋគាត់មិនចង់ប្ដឹងទៅតុលាការទេ ដោយសារគាត់ត្រូវចំណាយពេលវេលាច្រើន ទោះបីជារឿងក្ដីខ្លះគាត់ជាអ្នកជាបាត់បង់ផលប្រយោជន៍ក៏ដោយ។

**-មន្ត្រីរាជការ សិស្ស និស្សិតៈ** បុគ្គលទាំងនេះត្រូវបានចាត់ទុកជាអ្នកដែលមានចំណេះដឹង និងមានការយល់ដឹង អំពីច្បាប់ ក៏ដូចជាព័ត៌មានផ្សេងៗជាច្រើន ច្បាស់ជាងប្រជាពលរដ្ឋទូទៅ។ ដូចនេះ សិស្ស និស្សិត មន្ត្រីរាជការ គួរធ្វើខ្លួនជាគំរូ ដោយគោរពច្បាប់ និងមិនប្រតិបត្តិអ្វីដែលល្មើសច្បាប់ ហើយជាពិសេស ត្រូវមានស្មារតីចេះចែករំលែកនូវចំណេះដឹងក្នុងនាមប្រជាពលរដ្ឋខ្មែរ។

**-ប្រជាពលរដ្ឋៈ** ប្រជាពលរដ្ឋត្រូវ ចូលរួមអនុវត្តច្បាប់ឱ្យបានខ្ជាប់ខ្ជួន ស្របតាមស្មារតី សុច្ចរិត និងស្មោះត្រង់។ ជាពិសេសពេលដែលមានការធ្វើការបង្កើតកិច្ចសន្យាប្រភេទណាមួយនោះត្រូវតែប្រុងប្រយ័ត្ន ដើម្បីជៀសវាងកុំឱ្យមាន វិវាទកើតមានឡើងជាយថាហេតុ ហើយត្រូវតែគោរពនូវគោលការណ៍សុច្ចរិតភាព និងភាពស្មោះត្រង់គ្រប់ពេលវេលា។

## ឯកសារយោង


១. ក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា, លេខ នស /រកម/១២០៧/០៣០,០៨ ធ្នូ ២០០៧

២. ក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា, លេខ នស /រកម/០៧០៦/០២១, ០៦ កក្កដា ២០០៦

៣. ច្បាប់ស្តីពីការងារ, ១៣ មិនា ឆ្នាំ ២០០៧

៤. សេចក្តីកំណត់ចំពោះមាត្រានីមួយៗ នៃក្រមរដ្ឋប្បវេណី ភាគីទី២, ០៩ ធ្នូ ២០១០

៥. សៀវភៅក្រមរដ្ឋប្បវេណី និងក្រមនីតិវិធីរដ្ឋប្បវេណី ភាគទី១ របស់ក្រសួងយុត្តិធម៌, ធ្នូ ឆ្នាំ ២០១៥

៦. សេចក្តីពន្យល់ អំពីក្រមរដ្ឋប្បវេណី ភាគទី១ រៀបរាងដោយ ក្រុមការងារនៃគ្រូបណ្តុះបណ្តាលនៅសាលាភូមិន្ទចៅក្រមនៃរាជបណ្ឌិតសភាវិជ្ជាជីវៈតុលាការ, មេសា ២០១៣

៧. សន្ទានុក្រមផ្នែករដ្ឋប្បវេណី នៃក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា, លេខ នស/រកម/ ១២០៧/០៣០, ០៨ ធ្នូ ២០០៧ ។

# ឧបសម្ព័ន្ធ

# ជំពូកទី ២
# ការបង្ហាញឆន្ទៈ និង កិច្ចសន្យា
## ផ្នែកទី ១
## ការបង្កើតកិច្ចសន្យា

**មាត្រា ៣៣៦.–** ការបង្កើតកិច្ចសន្យាដោយសំណើ និង ស្ទីការ

១-កិច្ចសន្យាមានអានុភាពដោយសារសំណើ និង ស្ទីការត្រូវគ្នា ។

២-ទោះបីមានបញ្ញត្តិនៃកថាខណ្ឌទី ១ ខាងលើនេះក៏ដោយ ក៏កិច្ចសន្យាដែលភាគីម្ខាងទទួលករណីយកិច្ចធ្វើអនុប្បទានទ្ធកម្មសិទ្ធិលើអចលនវត្ថុ ឬ ករណីយកិច្ចធ្វើលទ្ធកម្មនូវកម្មសិទ្ធិលើអចលនវត្ថុ នឹងមានអានុភាព លុះត្រាតែបានធ្វើលិខិតយថាភូត ។

**មាត្រា ៣៣៧.–** និយមន័យនៃសំណើ និង ស្ទីការ

១-សំណើគឺជាការសុំបង្កើតកិច្ចសន្យាដែលធ្វើឡើង ដោយមានឆន្ទៈភ្ជាប់ខ្លួនជាមួយនឹងចំណងគតិយុត្តក្នុងករណីដែលមានស្ទីការរបស់ភាគីម្ខាងទៀតចំពោះសំណើនេះ ។

២-សំណើត្រូវមានអានុភាពនៅពេលដែលសំណើនោះបានដល់ភាគីម្ខាងទៀត ។ ប៉ុន្តែ ប្រសិនបើដំណឹងអំពីការដកសំណើវិញ ដល់ភាគីម្ខាងទៀត នៅពេលព្រមគ្នានឹងពេលសំណើដល់ ឬ មុនពេលសំណើដល់ នោះអានុភាពសំណើមិនត្រូវកើតឡើយ ។

៣-ស្ទីការគឺជាការបង្ហាញឆន្ទៈដែលអ្នកទទួលសំណើយល់ព្រមចំពោះសំណើនោះ ។

៤-ស្ទីការត្រូវមានអានុភាពនៅពេលដែលស្ទីការនោះបានដល់អ្នកស្នើ ។ ប៉ុន្តែ ប្រសិនបើដំណឹងអំពីការដកស្ទីការវិញ ដល់អ្នកស្នើ នៅពេលព្រមគ្នានឹងពេលស្ទីការដល់ ឬ មុនពេលស្ទីការដល់ នោះអានុភាពនៃស្ទីការ មិនត្រូវកើតឡើយ ។

**មាត្រា ៣៣៨.–** សំណើដែលមានកំណត់អំឡុងពេលសម្រាប់ស្ទីការ និង ការដកសំណើនោះ

១-សំណើអាចធ្វើឡើងបានដោយកំណត់អំឡុងពេលសម្រាប់ស្ទីការ ។ អំឡុងពេល

សម្រាប់ស្ទីការ ត្រូវគិតចាប់ពីថ្ងៃដែលជូនដំណឹងអំពីសំណើ បើមិនច្បាស់ថា អ្នកស្នើកំណត់ពេលផ្សេង ។

២-សំណើដែលត្រូវបានធ្វើឡើងដោយមានកំណត់អំឡុងពេលសម្រាប់ស្ទីការ មិនអាចដកវិញបានទេ ។

៣-ប្រសិនបើអ្នកស្នើមិនបានទទួលដំណឹងអំពីស្ទីការ ក្នុងអំឡុងពេលដែលបានកំណត់នៅកថាខណ្ឌទី ១ ខាងលើនេះទេ សំណើនោះត្រូវបាត់បង់អានុភាពដោយស្វ័យប្រវត្តិនៅពេលផុតអំឡុងពេលសម្រាប់ស្ទីការ ។ ក្នុងករណីដែលដំណឹងអំពីការបដិសេធសំណើបានដល់អ្នកស្នើក្នុងអំឡុងពេលសម្រាប់ស្ទីការនោះ សំណើនោះក៏ត្រូវបាត់បង់អានុភាពដែរ ។

**មាត្រា ៣៣៩.–** សំណើដែលគ្មានកំណត់អំឡុងពេលសម្រាប់ស្ទីការ និង ការដកសំណើនោះ

១-ចំពោះសំណើដែលត្រូវបានធ្វើឡើងដោយគ្មានកំណត់អំឡុងពេលសម្រាប់ស្ទីការរវាងគូភាគីដែលកំពុងនិយាយគ្នា នៅក្នុងស្ថានភាពដែលអាចឆ្លើយភ្លាមៗបាន ប្រសិនបើភាគីដែលទទួលសំណើមិនបានយល់ព្រមភ្លាមៗទេ សំណើនោះត្រូវបាត់បង់អានុភាព ។

២-ចំពោះសំណើដែលធ្វើរវាងគូភាគីដែលមិននិយាយគ្នា ដោយគ្មានកំណត់អំឡុងពេលសម្រាប់ស្ទីការទេ អ្នកស្នើមិនអាចដកសំណើនោះវិញក្នុងអំឡុងពេលសមរម្យបានឡើយ ។

៣-ការដកសំណើត្រូវមានអានុភាព លុះត្រាតែការជូនដំណឹងអំពីការដកសំណើនោះបានមកដល់ភាគីម្ខាងទៀត មុនពេលភាគីម្ខាងទៀតជូនដំណឹងអំពីស្ទីការ ។

**មាត្រា ៣៤០.–** ពេលនៃការបង្កើតកិច្ចសន្យា : គោលការណ៍នៃការមកដល់នៃស្ទីការ

កិច្ចសន្យាត្រូវកើតឡើងនៅពេលដែលដំណឹងអំពីស្ទីការបានមកដល់អ្នកស្នើ ។

**មាត្រា ៣៤១.–** ការមកដល់យឺតយ៉ាវនៃស្ទីការ

១-ក្នុងករណីដែលការជូនដំណឹងអំពីស្ទីការ ចំពោះសំណើដែលមានអំឡុងពេល

សម្រាប់ស្ទីការ មកដល់ភាគីម្ខាងទៀត ក្រោយពេលអំឡុងពេលសម្រាប់ស្ទីការនោះកន្លងផុត ប្រសិនបើអ្នកស្នើស្ថិតនៅក្នុងស្ថានភាពដែលអាចដឹងថា ភាគីម្ខាងទៀតជូនដំណឹងអំពីស្ទីការនោះ នៅពេលដែលអាចមកដល់ក្នុងអំឡុងពេលសម្រាប់ស្ទីការក្នុងករណីធម្មតា នោះអ្នកស្នើត្រូវជូនដំណឹងអំពីការមកដល់ស្ទីការដោយមានការយឺតយ៉ាវនោះ ទៅអ្នកធ្វើស្ទីការ ដោយគ្មានការយឺតយ៉ាវ ។ ក្នុងករណីដែលអ្នកស្នើធ្វេសប្រហែសក្នុងការជូនដំណឹងអំពីការមកដល់ស្ទីការដោយមានការយឺតយ៉ាវនោះ ស្ទីការដែលមកដល់ដោយមានការយឺតយ៉ាវនោះ មានសុពលភាព ។

២-អ្នកស្នើ អាចចាត់ទុកថា ស្ទីការដែលបានមកដល់អ្នកស្នើក្រោយពេលផុតអំឡុងពេលសម្រាប់ស្ទីការ ជាសំណើថ្មី ។

**មាត្រា ៣៤២.–** ស្ទីការដោយមានបន្ថែមការកែប្រែ

១-ស្ទីការដែលអ្នកធ្វើស្ទីការបានដាក់ល័ក្ខខ័ណ្ឌលើសំណើ ឬ កែប្រែសារធាតុផ្សេងនៃសំណើ មិនត្រូវក្លាយជាស្ទីការសុពល តែស្ទីការនោះមានអានុភាពជាសំណើថ្មី ។ កិច្ចសន្យាត្រូវកើតឡើងនៅពេលដែលអ្នកធ្វើសំណើដើម ធ្វើស្ទីការចំពោះសំណើថ្មីនោះ ។

២-ប្រសិនបើល័ក្ខខ័ណ្ឌ ឬ ការកែប្រែដែលភ្ជាប់ជាមួយនឹងស្ទីការមិនធ្វើឱ្យមានការកែប្រែសារធាតុនៃសំណើទេ ស្ទីការនោះមានសុពលភាព លុះត្រាតែអ្នកស្នើមិនតវ៉ាភ្លាម ។ អត្ថន័យនៃកិច្ចសន្យាដែលត្រូវកើតឡើងដោយស្ទីការនោះ ត្រូវទៅតាមអត្ថន័យនៃស្ទីការ លុះត្រាតែអ្នកស្នើដែលបានទទួលស្ទីការមិនតវ៉ាភ្លាមៗទេ ។

**មាត្រា ៣៤៣.–** ការបង្កើតកិច្ចសន្យាដោយសកម្មភាពដែលត្រូវបានចាត់ទុកថាជាស្ទីការ

ក្នុងករណីដែលមិនចាំបាច់ឱ្យមានដំណឹងអំពីស្ទីការ ដោយសារឆន្ទៈរបស់អ្នកស្នើ ឬ ដោយសារទំនៀមទម្លាប់នៃកិច្ចការជំនួញ កិច្ចសន្យាត្រូវកើតឡើងនៅពេលដែលមានសកម្មភាពអាចទទួលស្គាល់ថាជាស្ទីការ ។

**មាត្រា ៣៤៤.–** ការដកសំណើចំពោះបុគ្គលដែលមិនបានកំណត់ជាក់លាក់

សំណើចំពោះបុគ្គលដែលមិនបានកំណត់ជាក់លាក់តាមការផ្សាយជាសាធារណៈ

ឬ តាមវិធីផ្សេងទៀត អាចដកបានតែតាមវិធីដូចគ្នានឹងសំណើនោះ ។

## ផ្នែកទី ២
## វិការៈក្នុងការបង្ហាញឆន្ទៈ និង សុពលភាពនៃកិច្ចសន្យា

**មាត្រា ៣៤៥.–** ការបង្ហាញឆន្ទៈដែលមានវិការៈ

អ្នកដែលបង្ហាញឆន្ទៈអាចលុបចោលកិច្ចសន្យាបាន ដោយហេតុថា ការបង្ហាញឆន្ទៈនោះមានវិការៈ តាមបញ្ញត្តិនៃផ្នែកទី ២ (វិការៈក្នុងការបង្ហាញឆន្ទៈ និង សុពលភាពនៃកិច្ចសន្យា) នេះ និង ផ្នែកទី ៣ (មោឃភាព និង ការលុបចោល) ក្នុងករណីដូចខាងក្រោមនេះ :

ក- ការបង្ហាញឆន្ទៈត្រូវបានធ្វើឡើងដោយការភាន់ច្រឡំ ។

ខ- ការបង្ហាញឆន្ទៈត្រូវបានធ្វើឡើងដោយការឆបោក ឬ ការគម្រាមកំហែង ឬ ការបង្ហាញការមិនពិតរបស់ភាគីម្ខាងទៀត ។

គ- ការបង្ហាញឆន្ទៈត្រូវបានធ្វើឡើងដោយអំពើឆ្លៀតឱកាសដោយមានគោលបំណងកេងយកចំណេញហួសហេតុ ។

**មាត្រា ៣៤៦.–** ការភាន់ច្រឡំ

១- ក្នុងករណីដែលភាគីមានការភាន់ច្រឡំអំពីចំណុចសំខាន់ៗនៃកិច្ចសន្យា បើភាគីម្ខាងទៀតបានស្ថិតនៅក្នុងស្ថានភាពដែលអាចដឹងអំពីការភាន់ច្រឡំនេះ ភាគីដែលបានភាន់ច្រឡំអាចលុបចោលនូវកិច្ចសន្យាបាន ដោយហេតុថា ការបង្ហាញឆន្ទៈនោះមានវិការៈ ។

២- ក្នុងករណីដែលភាគីម្ខាងនៃកិច្ចសន្យា មានការភាន់ច្រឡំអំពីចំណុចនៃកិច្ចសន្យាដែលខ្លួនយល់ឃើញថាសំខាន់ ឬ ចំណុចដែលខ្លួនយល់ឃើញថាសំខាន់ក្នុងការបង្កើតកិច្ចសន្យា បើភាគីម្ខាងទៀតបានស្ថិតនៅក្នុងស្ថានភាពដែលអាចដឹងអំពីភាពសំខាន់នៃចំណុចនេះ និង ការភាន់ច្រឡំរបស់អ្នកបង្ហាញឆន្ទៈនោះ ភាគីដែលបានភាន់ច្រឡំអាចលុបចោលនូវកិច្ចសន្យាបាន ដោយហេតុថា ការបង្ហាញឆន្ទៈនោះមានវិការៈ ។

៣-ក្នុងករណីដែលភាគីទាំងសងខាងមានការភាន់ច្រឡំអំពីចំណុចសំខាន់ៗនៃកិច្ចសន្យា ឬ ចំណុចនៃកិច្ចសន្យាដែលភាគីទាំងសងខាងយល់ឃើញថាសំខាន់ ឬ ចំណុចដែលភាគីទាំងសងខាងយល់ឃើញថាសំខាន់ក្នុងការបង្កើតកិច្ចសន្យា ទោះបីជាភាគីម្ខាងមិនមានលទ្ធភាពអាចដឹងអំពីការភាន់ច្រឡំរបស់ភាគីម្ខាងទៀតក៏ដោយ ក៏ភាគីដែលបានភាន់ច្រឡំអាចលុបចោលនូវកិច្ចសន្យាបានដែរ ដោយហេតុថា ការបង្ហាញឆន្ទៈនោះមានវិការៈ ។

៤-ការលុបចោលនូវកិច្ចសន្យាដោយការភាន់ច្រឡំ ក្រៅពីភាគីម្ខាងទៀត អាចអះអាងចំពោះតតិយជនបាន ។ ប៉ុន្តែ ប្រសិនបើតតិយជនជាជនសុចរិត ហើយគ្មានកំហុសអំពីការភាន់ច្រឡំ មិនអាចអះអាងនូវការលុបចោលចំពោះតតិយជននោះបានឡើយ ។

**មាត្រា ៣៤៧.–** ការឆបោក

១-បុគ្គលដែលបានធ្វើការបង្ហាញឆន្ទៈ ដោយសារការឆបោករបស់ភាគីម្ខាងទៀត អាចលុបចោលនូវកិច្ចសន្យា ដោយហេតុថា ការបង្ហាញឆន្ទៈនោះមានវិការៈ ។

២-ក្នុងករណីដែលការបង្ហាញឆន្ទៈបានធ្វើឡើងដោយសារការឆបោករបស់តតិយជន អ្នកបង្ហាញឆន្ទៈអាចលុបចោលនូវកិច្ចសន្យា ដោយហេតុថា ការបង្ហាញឆន្ទៈនោះមានវិការៈ លុះត្រាតែក្នុងករណីដែលភាគីម្ខាងទៀតនៃការបង្ហាញឆន្ទៈនោះ បានដឹង ឬ អាចដឹងអំពីការឆបោកនោះ ។

៣-ការលុបចោលនូវកិច្ចសន្យាដោយការឆបោក ក្រៅពីភាគីម្ខាងទៀត អាចអះអាងចំពោះតតិយជនបាន ។ ប៉ុន្តែ ប្រសិនបើតតិយជនជាជនសុចរិត ហើយគ្មានកំហុសអំពីការឆបោក មិនអាចអះអាងនូវអានុភាពនៃការលុបចោលចំពោះតតិយជននោះបានឡើយ ។

**មាត្រា ៣៤៨.–** ព័ត៌មានមិនពិត

១-នៅពេលធ្វើកិច្ចសន្យា បើហេតុដែលបានបង្ហាញដោយភាគីម្ខាងនោះខុសពីការពិត ហើយភាគីម្ខាងទៀតបានបង្ហាញឆន្ទៈដោយជឿជាក់ថា ហេតុទាំងនោះជាការពិត ប៉ុន្តែ ប្រសិនបើភាគីនោះដឹងថា ហេតុនោះមិនមែនជាការពិត ខ្លួននឹងមិនបង្ហាញឆន្ទៈទេ ភាគីនោះអាចលុបចោលនូវកិច្ចសន្យាបាន ដោយហេតុថា ការបង្ហាញឆន្ទៈនោះមាន

វិការៈ ។

២-បញ្ញត្តិនៃកថាខណ្ឌទី ១ ខាងលើនេះ មិនរារាំងភាគីដែលបានបង្ហាញឆន្ទៈក្នុងការទាមទារសំណងនៃការខូចខាតពីបុគ្គលដែលបានបង្ហាញការណ៍មិនពិតនោះទេ ក្នុងករណីដែលបុគ្គលនេះមានកំហុស ។

៣-ការលុបចោលនូវកិច្ចសន្យាដោយព័ត៌មានមិនពិត ក្រៅពីភាគីម្ខាងទៀត អាចអះអាងចំពោះតតិយជនបាន ។ ប៉ុន្តែ ប្រសិនបើតតិយជនជាជនសុចរិត ហើយគ្មានកំហុសអំពីព័ត៌មានមិនពិត មិនអាចអះអាងនូវអានុភាពនៃការលុបចោល ចំពោះតតិយជននោះបានឡើយ ។

**មាត្រា ៣៤៩.–** ការរំលោភបំពានលើស្ថានភាព

១-នៅពេលធ្វើកិច្ចសន្យា បើភាគីម្ខាងនៃកិច្ចសន្យាបានប្រើឋានៈខ្លួនដែលមានអាទិភាពជាងភាគីម្ខាងទៀត ខាងផ្នែកសេដ្ឋកិច្ច ឬ ផ្នែកសង្គម ឬ បានប្រើស្ថានភាពផ្សេងទៀតដែលភាគីម្ខាងទៀតមិនអាចប្រឆាំងតបបានទេ ភាគីម្ខាងទៀតនោះអាចលុបចោលនូវកិច្ចសន្យាបាន ដោយហេតុថា ការបង្ហាញឆន្ទៈនោះមានវិការៈ ។

២-ការលុបចោលនូវកិច្ចសន្យាដោយយោងតាមបញ្ញត្តិនៃកថាខណ្ឌទី ១ ខាងលើនេះ មិនអាចអះអាងចំពោះតតិយជនដែលជាជនសុចរិត ហើយគ្មានកំហុសអំពីការរំលោភបំពានលើស្ថានភាពបានឡើយ ។

**មាត្រា ៣៥០.–** ការគម្រាមកំហែង

បុគ្គលដែលបានបង្ហាញឆន្ទៈដោយសារមានការគម្រាមកំហែងពីសំណាក់ភាគីម្ខាងទៀត ឬ ពីសំណាក់តតិយជន អាចលុបចោលនូវកិច្ចសន្យាបាន ដោយហេតុថា ការបង្ហាញឆន្ទៈនោះមានវិការៈ ។

**មាត្រា ៣៥១.–** អំពើកេងយកចំណេញហួសហេតុ

ក្នុងករណីដែលភាគីម្ខាងបានធ្វើកិច្ចសន្យា ដោយឆ្លៀតឱកាសដែលភាគីម្ខាងទៀតកំពុងជួបប្រទះការលំបាកខាងផ្នែកសេដ្ឋកិច្ច ឬ ភាពល្ងង់ ឬ ការខ្វះការពិសោធន៍ ហើយ

បានកេងយកចំណេញយ៉ាងសន្ធឹកសន្ធាប់ពីកិច្ចសន្យានោះ ភាគីម្ខាងទៀតនោះអាចលុបចោលនូវកិច្ចសន្យាបាន ដោយហេតុថា ការបង្ហាញឆន្ទៈនោះមានវិការៈ ។

**មាត្រា ៣៥២.–** ឋបនីយផ្លូវចិត្ត

ប្រសិនបើកិច្ចសន្យាត្រូវបានបង្កើតឡើង ដោយការបង្ហាញឆន្ទៈដែលភាគីដឹងខ្លួនថាខុសឆន្ទៈពិតរបស់ខ្លួន កិច្ចសន្យានោះមិនត្រូវរារាំងនូវអានុភាពឡើយ ។ ប៉ុន្តែ ក្នុងករណីដែលភាគីម្ខាងទៀតក៏ដឹងថាការបង្ហាញឆន្ទៈនោះ ខុសនឹងឆន្ទៈពិតរបស់អ្នកបង្ហាញឆន្ទៈដែរ អ្នកបង្ហាញឆន្ទៈនោះអាចបដិសេធការអនុវត្តកិច្ចសន្យាបាន ។

**មាត្រា ៣៥៣.–** ការបង្ហាញឆន្ទៈមិនពិត

១-កិច្ចសន្យា ដោយផ្អែកលើការបង្ហាញឆន្ទៈមិនពិតដែលត្រូវបានធ្វើឡើង ដោយមានការឃុបឃិតជាមួយនឹងភាគីម្ខាងទៀត ត្រូវចាត់ទុកជាមោឃៈ ។

២-មោឃភាពនៃកិច្ចសន្យាដែលបានកំណត់នៅកថាខណ្ឌទី ១ ខាងលើនេះ មិនអាចអះអាងចំពោះតតិយជនដែលមានទំនាក់ទំនងផលប្រយោជន៍ ដោយយកកិច្ចសន្យាដែលផ្អែកលើការបង្ហាញឆន្ទៈមិនពិតជាមូលដ្ឋានបានឡើយ ។ ប៉ុន្តែ បញ្ញត្តិនេះមិនត្រូវយកមកអនុវត្តឡើយ ចំពោះករណីដែលតតិយជននោះជាជនទុច្ចរិត ឬ មិនបានដឹងអំពីការបង្ហាញនូវឆន្ទៈមិនពិតដោយមានកំហុសធ្ងន់ធ្ងរ ។

**មាត្រា ៣៥៤.–** ភាពខុសច្បាប់ ឬ ភាពផ្ទុយនឹងសណ្តាប់ធ្នាប់សាធារណៈ និង ទំនៀមទម្លាប់ល្អ ក្នុងអត្ថន័យនៃកិច្ចសន្យា

១-ទោះបីជាភាគីនៃកិច្ចសន្យាបានធ្វើការបង្ហាញឆន្ទៈដោយគ្មានវិការៈក៏ដោយ ក៏កិច្ចសន្យាត្រូវបានចាត់ទុកជាមោឃៈ ក្នុងករណីខាងក្រោមនេះ :

ក-អត្ថន័យនៃកិច្ចសន្យានោះផ្ទុយនឹងបញ្ញត្តិដែលអនុវត្តដោយបង្ខំណាមួយ ។

ខ-អត្ថន័យនៃកិច្ចសន្យានោះផ្ទុយនឹងសណ្តាប់ធ្នាប់សាធារណៈ និង ទំនៀមទម្លាប់ល្អ ។

២-ប្រសិនបើអត្ថន័យនៃកិច្ចសន្យាមានផ្នែកណាមួយដែលផ្ទុយនឹងបញ្ញត្តិដែល

អនុវត្តដោយបង្ខំ ឬ ផ្ទុយនឹងសណ្ដាប់ធ្នាប់សាធារណៈ និង ទំនៀមទម្លាប់ល្អ ហើយទោះបីជាទុកផ្នែកផ្សេងទៀត ក៏មិនធ្វើឱ្យខូចសេចក្ដីសង្ឃឹមសមហេតុសមផលរបស់គូភាគីទេ នោះមានតែចំណុចដែលផ្ទុយនឹងបញ្ញត្តិដែលអនុវត្តដោយបង្ខំ ឬ ផ្ទុយនឹងសណ្ដាប់ធ្នាប់សាធារណៈ និង ទំនៀមទម្លាប់ល្អតែប៉ុណ្ណោះទេ ដែលត្រូវទុកជាមោឃៈ ។

**មាត្រា ៣៥៥.–** អលទ្ធភាពតាំងពីដំបូង

១-ទោះបីជាអត្ថន័យនៃកិច្ចសន្យាមិនអាចសម្រេចបានតាំងពីពេលដែលបង្កើតកិច្ចសន្យានោះក៏ដោយ ក៏កិច្ចសន្យានោះមិនត្រូវបានចាត់ទុកជាមោឃៈដោយយកមូលហេតុនៃអលទ្ធភាពនោះដែរ ។ ប៉ុន្តែ បញ្ញត្តិនេះមិនរារាំងភាគីក្នុងការលុបចោលនូវកិច្ចសន្យាដោយយកមូលហេតុនៃការភាន់ច្រឡំឡើយ ក្នុងករណីដែលល័ក្ខខ័ណ្ឌនៃការភាន់ច្រឡំត្រូវបានបំពេញ ។

២-ក្នុងករណីដែលភាគីដែលគួរតែអាចដឹងថា អត្ថន័យនៃកិច្ចសន្យាមិនអាចសម្រេចតាំងពីដំបូងបាន នាំឱ្យមានការខូចខាតដល់ភាគីម្ខាងទៀតដោយសារការបង្កើតកិច្ចសន្យា ភាគីនោះត្រូវទទួលខុសត្រូវក្នុងការសងការខូចខាតដល់ភាគីម្ខាងទៀត ដោយផ្អែកលើបញ្ញត្តិនៃមាត្រា ៣៩៨ (ល័ក្ខខ័ណ្ឌនៃការទទួលខុសត្រូវក្នុងការសងសំណងនៃការខូចខាត) នៃក្រមនេះ ។

## ផ្នែកទី ៣
## មោឃភាព និង ការលុបចោល

**មាត្រា ៣៥៦ .–** និយមន័យនៃសកម្មភាព

ពាក្យ “សកម្មភាព” ក្នុងផ្នែកទី ៣ (មោឃភាព និង ការលុបចោល) នេះ សំដៅទៅលើកិច្ចសន្យា ឬ សកម្មភាពឯកតោភាគី ។

**មាត្រា ៣៥៧.–** អត្ថន័យនៃមោឃភាព

ប្រសិនបើអត្ថន័យនៃសកម្មភាព ផ្ទុយនឹងបញ្ញត្តិដែលអនុវត្តដោយបង្ខំ ឬ ផ្ទុយនឹងសណ្តាប់ធ្នាប់សាធារណៈ និង ទំនៀមទម្លាប់ល្អ ជនណាក៏អាចអះអាងនូវមោឃភាពនៃកិច្ចសន្យានោះបាន ។ ក្នុងករណីដែលសកម្មភាពត្រូវចាត់ទុកជាមោឃៈ ដោយសារសកម្មភាពនោះផ្ទុយនឹងទម្រង់ដែលត្រូវបានទាមទារឱ្យមាន ដោយក្រមនេះ ឬ ច្បាប់ផ្សេង ជនណាក៏អាចអះអាងនូវមោឃភាពនៃកិច្ចសន្យានោះបាន ។

**មាត្រា ៣៥៨.–** សកម្មភាពដែលអាចលុបចោលបាន

១-សកម្មភាពដែលអាចលុបចោលបាន មានសុពលភាព រហូតដល់ពេលដែលអ្នកមានសិទ្ធិលុបចោល លុបចោលសកម្មភាពនោះ ។

២-ក្នុងករណីដែលអ្នកមានសិទ្ធិលុបចោល បានលុបចោលសកម្មភាពដែលអាចលុបចោលបាន សកម្មភាពនេះត្រូវចាត់ទុកជាមោឃៈតាំងពីដំបូង ។

៣-ក្នុងករណីដែលអ្នកមានសិទ្ធិលុបចោល បានផ្តល់សច្ចានុមតិលើសកម្មភាពដែលអាចលុបចោលបាន សកម្មភាពនេះត្រូវមានសុពលភាពជាស្ថាពរ ។

**មាត្រា ៣៥៩.–** អ្នកដែលមានសិទ្ធិលុបចោល

១-ចំពោះសកម្មភាពដែលអាចលុបចោលបាន ដោយមូលហេតុថា មានវិការៈក្នុងការបង្ហាញឆន្ទៈដែលបានកំណត់ ចាប់ពីមាត្រា ៣៤៦ (ការភាន់ច្រឡំ) ដល់មាត្រា ៣៥១ (អំពើកេងយកចំណេញហួសហេតុ) នៃក្រមនេះ អ្នកដែលបង្ហាញឆន្ទៈដោយមានវិការៈ ឬ អ្នកតំណាងដែលច្បាប់បានកំណត់របស់អ្នកនោះ អាចលុបចោលនូវសកម្មភាពនោះបាន ។ សន្តតិជនរបស់អ្នកដែលបង្ហាញឆន្ទៈ ឬ អ្នកដែលទទួលបន្តឋានៈក្នុងកិច្ចសន្យាពីអ្នកដែលបង្ហាញឆន្ទៈ ក៏អាចអនុវត្តសិទ្ធិលុបចោលបានដែរ ។

២-ចំពោះការលុបចោល ដោយមូលហេតុគ្មានសមត្ថភាពក្នុងការបង្ហាញឆន្ទៈ អនីតិភាព ឬ ការកម្រិតសមត្ថភាពក្នុងការធ្វើសកម្មភាពផ្សេងទៀត សាមីខ្លួន អ្នកតំណាងដែលច្បាប់បានកំណត់ ឬ ហិតូបត្ថម្ភកៈនៃជននោះ អាចលុបចោលនូវសកម្មភាពបាន ។ សន្តតិជន ឬ អច្ច័យលាភីសកលរបស់សាមីខ្លួន ក៏អាចអនុវត្តសិទ្ធិលុបចោលបានដែរ ។

**មាត្រា ៣៦០.–** វិធីនៃការលុបចោល ឬ សច្ចានុមតិ

ក្នុងករណីដែលភាគីម្ខាងទៀតនៃសកម្មភាពដែលអាចលុបចោលបាន ត្រូវបានកំណត់ច្បាស់លាស់ ការលុបចោល ឬ សច្ចានុមតិត្រូវធ្វើឡើងដោយការជូនដំណឹងទៅភាគីម្ខាងទៀតនោះ ។ អានុភាពនៃការលុបចោល ឬ សច្ចានុមតិ ត្រូវកើតឡើងនៅពេលដែលដំណឹងនោះបានដល់ភាគីម្ខាងទៀតនោះ ។

**មាត្រា ៣៦១.–** អ្នកមានសិទ្ធិផ្តល់សច្ចានុមតិ និង ល័ក្ខខ័ណ្ឌនៃការផ្តល់សច្ចានុមតិ

១-អ្នកមានសិទ្ធិលុបចោល អាចផ្តល់សច្ចានុមតិចំពោះសកម្មភាពដែលអាចលុបចោលបាន ។ ប៉ុន្តែ ក្នុងករណីដែលលុបចោលសកម្មភាព ដោយយកការបង្ហាញឆន្ទៈដោយមានវិការៈជាមូលហេតុ អ្នកមានសិទ្ធិលុបចោលអាចផ្តល់សច្ចានុមតិបាន ចាប់តាំងពីពេលដែលអ្នកមានសិទ្ធិលុបចោលនោះបានដឹងអំពីមូលហេតុនៃការលុបចោល ។ រីឯសកម្មភាពរបស់ជនដែលត្រូវបានកម្រិតសមត្ថភាពវិញ អ្នកមានសិទ្ធិលុបចោលអាចផ្តល់សច្ចានុមតិបាន នៅក្រោយពេលដែលស្ថានភាពដែលជាមូលហេតុនៃការលុបចោលត្រូវរលត់ ។

២-បញ្ញត្តិនៃវាក្យខណ្ឌទី ៣ កថាខណ្ឌទី ១ ខាងលើនេះ មិនត្រូវយកមកអនុវត្តឡើយ ចំពោះករណីដែលអ្នកតំណាងដែលច្បាប់បានកំណត់ ឬ ហិតូបត្ថម្ភកៈរបស់ជនដែលត្រូវបានកម្រិតសមត្ថភាពផ្តល់សច្ចានុមតិ ។

**មាត្រា ៣៦២.–** សច្ចានុមតិដែលច្បាប់បានកំណត់

នៅក្រោយពេលដែលអាចផ្តល់សច្ចានុមតិតាមបញ្ញត្តិនៃមាត្រា ៣៦១ (អ្នកមានសិទ្ធិផ្តល់សច្ចានុមតិ និង ល័ក្ខខ័ណ្ឌនៃការផ្តល់សច្ចានុមតិ) ខាងលើ សកម្មភាពដែលអាចលុបចោលបាន ត្រូវចាត់ទុកថា បានផ្តល់សច្ចានុមតិរួចហើយ ក្នុងករណីមានហេតុដូចខាងក្រោមនេះ :

ក-ការអនុវត្តកាតព្វកិច្ចទាំងមូល ឬ មួយផ្នែក ចំពោះកាតព្វកិច្ចដែលកើតឡើងដោយសកម្មភាពដែលអាចលុបចោលបាន ឬ ការដាក់ប្រាតិភោគដើម្បីធានាកាតព្វកិច្ចនោះ ។

ខ-ការអនុវត្តសិទ្ធិដែលបានទទួលពីសកម្មភាពដែលអាចលុបចោលបាន ឬ ការ

ទាមទារឱ្យភាគីម្ខាងទៀតអនុវត្ត ។

គ-អនុប្បទាន ឬ ការចាត់ចែងផ្សេងទៀតនូវសិទ្ធិទាំងមូល ឬ មួយផ្នែក ចំពោះសិទ្ធិដែលបានទទួលពីសកម្មភាពដែលអាចលុបចោលបាន ។

ប៉ុន្តែ បញ្ញត្តិនេះមិនត្រូវយកមកអនុវត្តឡើយ បើមានថបនីយថា ខ្លួនមិនបានផ្តល់សច្ចានុមតិ នៅពេលដែលហេតុដែលបានកំណត់នៅក្នុងករណីទាំងបីខាងលើនោះ កើតឡើង ។

**មាត្រា ៣៦៣.–** អាជ្ញាយុកាលនៃការរំលត់សិទ្ធិលុបចោល

១-ប្រសិនបើអ្នកមានសិទ្ធិលុបចោលមិនអនុវត្តសិទ្ធិនោះក្នុងរយៈពេល ៣ (បី) ឆ្នាំ ចាប់តាំងពីពេលដែលខ្លួនក្លាយទៅជាអ្នកដែលអាចផ្តល់សច្ចានុមតិ នោះសិទ្ធិលុបចោល និង សិទ្ធិទាមទារឱ្យសងសេចក្តីចម្រើនដោយឥតហេតុដែលកើតឡើង ដោយសារការលុបចោលនោះ ត្រូវរលត់ ។ បញ្ញត្តិស្តីពីការផ្អាកអាជ្ញាយុកាលមិនត្រូវយកមកអនុវត្តឡើយ ចំពោះអំឡុងពេលនេះ ។

២-ទោះបីជាមានបញ្ញត្តិនៃកថាខណ្ឌទី ១ ខាងលើនេះក៏ដោយ ប្រសិនបើហួសអំឡុងពេល ១០ (ដប់) ឆ្នាំ ចាប់តាំងពីកាលបរិច្ឆេទនៃសកម្មភាព នោះសិទ្ធិលុបចោលក៏ត្រូវរលត់ដែរ ។

៣-ក្នុងករណីដែលបុគ្គលច្រើននាក់មានសិទ្ធិលុបចោលនូវសកម្មភាពតែមួយ បញ្ញត្តិនៃកថាខណ្ឌទី ១ និង កថាខណ្ឌទី ២ ខាងលើនេះត្រូវយកមកអនុវត្ត ចំពោះសិទ្ធិលុបចោលនៃបុគ្គលនីមួយៗនោះ ។

## ផ្នែកទី ៤
## ការតំណាង

**មាត្រា ៣៦៤.–** និយមន័យនៃការតំណាង

ការតំណាងសំដៅទៅលើទំនាក់ទំនងគតិយុត្តដែលអានុភាពនៃកិច្ចសន្យាត្រូវមានចំពោះម្ចាស់សិទ្ធិផ្ទាល់ ក្នុងករណីដែលអ្នកតំណាង ធ្វើកិច្ចសន្យាជាមួយភាគីម្ខាងទៀត

ត្រូវយកមកអនុវត្តឡើយ ចំពោះករណីដែលកាតព្វកិច្ចរបស់ភាគីម្ខាងទៀត មិនទាន់ដល់ពេលកំណត់ដើម្បីអនុវត្ត ។

**មាត្រា ៣៨៧.–** ការតវ៉ាដោយមានការបារម្ភ

ភាគីដែលត្រូវអនុវត្តកាតព្វកិច្ចជាមុន នៅក្នុងកិច្ចសន្យាអញ្ញមញ្ញ អាចប្រកែកមិនព្រមអនុវត្តកាតព្វកិច្ចរបស់ខ្លួនបាន ក្នុងករណីដែលមានការបារម្ភដែលគួរឱ្យកត់សម្គាល់ថា ភាគីម្ខាងទៀតនឹងមិនអនុវត្តតាមខ្លឹមសារនៃកាតព្វកិច្ច ។ ប៉ុន្តែ បញ្ញត្តិនេះមិនត្រូវយកមកអនុវត្តឡើយ ចំពោះករណីដែលភាគីម្ខាងទៀតដាក់ប្រាតិភោគ ឬ ចាត់ចែងវិធានការផ្សេងទៀត ដើម្បីរំលត់ការបារម្ភនោះ ។

**មាត្រា ៣៨៨.–** ការអនុវត្តតាមបញ្ញត្តិស្ដីពីការសង

ក្រៅពីបញ្ញត្តិនៃជំពូកទី ៣ (ការអនុវត្តកិច្ចសន្យា) នេះ បញ្ញត្តិស្ដីពីការសងដែលបានកំណត់នៅក្នុងផ្នែកទី ១ (ការសង) នៃជំពូកទី ៧ ត្រូវយកមកអនុវត្តដូចគ្នាផងដែរ ចំពោះការអនុវត្តកិច្ចសន្យា ។

## ជំពូកទី ៤
## ការសង្គ្រោះចំពោះការបំពានលើកិច្ចសន្យា

### ផ្នែកទី ១
### បទប្បញ្ញត្តិទូទៅស្ដីពីការមិនអនុវត្តកាតព្វកិច្ច

**មាត្រា ៣៨៩.–** និយមន័យ និង ទម្រង់នៃការមិនអនុវត្តកាតព្វកិច្ច

ការមិនអនុវត្តកាតព្វកិច្ច សំដៅទៅលើករណីដែលកូនបំណុលមិនអនុវត្តកាតព្វកិច្ចដែលកើតឡើងពីកិច្ចសន្យា ។ ទម្រង់នៃការមិនអនុវត្តកាតព្វកិច្ច មានដូចខាងក្រោមនេះ :

ក-កូនបំណុលមិនអាចអនុវត្តកាតព្វកិច្ចឱ្យទាន់ពេលកំណត់ត្រូវអនុវត្ត ដោយសារការយឺតយ៉ាវក្នុងការអនុវត្ត ។

ខ-អលទ្ធភាពក្នុងការអនុវត្តកាតព្វកិច្ច ។

គ-កូនបំណុលមិនបានអនុវត្តឱ្យបានពេញលេញ តាមខ្លឹមសារនៃកាតព្វកិច្ច ។

ឃ-ករណីផ្សេងទៀតដែលគ្មានការអនុវត្តតាមខ្លឹមសារនៃកាតព្វកិច្ច ។

**មាត្រា ៣៩០.-** វិធីសង្គ្រោះចំពោះការមិនអនុវត្តកាតព្វកិច្ច

ក្នុងករណីដែលមានការមិនអនុវត្តកាតព្វកិច្ចរបស់កូនបំណុល ម្ចាស់បំណុលអាចទាមទារឱ្យអនុវត្តដោយបង្ខំ សងសំណងនៃការខូចខាត ឬ រំលាយកិច្ចសន្យា ដោយយោងតាមបញ្ញត្តិចាប់ពីផ្នែកទី ២ ដល់ផ្នែកទី ៤ នៃជំពូកទី ៤ នេះបាន ។

**មាត្រា ៣៩១.-** ការយឺតយ៉ាវក្នុងការអនុវត្ត

កូនបំណុលត្រូវបានចាត់ទុកថា មានការយឺតយ៉ាវក្នុងការអនុវត្ត ក្នុងករណីដែលខ្លួនមិនបានអនុវត្តកាតព្វកិច្ច នៅពេលដែលបានកំណត់ដូចខាងក្រោមនេះ :

ក-ប្រសិនបើមានកំណត់ពេលពិតប្រាកដសម្រាប់អនុវត្តកាតព្វកិច្ច នៅពេលដល់កាលកំណត់នោះ ។

ខ-ប្រសិនបើមានកំណត់ពេលមិនពិតប្រាកដសម្រាប់អនុវត្តកាតព្វកិច្ច នៅពេលដែលកូនបំណុលនោះដឹងថា ដល់ពេលកំណត់ហើយ ។

គ-ប្រសិនបើមិនបានកំណត់ពេលសម្រាប់អនុវត្តកាតព្វកិច្ចទេ នៅពេលដែលកូនបំណុលនោះទទួលការទាមទារឱ្យអនុវត្ត ។

**មាត្រា ៣៩២.-** អលទ្ធភាពក្នុងការអនុវត្ត

១-ប្រសិនបើគ្មានលទ្ធភាពក្នុងការអនុវត្តទេ ការអនុវត្តកាតព្វកិច្ចត្រូវក្លាយជាអលទ្ធភាព ។ អលទ្ធភាពនេះ ត្រូវរាប់បញ្ចូលទាំងករណីដែលការអនុវត្តកាតព្វកិច្ចនោះត្រូវបានវាយតម្លៃថា មិនអាចធ្វើកើត តាមស្ថានភាពសង្គម ឬ សេដ្ឋកិច្ច ។

២-ប្រសិនបើការណ៍ដែលមិនអាចអនុវត្តកាតព្វកិច្ចនៅពេលកំណត់ដែលត្រូវអនុវត្តមានពិតប្រាកដមុនពេលកំណត់ដែលត្រូវអនុវត្ត ការអនុវត្តកាតព្វកិច្ចត្រូវក្លាយជាអលទ្ធភាពនៅពេលនោះ ។

**មាត្រា ៣៩៣.–** ការអនុវត្តកាតព្វកិច្ចមិនបានពេញលេញ

ការមិនអនុវត្តកាតព្វកិច្ច សំដៅទៅលើករណីដែលកូនបំណុលបានអនុវត្តកាតព្វកិច្ច តែការផ្តល់តាវកាលិកមិនពេញលេញ ឬ ករណីដែលបានអនុវត្តតែមួយផ្នែកនៃកាតព្វកិច្ច ឬ ករណីផ្សេងទៀតដែលគ្មានការអនុវត្តឱ្យបានពេញលេញតាមខ្លឹមសារនៃកាតព្វកិច្ច ។

**មាត្រា ៣៩៤.–** ករណីផ្សេងនៃការមិនអនុវត្តកាតព្វកិច្ច

ក្រៅពីបញ្ញត្តិនៃមាត្រា ៣៩១ (ការយឺតយ៉ាវក្នុងការអនុវត្ត) មាត្រា ៣៩២ (អលទ្ធភាពក្នុងការអនុវត្ត) និង មាត្រា ៣៩៣ (ការអនុវត្តកាតព្វកិច្ចមិនបានពេញលេញ) នៃក្រមនេះ ករណីដែលមានការបំពានករណីយកិច្ចផ្សេងដែលកើតឡើងពីកិច្ចសន្យា ក៏ត្រូវចាត់ជាការមិនអនុវត្តកាតព្វកិច្ចដែរ ។

**មាត្រា ៣៩៥.–** ពហុមធ្យោបាយសង្គ្រោះ

ក្នុងករណីដែលមធ្យោបាយសង្គ្រោះមានច្រើនយ៉ាងអនុញ្ញាតចំពោះម្ចាស់បំណុល នោះម្ចាស់បំណុលអាចជ្រើសរើសមធ្យោបាយណាមួយ ឬ ច្រើន កុំឱ្យតែមធ្យោបាយទាំងនោះមានភាពផ្ទុយគ្នា ។

## ផ្នែកទី ២
## ការឱ្យអនុវត្តកាតព្វកិច្ចដោយបង្ខំ

**មាត្រា ៣៩៦.–** ដីកាបង្គាប់ឱ្យអនុវត្តកាតព្វកិច្ចដោយតុលាការ

ក្នុងករណីដែលកូនបំណុលមិនអនុវត្តកាតព្វកិច្ចដោយស្ម័គ្រចិត្តទេ ម្ចាស់បំណុលអាចទាមទារឱ្យអនុវត្តកាតព្វកិច្ចដោយបង្ខំបាន លើកលែងតែករណីដែលកាតព្វកិច្ចមានលក្ខណៈមិនអាចអនុវត្តដោយបង្ខំបាន ។ នីតិវិធីនៃការអនុវត្តដោយបង្ខំ ត្រូវអនុលោមតាមក្រមនីតិវិធីរដ្ឋប្បវេណី ។

**មាត្រា ៣៩៧.–** ទំនាក់ទំនងរវាងការទាមទារឱ្យអនុវត្តកាតព្វកិច្ច និង មធ្យោបាយផ្សេងៗ

ក្នុងករណីដែលកូនបំណុលមិនអនុវត្តកាតព្វកិច្ច ម្ចាស់បំណុលអាចទាមទារឱ្យសងការខូចខាត ជំនួសការទាមទារឱ្យអនុវត្តកាតព្វកិច្ច ឬ ជាមួយការទាមទារឱ្យអនុវត្តកាតព្វកិច្ច ក្នុងទំហំដែលមិនមានភាពផ្ទុយគ្នា ។

## ផ្នែកទី ៣
## សំណងនៃការខូចខាត

**មាត្រា ៣៩៨.–** ល័ក្ខខ័ណ្ឌនៃការទទួលខុសត្រូវក្នុងការសងសំណងនៃការខូចខាត

១-ក្នុងករណីដែលកូនបំណុលមិនបានអនុវត្តកាតព្វកិច្ចទេ ម្ចាស់បំណុលអាចទាមទារសំណងនៃការខូចខាតដែលកើតឡើង ដោយសារការមិនអនុវត្តកាតព្វកិច្ចនោះបាន ។ ប៉ុន្តែ ក្នុងករណីដែលកូនបំណុលមានសំអាងបញ្ជាក់ថា ខ្លួនគ្មានកំហុស ចំពោះការមិនអនុវត្តកាតព្វកិច្ចនោះទេ កូនបំណុលនោះត្រូវរួចផុតពីការទទួលខុសត្រូវក្នុងការសងសំណងខូចខាត ។

២-ក្នុងករណីដែលកូនបំណុលឱ្យអ្នកដទៃទៀតធ្វើជាអ្នកជំនួយដើម្បីឱ្យជួយអនុវត្តកាតព្វកិច្ច កូនបំណុលនោះមិនអាចរួចផុតពីការទទួលខុសត្រូវក្នុងការសងសំណងខូចខាតបានទេ លើកលែងតែកូនបំណុលនោះមានសំអាងបញ្ជាក់ថា ខ្លួនគ្មានកំហុសក្នុងការជ្រើសតាំង និង ការត្រួតពិនិត្យអ្នកជំនួយទេ ហើយអ្នកជំនួយនោះក៏គ្មានកំហុសដែរ ។

**មាត្រា ៣៩៩.–** បញ្ញត្តិពិសេសអំពីកាតព្វកិច្ចជាប្រាក់

១-ចំពោះកាតព្វកិច្ចដែលមានគោលបំណងសងជាប្រាក់ ទោះបីជាកូនបំណុលមានសំអាងបញ្ជាក់ថា ការយឺតយ៉ាវក្នុងការសងបានកើតឡើងដោយប្រធានសក្តិក៏ដោយ ក៏កូនបំណុលនោះមិនអាចរួចផុតពីការសងការប្រាក់ក្នុងអំឡុងពេលនៃការយឺតយ៉ាវនោះបានដែរ ។ ការប្រាក់ក្នុងអំឡុងពេលនៃការយឺតយ៉ាវនោះ ត្រូវគណនាតាមអត្រាការប្រាក់ដែលច្បាប់បានកំណត់ ។ បើអត្រាការប្រាក់ក្នុងកិច្ចសន្យា ខ្ពស់ជាងអត្រាការប្រាក់ដែលច្បាប់បានកំណត់ នោះត្រូវគណនាតាមអត្រាការប្រាក់ក្នុងកិច្ចសន្យា ។

២-ចំពោះការខូចខាតដែលមានចំនួនលើសពីការប្រាក់ក្នុងអំឡុងពេលនៃការយឺតយ៉ាវ ប្រសិនបើកូនបំណុលមានសំអាងបញ្ជាក់ថា ខ្លួនគ្មានកំហុសចំពោះការមិនអនុវត្តកាតព្វកិច្ចនោះទេ នោះកូនបំណុលត្រូវរួចផុតពីការទទួលខុសត្រូវក្នុងការសងការខូចខាតនោះ ។

**មាត្រា ៤០០.–** ទស្សនៈអំពីការខូចខាត

១-ម្ចាស់បំណុលអាចទាមទារនូវសំណងនៃការខូចខាត គឺ អាចទាមទារនូវសំណងនៃផលប្រយោជន៍ពីការអនុវត្តដែលខ្លួនត្រូវទទួលបានដោយកិច្ចសន្យានោះ ហើយក្រៅពីនេះ អាចទាមទារផងដែរនូវចំណាយដែលគ្មានប្រយោជន៍ដោយសារការមិនអនុវត្ត និងចំណាយ ឬ បន្ទុកដែលបង្កើនឡើងដោយសារការមិនអនុវត្តកាតព្វកិច្ច ក្នុងទំហំដែលមិនជាន់គ្នាជាមួយនឹងសំណងនៃផលប្រយោជន៍ពីការអនុវត្ត ។

២-តុលាការក៏អាចបង្គាប់ឱ្យកូនបំណុលសងសំណងនៃការខូចខាតខាងផ្លូវចិត្តដោយផ្អែកលើការទាមទាររបស់ម្ចាស់បំណុលបានដែរ ។ ចំពោះចំនួនសំណងនៃការខូចខាតខាងផ្លូវចិត្ត តុលាការត្រូវសម្រេចដោយគិតពិចារណាអំពីកាលៈទេសៈជុំវិញផ្សេងៗ ។

**មាត្រា ៤០១.–** ទំហំនៃសំណងការខូចខាត

កូនបំណុលត្រូវសងការខូចខាត ដូចខាងក្រោមនេះ :

ក-ការខូចខាតដែលកើតមានឡើងជាធម្មតាចំពោះម្ចាស់បំណុល ដោយសារការមិនបានអនុវត្តកាតព្វកិច្ច ។

ខ-ការខូចខាតដែលកើតឡើងចំពោះម្ចាស់បំណុលដោយសារកាលៈទេសៈពិសេស បើគូភាគីនៃកិច្ចសន្យាអាចព្យាករបាននូវការខូចខាតនោះដែលនឹងអាចកើតឡើងនៅពេលធ្វើកិច្ចសន្យានោះ ។ ប៉ុន្តែ បញ្ញត្តិនេះមិនត្រូវយកមកអនុវត្តឡើយ ចំពោះករណីដែលគូភាគីនៃកិច្ចសន្យា មិនបានគិតពិចារណាអំពីការខូចខាតពិសេសនោះ នៅពេលធ្វើកិច្ចសន្យា ។

គ-ក្នុងករណីដែលកូនបំណុលមិនអនុវត្តកាតព្វកិច្ចដោយមានឆន្ទៈព្យាបាទ ឬដោយអំពើមិនស្មោះត្រង់ហួសហេតុ តុលាការអាចបង្គាប់ឱ្យកូនបំណុលសងផលប្រយោជន៍

ដែលកូនបំណុលបានទទួលពីអំពើដែលជាការមិនអនុវត្តកាតព្វកិច្ច ដោយផ្អែកលើការទាមទាររបស់ម្ចាស់បំណុលបាន ទោះបីមានបញ្ញត្តិក្នុងចំណុច ក និង ចំណុច ខ ខាងលើនេះក៏ដោយ ។

**មាត្រា ៤០២.–** ហេតុដែលនាំឱ្យបន្ថយសំណងនៃការខូចខាត

១-កាលបើការមិនបានអនុវត្តកាតព្វកិច្ច ឬ ការខូចខាតកើតឡើង ផ្នែកខ្លះត្រូវបានបង្កឡើងដោយកំហុសរបស់ម្ចាស់បំណុល តុលាការអាចបន្ថយនូវចំនួននៃសំណងការខូចខាតដែលកូនបំណុលត្រូវសងបាន តាមកម្រិតនៃការបង្កនោះ ។

២-ក្នុងករណីដែលការខូចខាតបានកើនឡើង ដោយសារម្ចាស់បំណុលធ្វេសប្រហែសក្នុងការសម្រាលការខូចខាតនោះ តុលាការអាចបន្ថយចំនួននៃសំណងការខូចខាតដែលកូនបំណុលត្រូវសងបាន តាមចំនួននៃការខូចខាតដែលម្ចាស់បំណុលអាចសម្រាលបាននោះ ។

**មាត្រា ៤០៣.–** ការកំណត់ជាមុននូវចំនួននៃសំណង ជាអាទិ៍

១-ម្ចាស់បំណុល និង កូនបំណុល អាចកំណត់ជាមុននូវការសន្យាពិសេសអំពីល័ក្ខខ័ណ្ឌ និង ចំនួនសំណងការខូចខាតបាន ។

២-ការសន្យាពិសេសដែលឱ្យកូនបំណុលរួចផុតជាមុនពីការទទួលខុសត្រូវក្នុងការមិនអនុវត្តកាតព្វកិច្ចដោយចេតនា ឬ ដោយកំហុសដ៏ធ្ងន់ធ្ងររបស់ខ្លួន មិនមានអានុភាពឡើយ ។

៣-ក្នុងករណីដែលភាគីទាំងសងខាងបានធ្វើការសន្យាពិសេសអំពីចំនួននៃសំណងការខូចខាត តុលាការមិនអាចបន្ថែម ឬ បន្ថយចំនួននោះបានទេ ។ ប៉ុន្តែ ក្នុងករណីដែលចំនួនទឹកប្រាក់ដែលភាគីទាំងសងខាងបានកំណត់ជាមុននោះ ច្រើនហួសហេតុពេក ឬ តិចហួសហេតុពេក បើប្រៀបធៀបទៅនឹងការខូចខាតដែលត្រូវបានកំណត់តាមបញ្ញត្តិនៃមាត្រា ៤០១ (ទំហំនៃសំណងការខូចខាត) ខាងលើនេះ ទើបតុលាការអាចបន្ថែម ឬ បន្ថយនូវប្រាក់សំណងដែលបានកំណត់ជាមុនបាន ។

៤-ការកំណត់ជាមុននូវចំនួននៃសំណង មិនរារាំងការទាមទារឱ្យអនុវត្តកាតព្វកិច្ច

ឬ ឱ្យរំលាយកិច្ចសន្យាទេ ។ ក្នុងករណីដែលម្ចាស់បំណុលរំលាយកិច្ចសន្យា ហើយទាមទារសំណងនៃការខូចខាតដែលជាការជំនួសកម្មវត្ថុនៃកិច្ចសន្យា ចំនួនទឹកប្រាក់នៃសំណងដែលភាគីទាំងសងខាងបានព្រមព្រៀងគ្នាដោយគិតជាមុន អំពីការខូចខាតដែលកើតឡើងដោយការយឺតយ៉ាវក្នុងការអនុវត្តកាតព្វកិច្ចនោះ មិនត្រូវចងគូភាគីទេ ។

៥-ប្រាក់ធានាសំណងក្នុងករណីបំពានកិច្ចសន្យា ត្រូវសន្មតថាជាការកំណត់ជាមុននូវចំនួននៃសំណង ។

**មាត្រា ៤០៤.–** គោលការណ៍នៃការសងការខូចខាតជាប្រាក់

ចំពោះសំណងនៃការខូចខាតដែលកើតឡើងដោយការមិនអនុវត្តកាតព្វកិច្ច កូនបំណុលត្រូវសងជាប្រាក់ ។ ប៉ុន្តែ បញ្ញត្តិនេះមិនត្រូវយកមកអនុវត្តឡើយ ចំពោះករណីដែលភាគីទាំងសងខាងបានកំណត់ផ្សេងពីនេះដោយការសន្យាពិសេស ។

**មាត្រា ៤០៥.–** ឧបាទេសកម្មនៃអ្នកសង

ប្រសិនបើម្ចាស់បំណុលបានទទួលនូវសំណងនៃការខូចខាតដោយការសងតម្លៃនៃវត្ថុ ឬ សិទ្ធិដែលជាអត្ថន័យនៃសិទ្ធិលើបំណុល កូនបំណុលត្រូវទទួលឋានៈដែលម្ចាស់បំណុលធ្លាប់មានចំពោះវត្ថុ ឬ សិទ្ធិនោះ ដោយស្វ័យប្រវត្តិ ។

**មាត្រា ៤០៦.–** អាជ្ញាយុកាលនៃការរំលត់សិទ្ធិទាមទារសំណង

អាជ្ញាយុកាលនៃការរំលត់សិទ្ធិទាមទារឱ្យសងការខូចខាតដោយសារការមិនអនុវត្តកាតព្វកិច្ច មានអំឡុងពេល ៥ (ប្រាំ) ឆ្នាំ ក្រោយពីពេលដែលការខូចខាតនោះកើតឡើង ។

## ផ្នែកទី ៤

## ការរំលាយកិច្ចសន្យា

**មាត្រា ៤០៧.–** ការរំលាយដោយមូលហេតុមិនអនុវត្តកាតព្វកិច្ច

ភាគីម្ខាងនៃកិច្ចសន្យាអញ្ញមញ្ញអាចរំលាយកិច្ចសន្យាបានភ្លាមៗ ក្នុងករណីដែលភាគីម្ខាងទៀតបំពានកិច្ចសន្យាយ៉ាងធ្ងន់ធ្ងរ ។

**មាត្រា ៤០៨.–** ការបំពានកិច្ចសន្យាយ៉ាងធ្ងន់ធ្ងរ

១-ការបំពានកិច្ចសន្យាយ៉ាងធ្ងន់ធ្ងរ សំដៅទៅលើករណីដែលភាគីម្ខាងមិនអាចសម្រេចនូវគោលបំណងនៃកិច្ចសន្យាបាន ដោយសារការបំពានរបស់ភាគីម្ខាងទៀត ។ ត្រូវចាត់ទុកថាមានការបំពានកិច្ចសន្យាយ៉ាងធ្ងន់ធ្ងរ ក្នុងករណីដូចខាងក្រោមនេះ :

ក- ភាគីម្ខាងបានដាស់តឿនភាគីម្ខាងទៀតដែលមិនបានអនុវត្តកាតព្វកិច្ច តាមពេលកំណត់ ដោយកំណត់អំឡុងពេលសមរម្យដើម្បីឱ្យអនុវត្តកាតព្វកិច្ច ហើយកាតព្វកិច្ចមិនត្រូវបានអនុវត្តក្នុងអំឡុងពេលនោះ ។

ខ-ភាគីមិនបានអនុវត្តកាតព្វកិច្ចតាមពេលកំណត់ក្នុងកិច្ចសន្យា ក្នុងករណីដែលគោលបំណងនៃកិច្ចសន្យាមិនបានសម្រេចសោះ បើភាគីមិនអនុវត្តកាតព្វកិច្ចតាមពេលកំណត់នោះ ។

គ-ភាគីមិនអាចអនុវត្តករណីយកិច្ចផ្តល់តាវកាលិកចម្បងរបស់ខ្លួនបានទេ ។

ឃ-ការបំពានកិច្ចសន្យាមានភាពហួសហេតុ ដែលធ្វើឱ្យបាត់បង់នូវទំនុកចិត្តរវាងគូភាគី ហើយមិនអាចជឿជាក់ថា នឹងអនុវត្តកាតព្វកិច្ចនាអនាគតបាន ។

២-ភាគីដែលបំពានកិច្ចសន្យា មិនអាចរារាំងការរំលាយកិច្ចសន្យាដោយផ្អែកលើបញ្ញត្តិនៃកថាខណ្ឌទី ១ ខាងលើនេះ ដោយយកមូលហេតុថាខ្លួនគ្មានកំហុសចំពោះការមិនអនុវត្តកាតព្វកិច្ចរបស់ខ្លួន បានឡើយ ។

**មាត្រា ៤០៩.–** វិធីអនុវត្តសិទ្ធិរំលាយកិច្ចសន្យា

១-ភាគីម្ខាងដែលមានសិទ្ធិរំលាយ អាចរំលាយកិច្ចសន្យា ដោយបង្ហាញឆន្ទៈរំលាយចំពោះភាគីម្ខាងទៀតបាន ។ ការបង្ហាញឆន្ទៈរំលាយនេះអាចធ្វើឡើងក្រៅតុលាការបាន ។

២-ការបង្ហាញឆន្ទៈរំលាយនេះ មិនអាចដកវិញបានទេ ។

៣-ការបង្ហាញឆន្ទៈរំលាយនេះ អាចដាក់ល័ក្ខខ័ណ្ឌបង្អង់បាន ។

**មាត្រា ៤១០.–** ការរំលាយកិច្ចសន្យាដែលភាគីម្ខាងមានច្រើននាក់

១-ក្នុងករណីដែលភាគីម្ខាងមានច្រើននាក់ ការរំលាយកិច្ចសន្យាត្រូវធ្វើឡើងដោយ

បុគ្គលទាំងអស់នោះចំពោះភាគីម្ខាងទៀត ឬ ដោយភាគីម្ខាងទៀតចំពោះបុគ្គលទាំងអស់នោះ ។

២-ក្នុងករណីដែលបានកំណត់ក្នុងកថាខណ្ឌទី ១ ខាងលើនេះ ប្រសិនបើសិទ្ធិរំលាយកិច្ចសន្យាបានរលត់ចំពោះបុគ្គលណាម្នាក់ ក្នុងចំណោមបុគ្គលនៃភាគីដែលមានច្រើននាក់ សិទ្ធិរំលាយនោះក៏ត្រូវរលត់ចំពោះបុគ្គលផ្សេងទៀតនៃភាគីនោះដែរ ។

**មាត្រា ៤១១.–** អានុភាពនៃការរំលាយកិច្ចសន្យា

១-ការរំលាយកិច្ចសន្យានាំឱ្យគូភាគីរួចផុតពីករណីយកិច្ចក្នុងកិច្ចសន្យា លើកលែងតែករណីយកិច្ចសងការខូចខាត ។

២-ភាគីដែលបានទទួលតាវកាលិកនៃកិច្ចសន្យាតែមួយភាគ ឬ ទាំងអស់ ត្រូវមានករណីយកិច្ចសងតាវកាលិកនោះទៅភាគីម្ខាងទៀត ដើម្បីឱ្យភាគីនោះទទួលបដិទានឡើងវិញ ដោយសារការរំលាយ ។ ក្នុងករណីដែលភាគីទាំងសងខាង មានករណីយកិច្ចធ្វើបដិទានទៅវិញទៅមក ករណីយកិច្ចទាំងនោះត្រូវអនុវត្តនៅពេលជាមួយគ្នា ។

៣-ភាគីដែលមានករណីយកិច្ចសងជាប្រាក់ដោយការរំលាយកិច្ចសន្យា ត្រូវសងជាមួយនឹងការប្រាក់ដោយគិតចាប់ពីថ្ងៃដែលបានទទួលប្រាក់ដើមនោះ ។ ភាគីដែលមានករណីយកិច្ចបង្វិលជាវត្ថុ ឬ ជាតាវកាលិកផ្សេងដែលខ្លួនបានទទួល ទៅភាគីម្ខាងទៀតដោយសារការរំលាយ ត្រូវសងទាំងផលដែលបានទទួលពីវត្ថុ ឬ តាវកាលិកនោះផងដែរ ។

៤-ការរំលាយកិច្ចសន្យាមិនអាចធ្វើឱ្យខូចផលប្រយោជន៍ត្រឹមត្រូវរបស់តតិយជនបានឡើយ ។

**មាត្រា ៤១២.–** សិទ្ធិរំលាយក្នុងករណីដែលកម្មវត្ថុនៃកិច្ចសន្យាត្រូវបានខូចខាត ឬ បាត់បង់

១-សិទ្ធិរំលាយត្រូវរលត់ ក្នុងករណីភាគីដែលមានសិទ្ធិរំលាយបានធ្វើឱ្យមានការខូចខាត ឬ ការបាត់បង់ដល់វត្ថុដែលជាកម្មវត្ថុនៃកិច្ចសន្យា ឬ មិនអាចសងវត្ថុនោះវិញបានដោយចេតនា ឬ ធ្វើឱ្យវត្ថុនោះក្លាយជាវត្ថុប្រភេទផ្សេង ដោយការកែច្នៃ ឬ ការផ្លាស់ទម្រង់ដោយចេតនា ។

២-ក្នុងករណីដែលបានកំណត់នៅកថាខណ្ឌទី ១ ខាងលើនេះ បើភាគីបានអនុវត្ត សិទ្ធិរំលាយ ភាគីនោះត្រូវសងជាប្រាក់នូវតម្លៃនៃវត្ថុដែលជាកម្មវត្ថុនោះ ត្រឹមកម្រិតតម្លៃ ដែលបានកំណត់ក្នុងកិច្ចសន្យា ។

៣-ក្នុងករណីដែលភាគីម្ខាងទៀតមានកំហុស ឬ មានមូលហេតុក្នុងការខូចខាត ឬ ការមិនបានសងវត្ថុដែលជាកម្មវត្ថុនោះ ភាគីដែលមានសិទ្ធិរំលាយ គ្មានករណីយកិច្ចក្នុង ការសងជាប្រាក់នូវតម្លៃនៃវត្ថុនោះ ដូចបានកំណត់នៅក្នុងកថាខណ្ឌទី ២ ខាងលើនេះ ឡើយ ។

**មាត្រា ៤១៣.-** អាជ្ញាយុកាលនៃការរំលត់សិទ្ធិរំលាយកិច្ចសន្យា

អាជ្ញាយុកាលនៃការរំលត់សិទ្ធិរំលាយកិច្ចសន្យាដោយមូលហេតុនៃការមិនអនុវត្ត កាតព្វកិច្ច និង សិទ្ធិទាមទារបដិទាន មានអំឡុងពេល ៥ (ប្រាំ) ឆ្នាំ ក្រោយពីពេលដែល មិនបានអនុវត្តកាតព្វកិច្ច ។

**មាត្រា ៤១៤.-** សិទ្ធិរំលាយដែលបានកំណត់ក្នុងកិច្ចសន្យា និង ការរំលាយដោយការ ព្រមព្រៀងគ្នា

១-គូភាគីនៃកិច្ចសន្យាអាចសន្យាឱ្យភាគីម្ខាង ឬ សងខាងមានសិទ្ធិរំលាយ នៅក្នុង កិច្ចសន្យានោះបាន ។ បញ្ញត្តិពីមាត្រា ៤០៩ (វិធីអនុវត្តសិទ្ធិរំលាយកិច្ចសន្យា) ដល់មាត្រា ៤១២ (សិទ្ធិរំលាយក្នុងករណីដែលកម្មវត្ថុនៃកិច្ចសន្យាត្រូវបានខូចខាត ឬ បាត់បង់) នៃ ក្រមនេះ ស្ដីពីការរំលាយដែលច្បាប់បានកំណត់ ត្រូវយកមកអនុវត្តដូចគ្នាផងដែរ ចំពោះ វិធីអនុវត្ត និង អានុភាពនៃសិទ្ធិរំលាយ ដែលបានកំណត់ដោយកិច្ចសន្យា លើកលែងតែ មានការព្រមព្រៀងគ្នាផ្សេង ។

២-ទោះបីជាគ្មានការកំណត់សិទ្ធិរំលាយក្នុងកិច្ចសន្យាក៏ដោយ ក៏គូភាគីអាចរំលាយ កិច្ចសន្យាដោយការព្រមព្រៀងគ្នាបានដែរ ។ ប៉ុន្តែ ការរំលាយនោះមិនអាចធ្វើឱ្យខូចផល ប្រយោជន៍របស់តតិយជនបានទេ ។

## ព្រះរាជាណាចក្រកម្ពុជា

## ជាតិ សាសនា ព្រះមហាក្សត្រ

### កិច្ចសន្យាលក់_ទិញដី_ផ្ទះ

ខ្ញុំបាទ-នាងខ្ញុំឈ្មោះ................................អាយុ............ឆ្នាំ កាន់អត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរលេខ............. ចុះថ្ងៃទី...........ខែ..........ឆ្នាំ.......... មានទីលំនៅផ្ទះលេខ............ផ្លូវលេខ........... ក្រុមទី............ភូមិ.................... ឃុំ/សង្កាត់......................ស្រុក/ខណ្ឌ......................ខេត្ត/ក្រុង...................... ហៅកាត់ថា **ភាគី"ក" ជាអ្នកទិញ** .......................................... ។

ខ្ញុំបាទ-នាងខ្ញុំឈ្មោះ................................អាយុ............ឆ្នាំ កាន់អត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរលេខ............. ចុះថ្ងៃទី...........ខែ..........ឆ្នាំ.......... មានទីលំនៅផ្ទះលេខ............ផ្លូវលេខ........... ក្រុមទី............ភូមិ.................... ឃុំ/សង្កាត់......................ស្រុក/ខណ្ឌ......................ខេត្ត/ក្រុង...................... ហៅកាត់ថា **ភាគី"ខ" ជាអ្នកលក់** ..........................................។

***ភាគី"ក" និងភាគី"ខ" បានព្រមព្រៀងចុះកិច្ចសន្យាលក់-ទិញ តាមប្រការដូចខាងក្រោម:***

**<u>ប្រការ១</u>: អចលនទ្រព្យ ដី ឬផ្ទះ**

បណ្ណសំគាល់សិទ្ធិកាន់កាប់អចលនទ្រព្យលេខ....................................ចុះថ្ងៃទី..........ខែ..........ឆ្នាំ........... ចេញ ដោយស្ថាប័នមានសមត្ថកិច្ច....................................................................................... ។

**<u>ប្រការ២</u>: អំពីតម្លៃអចលនទ្រព្យ និងការទូទាត់**

ភាគីទាំងពីរបានឯកភាពលើតម្លៃអចលនទ្រព្យ គឺ.....................ដុល្លារ (.............................................) ដែលត្រូវទូទាត់តាមរយៈ តាមសាច់ប្រាក់សុទ្ធ នៅពេលដែល ភាគី"ខ" រៀបចំឯកសាររួចរាល់ផ្តល់ឱ្យភាគី"ក" ចុះថ្ងៃទី..........ខែ.............ឆ្នាំ.............. ។

**<u>ប្រការ៣</u>: ការទទួលខុសត្រូវរបស់ភាគី"ខ"**

ត្រូវបំពេញបែបបទលើឯកសារ (កាត់ឈ្មោះ) នៃអចលនទ្រព្យនេះប្រគល់ឱ្យភាគី"ក" ដោយថ្លៃចំណាយ នៃសេវា ក្នុងកាត់ឈ្មោះនេះជាការទទួលខុសត្រូវរបស់ភាគី"ខ" ។

**<u>ប្រការ៤</u>: ការទទួលខុសត្រូវរបស់ភាគី"ក"**

ភាគី"ក" មានសិទ្ធិកាន់កាប់ឯកសារទៅជំរះបញ្ជីលក់-ទិញ នៅគ្រប់ស្ថាប័នមានសមត្ថកិច្ច ។

**ប្រការ៥:** កិច្ចសន្យានេះធ្វើឡើងជាភាសាខ្មែរចំនួន ០៤ច្បាប់ សម្រាប់ភាគី "ក" និងភាគី "ខ" រក្សាទុកចំនួន ០១ច្បាប់ម្នាក់ មេធាវី ០១ច្បាប់ និងតំកល់ទុកនៅឃុំ/សង្កាត់ចំនួន ០១ច្បាប់ ។

**ប្រការ៦:** កិច្ចសន្យានេះធ្វើឡើងរវាងភាគី "ក" និងភាគី "ខ" ដោយគ្មានការបង្ខិតបង្ខំពីភាគីណាមួយឡើយ ហើយកិច្ចសន្យានេះមានសុពលភាពនៅពេលដែលចុះហត្ថលេខា និងផ្តិតស្នាមមេដៃស្តាំ ជាភស្តុតាង ។

ធ្វើនៅ................ ថ្ងៃទី..........ខែ...........ឆ្នាំ.............

| | | | |
|---|---|---|---|
| **ភាគី "ខ"** | **សាក្សីភាគី "ខ"** | **សាក្សីភាគី "ក"** | **ភាគី "ក"** |
| ឈ្មោះ.......................... | ឈ្មោះ.......................... | ឈ្មោះ.......................... | ឈ្មោះ.......................... |

លេខ:..................

បានឃើញ និង បញ្ជាក់ថា ស្នាមមេដៃស្តាំទាំងអស់តាមឈ្មោះរៀងគ្នាខាងលើ ពិតជាបានផ្តិតនៅចំពោះមុខយើងជាមេឃុំ/ចៅសង្កាត់ តាមខ្លឹមសារនៃកិច្ចសន្យាប្រាកដមែន ។

ធ្វើនៅ..............ថ្ងៃទី...........ខែ...........ឆ្នាំ.........

**មេឃុំ/ចៅសង្កាត់** ...................

បានឃើញ និង បញ្ជាក់ថា

ភាគីទាំងពីរបានផ្តិតមេដៃស្តាំ ចំពោះមុខមេធាវីប្រាកដមែន ។

ធ្វើនៅ.............ថ្ងៃទី.........ខែ..........ឆ្នាំ.........

**មេធាវី**

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

# <u>កិច្ចសន្យាព្រមព្រៀងជួលដី</u>

**កិច្ចព្រមព្រៀងជួលនេះ ត្រូវបានធ្វើឡើងរវាង:**

១- លោក.................................កាន់អត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរលេខ:.................................និងភរិយាឈ្មោះ .................................កាន់អត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរលេខ.................................មានអាស័យដ្ឋានលេខ ...............ផ្លូវលេខ...............សង្កាត់.................................ខណ្ឌ.................................ខេត្ត................................. ជាម្ចាស់ដី ដែលមានទីតាំង ស្ថិតនៅ................................................................................................................................................................(ចាប់ពីពេលនេះតទៅ ហៅកាត់ថា **ភាគី "ក"**) ។

**និង**

២- លោក .................................ភេទ...............

កើតនៅថ្ងៃទី..........ខែ..........ឆ្នាំ..........កាន់លិខិតឆ្លងដែនលេខ.................................មានអាស័យដ្ឋានលេខ ..........ផ្លូវ..........សង្កាត់.................................ខណ្ឌ.................................ខេត្ត................................. ជាអ្នកជួលដី (ចាប់ពីពេលនេះតទៅ ហៅកាត់ថា **ភាគី "ខ"**) ។

**ភាគី"ក" និងភាគី"ខ" បានព្រមព្រៀងគ្នាតាមប្រការ និងលក្ខខណ្ឌដូចតទៅ:**

**<u>ប្រការ១:</u> កិច្ចព្រមព្រៀងជួល**

**ភាគី "ក"** យល់ព្រមជួលដី អោយ **ភាគី "ខ"** ក្នុងរយ:ពេល...............ឆ្នាំ គិតចាប់ពីថ្ងៃទី ............... ខែ...............ឆ្នាំ...............រហូតដល់ថ្ងៃទី...............ខែ...............ឆ្នាំ...............(តទៅនេះហៅកាត់ថា **"រយ:ពេលជួល"**) ។

**<u>ប្រការ២:</u> ថ្លៃឈ្នួលប្រចាំខែ**

ថ្លៃឈ្នួលប្រចាំខែគឺ...............USD (...............ដុល្លារអាមេរិកក្នុងមួយខែ) ក្នុងរយ:ពេលជួល ហៅថា ប្រាក់ឈ្នួល **ភាគី "ខ"** ត្រូវបង់ប្រាក់ឈ្នួលទៅអោយ **ភាគី "ក"** នៃដើមខែនីមួយៗនៅរៀងរាល់ខែដោយចន្លោះពីថ្ងៃទី ០១ ដល់ថ្ងៃទី ០៧ នៃដើមខែនីមួយៗ ។ ប្រសិនបើ **ភាគី "ខ"** ខកខានមិនបានបង់ប្រាក់ឈ្នួលទៅតាមកិច្ចសន្យានេះទេ ប្រាក់កក់ និងត្រូវទុកជាអសារបង់ ហើយចំពោះកិច្ចសន្យាជួលដី ត្រូវទុកជាមោឃ:ដោយស្វ័យប្រវត្តិ ។

**<u>ប្រការ៣:</u> ប្រាក់កក់**

**ភាគី "ខ"** បានយល់ព្រមបង់ប្រាក់កក់ជូនទៅ **ភាគី "ក"** ចំនួន ............USD (...........................ដុល្លារអាមេរិក) ស្មើនឹងប្រាក់ឈ្នួលប្រចាំខែ ......ខែ ចាប់ពីពេលនេះតទៅហៅកាត់ថា ប្រាក់កក់ ប្រសិនបើ **ភាគី "ខ"** បញ្ចប់កិច្ចសន្យាជួលមុនកាលកំណត់ជួលនេះ ប្រាក់កក់ត្រូវទុកជាអសារបង់របស់ **ភាគី "ក"** ។ ប៉ុន្តែក្រោយពេលផុតកំណត់រយៈពេលជួល **ភាគី "ក"** ត្រូវបង្វិលប្រាក់កក់ជូន **ភាគី "ខ"** វិញគ្រប់ចំនួន ។

**<u>ប្រការ៤:</u> ការលក់ដី ឬផ្ទេរ**

ប្រសិនបើ **ភាគី "ក"** ធ្វើការលក់ដីខាងលើនេះទៅអោយភាគីណា ឬ ក្រុមហ៊ុនណាមួយផ្សេងនោះ **ភាគី "ក"** និងម្ចាស់កម្មសិទ្ធិថ្មីត្រូវរក្សា និងគោរពតាមគ្រប់លក្ខខណ្ឌនៃកិច្ចសន្យាជួលទៅដដែល រហូតដល់ពេលផុតកំណត់នៃកិច្ចសន្យាជួល ។ **ភាគី "ខ"** មិនត្រូវបានអនុញ្ញាតិអោយធ្វើការផ្ទេរ ឬ ជួលបន្តដីនេះទៅអោយភាគីទី៣ បានឡើយ ។ (អាចជួលបាន) ត្រូវតែជូនដំណឹង និងមានការឯកភាពយល់ព្រមពីសំណាក់ **ភាគី "ក"** ជាមុនសិន ។

**<u>ប្រការ៥:</u> លើប្រាក់ពន្ធ ទឹក ភ្លើង និងសេវាកម្មផ្សេងៗ**

**ភាគី "ខ"** ត្រូវទទួលខុសត្រូវថ្លៃប្រើប្រាស់ ទឹក ភ្លើងអគ្គិសនី សំរាម ទូរស័ព្ទ ទូរទស្សន៍ខ្សែកាប និងការបង់ពន្ធធ្វើអាជីវកម្មនៅលើដីនេះ ។ល។ តាមច្បាប់រដ្ឋដែលបានកំណត់អោយបង់ និងតាមវិក័យប័ត្រដែលក្រុមហ៊ុននីមួយៗបានផ្តល់អោយ ក្នុងកំឡុងពេលនៅកិច្ចសន្យាជួល ។ ប្រសិនបើវិក័យប័ត្រដែលមិនបានបង់ និងត្រូវកាត់យកពីប្រាក់កក់នៅពេលផុតកំណត់រយៈពេលជួល ។

**<u>ប្រការ៦:</u> សុវត្ថិភាពសង្គម និងការថែទាំ**

**ភាគី "ខ"** ត្រូវជួយថែទាំដីនេះក្នុងលក្ខណៈល្អត្រឹមត្រូវ និងមានអនាម័យក្នុងកំឡុងពេលជួល ហើយ **ភាគី "ខ"** មិនត្រូវប្រើប្រាស់ដីនេះ ដើម្បីធ្វើសកម្មភាពផ្ទុយ និងច្បាប់ ឬខុសច្បាប់ផ្សេងៗ ឡើយ ដូចជា: ជួញដូរគ្រឿងញៀន, បើកបន, ឬផ្ទុកអាវុធ ។ល។ ហើយត្រូវទទួលខុសត្រូវទាំងស្រុង ចំពោះសកម្មភាពរបស់ខ្លួនផ្ទាល់ ។ ករណីអគ្គិភ័យ និងការបង្កជំលោះជាមួយអ្នកជិតខាង និងការបាត់បង់ដែលបង្កឡើងដោយការធ្វេសប្រហែសរបស់ **ភាគី "ខ"** នោះ ជាបន្ទុករបស់ **ភាគី "ខ"** ក្នុងការសងការខូចខាត ។

**<u>ប្រការ៧:</u> ការយល់អំពីកិច្ចសន្យាជួល**

កិច្ចសន្យានេះត្រូវធ្វើឡើងចំនួន ០៣ច្បាប់ ដែលមានខ្លឹមសារ និងសុពលភាពស្មើគ្នា ។ ភាគីទាំងពីរបាន អានគ្រប់ខ្លឹមសារ និងលក្ខខណ្ឌក្នុងកិច្ចសន្យានេះ ហើយភាគីនីមួយៗ ត្រូវគោរពគ្រប់ប្រការតាម លក្ខខណ្ឌនៃកិច្ចសន្យានេះ ។ ប្រសិនបើភាគីណាមួយប្រព្រឹត្តបទល្មើស និងកិច្ចសន្យានេះ ភាគីនោះត្រូវ ទទួលខុសត្រូវចំពោះមុខច្បាប់ នៃព្រះរាជាណាចក្រកម្ពុជា ហើយកិច្ចសន្យានេះ ភាគីនីមួយៗរក្សាទុក ម្នាក់មួយច្បាប់ និងសាក្សីមួយច្បាប់ និងយល់ព្រមផ្តិតមេដៃស្តាំទុកជាភស្តុតាង ។

ធ្វើនៅ. ថ្ងៃទី ______ ខែ________ ឆ្នាំ __________

**ស្នាមមេដៃភាគី "ខ"** **សាក្សី** **ស្នាមមេដៃភាគី "ក"**

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

## លិខិតប្រគល់និងទទួលប្រាក់

ខ្ញុំបាទ-នាងខ្ញុំឈ្មោះ..........................អាយុ..........ឆ្នាំ កាន់អត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរលេខ....................
ចុះថ្ងៃទី.........ខែ..........ឆ្នាំ.......... មានទីលំនៅផ្ទះលេខ............ផ្លូវលេខ............ ក្រុមទី............ភូមិ....................
ឃុំ/សង្កាត់.....................ស្រុក/ខណ្ឌ.....................ខេត្ត/ក្រុង...................... ។

**បានទទួលប្រាក់ចំនួន**......................ដុល្លារ (..................................................) នៅថ្ងៃទី............
ខែ.............ឆ្នាំ............. ។

ខ្ញុំបាទ-នាងខ្ញុំឈ្មោះ..........................អាយុ..........ឆ្នាំ កាន់អត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរលេខ..............
ចុះថ្ងៃទី..........ខែ..........ឆ្នាំ.......... មានទីលំនៅផ្ទះលេខ............ផ្លូវលេខ............ ក្រុមទី............ភូមិ....................
ឃុំ/សង្កាត់.....................ស្រុក/ខណ្ឌ.....................ខេត្ត/ក្រុង...................... ។

ក្រែងពុំពិតប្រាកដយើងខ្ញុំទាំងពីរនាក់ សូមផ្តិតមេដៃស្តាំទុកជាភស្តុតាងតាមផ្លូវច្បាប់ ។

**ធ្វើនៅ...............ថ្ងៃទី..........ខែ...........ឆ្នាំ២០.......**

| **ស្នាមមេដៃស្តាំអ្នកទទួលប្រាក់** | **សាក្សីអ្នកទទួលប្រាក់** | **សាក្សីអ្នកប្រគល់ប្រាក់** | **ស្នាមមេដៃស្តាំអ្នកប្រគល់ប្រាក់** |
|---|---|---|---|
| ឈ្មោះ.......................... | ឈ្មោះ.......................... | ឈ្មោះ.......................... | ឈ្មោះ.......................... |

បានឃើញ និង បញ្ជាក់ថា

ភាគីទាំងពីរបានផ្តិតមេដៃស្តាំ ចំពោះមុខមេធាវី

ប្រាកដមែន ។

ធ្វើនៅ.............ថ្ងៃទី..........ខែ...........ឆ្នាំ..........

**មេធាវី**

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

## <u>កិច្ចសន្យាខ្ចីប្រាក់_ដាក់បញ្ចាំ</u>

រវាងខ្ញុំបាទ-នាងខ្ញុំឈ្មោះ..............................អាយុ.........ឆ្នាំ កាន់អត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរលេខ.............. ចុះថ្ងៃទី.........ខែ.........ឆ្នាំ......... មានទីលំនៅផ្ទះលេខ............ផ្លូវលេខ........... ក្រុមទី............ភូមិ.................. ឃុំ/សង្កាត់.......................ស្រុក/ខណ្ឌ......................ខេត្ត/ក្រុង...................... ហៅកាត់ថា **ភាគី“ក” ម្ចាស់ប្រាក់** ។

**និង**

ខ្ញុំបាទ-នាងខ្ញុំឈ្មោះ................................អាយុ...........ឆ្នាំ កាន់អត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរលេខ.............. ចុះថ្ងៃទី..........ខែ.........ឆ្នាំ.......... មានទីលំនៅផ្ទះលេខ...........ផ្លូវលេខ........... ក្រុមទី............ភូមិ.................. ឃុំ/សង្កាត់......................ស្រុក/ខណ្ឌ....................ខេត្ត/ក្រុង...................... ហៅកាត់ថា **ភាគី“ខ” ជាអ្នកខ្ចីប្រាក់** ។

***ភាគី“ក” និងភាគី“ខ” បានព្រមព្រៀង តាមប្រការដូចខាងក្រោម:***

**<u>ប្រការ១:</u>** ភាគី“ក” យល់ព្រមឱ្យភាគី“ខ” ខ្ចីប្រាក់ចំនួន......................ដុល្លារ (...................................................)

ភាគី“ខ”បានទទួលចំនួនទឹកប្រាក់នេះ នៅពេលចុះកិច្ចសន្យាចំពោះមុខសាក្សី និងមេធាវី ។

**<u>ប្រការ២:</u>** ភាគី“ខ” យល់ព្រមបង់ការប្រាក់ឱ្យភាគី“ក” ហើយភាគី“ក” យល់ព្រមទទួលការប្រាក់ពី ភាគី“ខ” ក្នុងអត្រាព្រមព្រៀង.............ភាគរយ ក្នុង១ខែ ស្មើនឹង...................(...................................................) នៃប្រាក់ដែលបានខ្ចី ។ រយៈពេល.................................នៃការខ្ចីប្រាក់ គិតចាប់ពីថ្ងៃទី...........ខែ............ ឆ្នាំ.......... រហូតដល់ថ្ងៃទី..........ខែ..........ឆ្នាំ........... ។

**<u>ប្រការ៣:</u>** ភាគី“ខ” យល់ព្រមបង់ការប្រាក់ឱ្យ ភាគី“ក” នៅថ្ងៃទី............ដើមខែនិមួយៗ ។ ភាគី“ក” យល់ព្រមឱ្យភាគី“ខ” បង់សងនូវចំនួនទឹកប្រាក់ខ្ចីទាំងអស់ ឬមួយផ្នែកណានោះ នៃកិច្ចសន្យានៅពេលណាក៏បានក្នុងពេលអនុវត្តកិច្ចសន្យានេះ បើកាលណាភាគី“ខ” មានបំណងចង់ចេញសងរួមទាំងប្រាក់ដើមនិងការប្រាក់ផង ។ ក្នុងករណីភាគី“ខ” ពុំបានបង់ការក្នុងរយៈពេល**<u>០៣ខែជាប់ៗគ្នានោះ</u>** ភាគី“ខ”យល់ព្រមឱ្យភាគី“ក” ប្រើសិទ្ធិរបស់ខ្លួនក្នុងការបញ្ឈប់ ឬបញ្ចប់កិច្ចសន្យានេះបានដោយឯកតោភាគី ។

ភាគី“ខ”បានយល់ព្រមថា ករណីបង់ការប្រាក់យឺតយ៉ាវរហូតដល់ ០៣ខែ អនុញ្ញាតឱ្យភាគី“ខ” រឹបអូសយកផ្ទះ និងដីដែលបានដាក់បញ្ចាំឱ្យភាគី“ខ” រួចចុះចេញពីផ្ទះ និងដី ដោយគ្មានលក្ខខណ្ឌអ្វីទាំងអស់ ។

**ប្រការ៤:** យោងកិច្ចសន្យានេះ ដើម្បីធានាដល់ការបំពេញកាតព្វកិច្ចភាគី˝ខ˝បានដាក់អចលនទ្រព្យធានាមានដូចជា:

| ល.រ | រាយមុខទ្រព្យសម្បត្តិដាក់បញ្ចាំ | ចំនួនច្បាប់ | ផ្សេងៗ |
|---|---|---|---|
| ១ | ប័ណ្ណសំគាល់សិទ្ធិកាន់កាប់អចលនទ្រព្យ:.........................................<br>ចុះថ្ងៃទី......ខែ.........ឆ្នាំ........( ក្រុម/ភូមិ..........ឃុំ/សង្កាត់............)<br>ស្រុក/ខណ្ឌ......................ខេត្ត/ក្រុង................................ ។ | | |
| ២ | ប័ណ្ណសំគាល់សិទ្ធិកាន់កាប់អចលនទ្រព្យ:.........................................<br>ចុះថ្ងៃទី......ខែ.........ឆ្នាំ........( ក្រុម/ភូមិ..........ឃុំ/សង្កាត់............)<br>ស្រុក/ខណ្ឌ......................ខេត្ត/ក្រុង................................ ។ | | |
| ៣ | ប័ណ្ណសំគាល់សិទ្ធិកាន់កាប់អចលនទ្រព្យ:.........................................<br>ចុះថ្ងៃទី......ខែ.........ឆ្នាំ........( ក្រុម/ភូមិ..........ឃុំ/សង្កាត់............)<br>ស្រុក/ខណ្ឌ......................ខេត្ត/ក្រុង................................ ។ | | |

**ប្រការ៥:** កិច្ចសន្យានេះធ្វើឡើងជាភាសាខ្មែរចំនួន ០៣ច្បាប់ សម្រាប់ភាគី˝ក˝ និងភាគី˝ខ˝ រក្សាទុកចំនួន ០១ច្បាប់ម្នាក់ មេធាវី ០១ច្បាប់ ។

**ប្រការ៦:** កិច្ចសន្យានេះធ្វើឡើងរវាងភាគី˝ក˝ និងភាគី˝ខ˝ ដោយគ្មានការបង្ខិតបង្ខំពីភាគីណាមួយឡើយ ហើយកិច្ចសន្យានេះមានសុពលភាពនៅពេលដែលចុះហត្ថលេខា និងផ្តិតស្នាមមេដៃស្តាំ ជាភស្តុតាង ។

ធ្វើនៅ................ ថ្ងៃទី..........ខែ...........ឆ្នាំ............

**ភាគី˝ខ˝** **សាក្សីភាគី˝ខ˝** **សាក្សីភាគី˝ក˝** **ភាគី˝ក˝**

ឈ្មោះ......................... ឈ្មោះ......................... ឈ្មោះ......................... ឈ្មោះ.........................

បានឃើញ និង បញ្ជាក់ថា
ភាគីទាំងពីរបានផ្តិតមេដៃស្តាំ ចំពោះមុខមេធាវី
ប្រាកដមែន ។
ធ្វើនៅ.............ថ្ងៃទី.........ខែ..........ឆ្នាំ..........
**មេធាវី**

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

## <u>លិខិតសងប្រាក់</u>

ខ្ញុំបាទ-នាងខ្ញុំឈ្មោះ..........................អាយុ.........ឆ្នាំ កាន់អត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរលេខ.................. ចុះថ្ងៃទី.........ខែ.........ឆ្នាំ......... មានទីលំនៅផ្ទះលេខ...........ផ្លូវលេខ.......... ក្រុមទី...........ភូមិ................. ឃុំ/សង្កាត់....................ស្រុក/ខណ្ឌ...................ខេត្ត/ក្រុង..................... ។

**បានសងប្រាក់ចំនួន**.....................ដុល្លារ (...........................................) នៅថ្ងៃទី........... ខែ...........ឆ្នាំ............ ។

ទៅឱ្យឈ្មោះ.............................អាយុ..........ឆ្នាំ កាន់អត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរលេខ...................... ចុះថ្ងៃទី..........ខែ.........ឆ្នាំ.......... មានទីលំនៅផ្ទះលេខ...........ផ្លូវលេខ.......... ក្រុមទី...........ភូមិ................. ឃុំ/សង្កាត់....................ស្រុក/ខណ្ឌ...................ខេត្ត/ក្រុង..................... ។

សងប្រាក់គ្រប់ចំនួន ហើយសូមបញ្ចប់នូវកិច្ចសន្យាទិញ-លក់ដីនិងផ្ទះ ចុះថ្ងៃទី........ខែ.........ឆ្នាំ.......... ចាប់ពីពេលនេះតទៅ ។

**ធ្វើនៅ.............ថ្ងៃទី.........ខែ..........ឆ្នាំ២០......**

| | | | |
|---|---|---|---|
| **ស្នាមមេដៃស្តាំសងប្រាក់** | **សាក្សីអ្នកសងប្រាក់** | **សាក្សីអ្នកទទួលប្រាក់** | **ស្នាមមេដៃស្តាំអ្នកទទួលប្រាក់** |
| ឈ្មោះ........................ | ឈ្មោះ........................ | ឈ្មោះ........................ | ឈ្មោះ........................ |

## ព្រះរាជាណាចក្រកម្ពុជា

### ជាតិ សាសនា ព្រះមហាក្សត្រ

## <u>កិច្ចព្រមព្រៀងលក់ផ្តាច់ (អចលនៈវត្ថុ)</u>

### <u>ធ្វើឡើងរវាង</u>

លោក........................អាយុ...........ឆ្នាំ មានទីលំនៅ ភូមិ.............ឃុំ-សង្កាត់......................
ស្រុក-ខណ្ឌ......................ខេត្ត-ក្រុង.................. លេខទូរស័ព្ទលេខ...................... កាន់អត្តសញ្ញាណប័ណ្ណ
សញ្ជាតិខ្មែរលេខ...................... ទូរស័ព្ទលេខៈ................................ ជាអ្នកមិញ្ញជី ( ហៅកាត់ថា **ភាគី ˝ក˝** ) ។

**និង**

លោក........................អាយុ...........ឆ្នាំ មានទីលំនៅ ភូមិ.............ឃុំ-សង្កាត់......................
ស្រុក-ខណ្ឌ......................ខេត្ត-ក្រុង.................. លេខទូរស័ព្ទលេខ...................... កាន់អត្តសញ្ញាណប័ណ្ណ
សញ្ជាតិខ្មែរលេខ...................... ទូរស័ព្ទលេខៈ................................ ជាអ្នកមិញ្ញជី ( ហៅកាត់ថា **ភាគី ˝ខ˝** ) ។

### <u>*ភាគីទាំងពីរបានព្រមព្រៀងគ្នាដូចខាងក្រោម:*</u>

**<u>ប្រការ១:</u>** **ភាគី ˝ក˝** មានដីទំហំ....................ស្ថិតនៅក្នុងភូមិ ..................ស្រុក............. ខេត្ត..............
ក្នុងតំលៃ ......... = .........ដុល្លារ (..............ដុល្លារអាមេរិក) (ក្នុងចំនួនដី .............ហិកតា) ។
រួមទាំងដើមឈើដែលមានដុះលើដី មានព្រំប្រទល់:

- ខាងជើងទល់នឹង.......................... - ខាងត្បូងទល់នឹង..........................
- ខាងកើតទល់នឹង.......................... - ខាងលិចទល់នឹង..........................

**<u>ប្រការ២:</u>** **ភាគី ˝ខ˝** យល់ព្រមប្រគល់ប្រាក់កក់ចំនួន ៣០% ស្មើនឹង ........................................
ជាប្រាក់កក់បណ្តោះអាសន្នលើចំណែកលើកទី១ នៃសរុបប្រាក់...........................................
នៅថ្ងៃទី..........ខែ...........ឆ្នាំ...........ដើម្បីយកទៅដោះស្រាយការងារផ្សេងៗដែលពាក់ព័ន្ធជាមួយ **ភាគី ˝ក˝** ។

**<u>ប្រការ៣:</u>** **ភាគី ˝ខ˝** យល់ព្រមប្រគល់ប្រាក់កក់ចំនួន ៥០% លើកទី២ ស្មើនឹង ..............................
នៅថ្ងៃទី..........ខែ...........ឆ្នាំ........... ដើម្បីមកកាត់ឈ្មោះផ្ទេរសិទ្ធិជូនភាគី ˝ខ˝ រួចរាល់ ។

**<u>ប្រការ៣:</u>** **ភាគី ˝ខ˝** ត្រូវប្រគល់ប្រាក់គ្រប់ចំនួននៅពេលដែល **ភាគី ˝ក˝** កាត់ឈ្មោះរួចរាល់ហើយ ត្រូវប្រាក់ដែលនៅចំនួន ២០% ស្មើនឹង.................................. នៃទឹកប្រាក់សរុបទាំង ។

**<u>ប្រការ៤:</u>** **ភាគី ˝ក˝** ក្រោយពីចុះកិច្ចព្រមព្រៀងនេះ និងទទួលប្រាក់កក់ថ្លៃដីរួចហើយ ត្រូវមានកាតព្វកិច្ចដូចខាងក្រោម :

- ត្រូវចេញមុខដោះស្រាយចំពោះមុខច្បាប់ និងចំណាយប្រាក់ដោយខ្លួនឯង ប្រសិនបើមានតតិយជនណាមួយមកតវ៉ាថា ដីលក់ខាងលើនេះ ជាដីរបស់ខ្លួនមិនបានលក់ទេ ។
- ក្នុងករណី**ភាគី"ក"** កែប្រែឈប់លក់វិញ មិនគោរពតាមកិច្ចសន្យានេះ **ភាគី"ក"** ត្រូវសងសងជំងឺចិត្ត ថ្លៃខាតពេលវេលា និងប្រាក់កក់ឱ្យ **ភាគី"ខ"** ស្មើនឹងប្រាក់កក់ទទួលបានគុណនឹង ២ដង ។
- ក្នុងករណី **ភាគី"ខ"** ដែលបានកក់ប្រាក់រួចហើយ ប្រែជាឈប់ទិញដីនោះវិញ ឬ មិនគោរពតាមកិច្ចសន្យាខាងលើប្រាក់កក់ដែលកក់ឱ្យ **ភាគី"ក"** ត្រូវចាត់ទុកជាមោឃៈ ។

**ប្រការ៥:** កិច្ចសន្យានេះធ្វើឡើងចំនួន ០៤ច្បាប់ ភាគី"ក" រក្សាទុកចំនួន ០១ច្បាប់ ភាគី"ខ" ចំនួន ០១ច្បាប់ និង មេធាវីចំនួនខាងសង ០២ច្បាប់ មានតំលៃ និងប្រសិទ្ធិស្មើគ្នា ។

**ប្រការ៦:** ភាគីទាំងពីរក្រោយពីអានកិច្ចសន្យា ហើយឯកភាពតាមខ្លឹមសារ នៃកិច្ចព្រមព្រៀងដូចមានចែងខាងលើទាំងស្រុងហើយ ភាគីទាំងពីរត្រូវផ្តិតមេដៃស្តាំទុកជាសំណុំ និង ទទួលអនុវត្តឱ្យបានល្អត្រឹមត្រូវតាមគោលការណ៍ច្បាប់ ។ ករណីមិនគោរពតាមកិច្ចព្រមព្រៀងនេះ ភាគីដែលមិនគោរពត្រូវទទួលខុសត្រូវចំពោះមុខច្បាប់ជាធរមាន នៃព្រះរាជាណាចក្រកម្ពុជា ។

ធ្វើនៅ. ថ្ងៃទី..........ខែ............ឆ្នាំ ២០.......

**ស្នាមមេដៃស្តាំភាគី"ខ"** **ស្នាមមេដៃស្តាំភាគី"ក"**

បានឃើញ និង បញ្ជាក់ថា

គូភាគីទាំងពីរបានផ្តិតមេដៃនៅចំពោះមុខយើង

មេធាវីប្រាកដមែន ។

ធ្វើនៅ. ថ្ងៃទី..........ខែ.............ឆ្នាំ២០....

**មេធាវី**

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

# កិច្ចសន្យាស្ម័គ្រចិត្តនៅបម្រើការងារ

ខ្ញុំបាទ/នាងខ្ញុំឈ្មោះ.........................................(ជាអក្សរឡាតាំង)..............................................

ភេទ.....................សញ្ជាតិ..........................កើតថ្ងៃទី..............ខែ......................ឆ្នាំ..........................

